ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និង កីឡា

កម្មវិធីសិក្សាលំអិត

តាសារខ្មែរ

សំរាប់

អប់រំមូលដ្ឋានចំណេះទូទៅ

ផ្សាយចេញពីនាយកដ្ឋានស្រាវជ្រាវគរុកោសល្យ ឆ្នាំ២០១៦

Production of these materials is made possible by the generous support of the American people through the Cambodia Basic Education (CBE) project, funded by United States Agency for International Development (USAID) and managed by RTI international.

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និង កីឡា
លេខ : ៦៧៣០ អយក.ប្រក.

ប្រកាស

ស្តីពី

ការអនុញ្ញាតឱ្យបោះពុម្ពផ្សាយឯកសារ

"កម្មវិធីសិក្សាលំអិតភាសាខ្មែរ សំរាប់អប់រំមូលដ្ឋានចំណេះទូទៅ "

~ ~ ~

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម /០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែកក្កដា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម ០១៩៦-០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ/បក ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ ក្រសួងអប់រំ យុវជន និង កីឡា
- យោងគោលនយោបាយសំរាប់អភិវឌ្ឍន៍កម្មវិធីសិក្សាចំណេះទូទៅ ២០០៥-២០០៩
- យោងរបាយការណ៍របស់អង្គប្រជុំតុមូល ចុះថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០០៦ ។

សម្រេច

ប្រការ ១.- អនុញ្ញាតឱ្យបោះពុម្ពផ្សាយឯកសារ " **កម្មវិធីសិក្សាលំអិតភាសាខ្មែរ សំរាប់អប់រំមូលដ្ឋានចំណេះទូទៅ** " ដែលរៀបចំ ដោយនាយកដ្ឋានស្រាវជ្រាវគរុកោសល្យ សហការជាមួយនឹងអង្គការ RTI ដើម្បីប្រើប្រាស់នៅតាមសាលារៀន ចំណេះទូទៅ ។

ប្រការ ២.- អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ អធិការដ្ឋានអប់រំ នាយកដ្ឋានស្រាវជ្រាវគរុកោសល្យ នាយកដ្ឋាន បឋមសិក្សា នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ និងអង្គការ RTI មានភារកិច្ចអនុវត្តប្រតាសនេះ ។

ភ្នំពេញ ថ្ងៃទី ៣៧ ខែ ៤៧ ឆ្នាំ ២០០៦

ហ្ឌិត ភុល ដេង

<u>កន្លែងទទួល</u> :
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី " ដើម្បីជ្រាបជាព័តិមាន "
- គ្រប់អង្គភាពក្រោមឱវាទក្រសួងអប់រំ យុវជន និងកីឡា " ដើម្បីមុខការ "
- ដូចប្រការ ២
- កាលប្បវត្តិ - ឯកសារ នា.សគ.

អាស័យដ្ឋានលេខ៨០ មហាវិថីព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២១៧ ២៥៣ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
Email: crsmeys@camnet.com.kh Web Site: www.moeys.gov.kh

កថាមុខ

ភាសាខ្មែរ គឺជាភាសាជាត និងជាភាសាសំរាប់ប្រើប្រាស់ជាផ្លូវការ ដែលប្រជាជនគ្រប់រូបត្រូវចេះដឹងគ្រប់ៗគ្នា។ ដូចនេះមុខវិជ្ជាភាសាខ្មែរ មានវិសាលភាពក្រៃលែង ព្រោះមុខវិជ្ជាភាសាខ្មែរ ជាមុខវិជ្ជាមូលដ្ឋានគ្រឹះ សំរាប់សិក្សាមុខវិជ្ជាដទៃទៀត ឱ្យបានល្អប្រសើរ និងសំរាប់ប្រើប្រាស់ គ្រប់ស្ថានភាពនៃជីវភាពរស់នៅ។ ជាពិសេស សិស្សានុសិស្ស នឹងមានចំណេះដឹងជ្រៅជ្រះ មានសមត្ថភាព សំរាប់អនាគតដែលមានភាពជាអ្នកដឹកនាំ ប្រកបដោយគុណធម៌ សីលធម៌សុជីវធម៌ និងការឈ្លាសវៃក្នុងការដោះស្រាយបញ្ហាទាំងឡាយ។ ដើម្បីឱ្យមុខវិជ្ជាភាសាខ្មែរ កាន់តែបំពេញមុខងារ សំបូរបែបរបស់ខ្លួន ប្រកបដោយគុណភាព និងប្រសិទ្ធភាពខ្ពស់ លុះណាតែមុខវិជ្ជានេះ មានសមត្ថភាពសមស្របទៅនឹងការវិវត្តរីកចំរើនរបស់មនុស្សជាតិ និង សង្គមជាតិ។ ដូចនេះការកែលំអកម្មវិធីសិក្សាមុខវិជ្ជា ភាសាខ្មែរ គឺជាការចាំបាច់ដើម្បីឆ្លើយតបនឹងតំរូវការជាក់ស្តែង ទាំងក្នុងការសិក្សា ទាំងក្នុងការប្រើប្រាស់ ទូទៅ ។ ម្យ៉ាងទៀត កម្មវិធីសិក្សាលំអិត នៃមុខវិជ្ជាភាសាខ្មែរនេះ ជាគោលបន្ទាត់ សំរាប់ការរៀបចំ ស្បៀវភៅសិក្សា តែសំភារឧបទេស វិធីសាស្ត្របង្រៀន និងយន្តការនានា ក្នុងការអភិវឌ្ឍវិសយ័អប់រំមួយ ដែលមានការចូលរួម ពីសំណាក់លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស មាតាបិតាសិស្ស និងសហគមន៍ ។

ក្រសួងអប់រំយុវជន និងកីឡាមានជំនឿយ៉ាងមុតមាំថា កម្មវិធីសិក្សាលំអិតនៃមុខវិជ្ជាភាសាខ្មែរ សំរាប់អប់រំមូលដ្ឋាននេះ នឹងចូលរួមបំរើឱ្យការកសាងធនធានមនុស្សនៅកម្ពុជា ប្រកបដោយគុណភាព និងមានជំនាញខ្ពស់ ព្រមទាំងរក្សាបាននូវភាពគង់វង្ស និងភាពរឹងមាំ នៃវប្បធម៌របស់ជាតិ ។

ក្នុងនាមក្រសួងអប់រំ យុវជន និងកីឡា ខ្ញុំសូមថ្លែងអំណរគុណដោយស្មោះ ចំពោះគំរោងអប់រំមូលដ្ឋាននៅកម្ពុជា CBE និងអ្នកជំនួយការបច្ចេកទេស ដែលបានចូលរួមបំពេញការងារនេះ យ៉ាងសកម្ម និងសូមកោតសរសើរផងដែរ ចំពោះស្នាដៃដ៏ថ្លៃថ្លារបស់ក្រុមការងារអភិវឌ្ឍកម្មវិធីសិក្សាទាំងអស់ ដែលបានយកអស់កំលាំងកាយ ចិត្ត ប្រាជ្ញា ស្មារតីក្នុងការកសាងឯកសារនេះឱ្យបានសំរេចជាផ្លែផ្កាឡើង ។

ជ. ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

រដ្ឋលេខាធិការ

អ៊ឹម សិទ្ធី

អារម្ភកថា

ភាសាខ្មែរ មិនត្រឹមតែជាភាសា ប្រើប្រាស់សំរាប់ ការប្រាស្រ័យទាក់ទងគ្នាប្រចាំថ្ងៃ ប៉ុណ្ណោះទេ តែសំខាន់ជាងនេះទៅទៀត ភាសាខ្មែរជាភាសាផ្លូវការ ដែលគេប្រើក្នុងកិច្ចការរដ្ឋ និងជាភាសាយាន សំរាប់សិក្សាមុខវិជ្ជាដទៃទៀត ។

កម្មវិធីសិក្សាភាសាខ្មែរ នៅកំរិតអប់រំមូលដ្ឋាន យកចិត្តទុកដាក់ លើការពង្រឹងគុណភាព និងពង្រីកសមត្ថភាពមូលដ្ឋាន ខាងការស្តាប់ ការនិយាយ ការអាន និងការសរសេរ ដែលត្រូវបានអនុវត្តតាំងពីបឋមសិក្សា រហូតដល់ថ្នាក់ឧត្តមសិក្សា និងសំរាប់ការបណ្តុះបណ្តាល វិជ្ជាជីវៈផ្សេងៗ ទៀត ។ កម្មវិធីសិក្សាភាសាខ្មែរ អភិវឌ្ឍបំណិននានានៃសមត្ថភាពទាំងបួន និងបំណិនផ្សេងៗទៀត ក្នុងគោលបំណងជួយសិស្ស ក្នុងការសិក្សាមុខវិជ្ជាដទៃទៀត និងប្រើប្រាស់ក្នុងជីវភាពប្រចាំថ្ងៃ ប្រកបដោយប្រសិទ្ធភាព និងដើម្បីត្រៀមខ្លួន បន្តការសិក្សាទៅកំរិតខ្ពស់ទៀត ។

កម្មវិធីសិក្សាមុខវិជ្ជាភាសាខ្មែរ បច្ចុប្បន្ននេះបានរៀបចំឡើង តាមលំដាប់លំដោយ តាំងពីថ្នាក់ទី១ រហូតដល់ថ្នាក់ទី៩ ដោយកំណត់លទ្ធផលសិក្សា តាមថ្នាក់នីមួយៗ ហើយតំរូវអោយសិស្សសំរេចអោយបាន នៅពេលបញ្ចប់ឆ្នាំសិក្សានីមួយៗ ។ ដើម្បីងាយស្រួល ក្នុងការប្រើប្រាស់កម្មវិធីសិក្សានេះ នៅក្នុងនោះ ក៏មាន ចំនួនមេរៀន រយៈពេលបង្រៀន បំណិន និងខ្លឹមសារ សំរាប់មេរៀននៃថ្នាក់នីមួយៗ ផងដែរ ។

គណៈកម្មការនិពន្ធសង្ឃឹមថា កម្មវិធីលំអិតកំរិតអប់រំមូលដ្ឋានមុខវិជ្ជាភាសាខ្មែរថ្មីនេះ អាចប្រើសំរាប់អភិវឌ្ឍស្បៀវភៅសិក្សា សំភារឧបទេស វិធីសាស្ត្របង្រៀន ការវាយតំលៃ និងវិធីនានាក្នុងការអភិវឌ្ឍ សមត្ថភាពសិស្ស អោយក្លាយជាពលរដ្ឋខ្មែរម្នាក់ ពូកែលើការងារច្រើនយ៉ាង និងមានប្រយោជន៍ សំរាប់ខ្លួនឯង គ្រួសារ សហគមន៍ និងប្រទេសជាតិ ។

គណៈកម្មការនិពន្ធកម្មវិធីសិក្សាមុខវិជ្ជាភាសាខ្មែរ

គណៈកម្មការអភិវឌ្ឍន៍កម្មវិធីសិក្សាភាសាខ្មែរ
សំរាប់ក៏រិតអប់រំមូលដ្ឋានចំណេះទូទៅ

កម្មវិធីសិក្សាមុខវិជ្ជា **ភាសាខ្មែរ** នេះត្រូវបានអភិវឌ្ឍដោយក្រសួងអប់រំ យុវជន និង កីឡា សហការជាមួយវិទ្យាស្ថានស្រាវជ្រាវត្រីកោណអន្តរជាតិ និង **OPCV/SKM** ដែលឧបត្ថម្ភថវិកាដោយ ទីភ្នាក់ងារសម្រាប់ការអភិវឌ្ឍអន្តរជាតិអាមេរិច ។

I. គណៈត្រប់ត្រង

១. ឯកឧត្តម កើ ណៃលាង

២. លោក លាង ងួនលី

៣. លោកស្រី ទន់ សាអ៊ីម

II. គណៈកម្មការរៀបចំកម្មវិធីសិក្សា

១. លោក យិន ធី

២. លោកស្រី ឈិន ស៊ីវឡេង

៣. លោកស្រី ម៉ៅ តាន់ណារី

៤. លោកស្រី ជា ចាន់នារី

៥. លោក កែវ មេន

៦. លោក ជួន សាក់

III. គណៈកម្មការពិនិត្យ

១. លោកស្រី ទន់ សាអ៊ីម

២. លោក ចាន់ សុភា

IV. អ្នកជំនួយបច្ចេកទេស

១. លោក ដេវិត ហូវ	OPCV/SKM
២. លោក ចន រឹត	RTI

លទ្ធផលសិក្សាភាសាខ្មែរ ថ្នាក់ទី ១

សមត្ថភាព	លទ្ធផលសិក្សា
ការស្តាប់	• ស្តាប់សួរសំដី និងសួរដំទៃទៀត
	• **ស្តាប់ និងបន្តឺសូរផ្សេងៗនៃព្យញ្ជនៈ** និងស្រៈ (**សូរ អ និងសូរ អ៊**)
	• **បង្ហាញឥរិយាបថក្នុងការស្តាប់ដោយយកចិត្តទុកដាក់ :** o **ស្តាប់ដោយគ្មានការរំខាន** o ធ្វើតាមការណែនាំងាយៗ មួយដំណាក់ ឬពីរដំណាក់
	• ស្តាប់រឿងនិងប្រាប់ឡើងវិញនូវផ្នែកខ្លះនៃរឿងដោយប្រើពាក្យផ្ទាល់ខ្លួន
ការនិយាយ	• ស្តាប់ និង សូត្រមេសូត្រ ឬ ច្រៀងចំរៀងខ្លីៗ តាមគ្រូ
	• ចាប់ផ្តើមប្រើប្រាស់ភាសាបានសមស្របតាមស្ថានភាពផ្សេងៗ ដោយនិយាយអោយបានច្បាស់លាស់ និងមានទំនុកចិត្ត ឧ: o ផ្តើយនឹងសំនួរដែលទាក់ទងព័ត៌មានអំពីខ្លួនឯង o ធ្វើការជាដៃគូ ដើម្បីសំដែងល្បែងដើរតួខ្លីៗ ងាយៗ ឧ: - ការជំរាបសួរ និងជំរាបលាគ្នាទៅវិញទៅមក - ការសំដែងការអរគុណ - ការណែនាំពីខ្លួនឯង និង ផ្តល់ព័ត៌មានងាយៗពីខ្លួនឯង
	• បង្កើនការប្រើប្រាស់ពាក្យបានទូលំទូលាយ ដើម្បី : o ហៅឈ្មោះវត្ថុផ្សេងៗដែលធ្លាប់ស្គាល់នៅក្នុង និងក្រៅថ្នាក់រៀន o ពណ៌នាអំពីវត្ថុ ទីកន្លែង មនុស្ស សត្វ និង រុក្ខជាតិ ដែលធ្លាប់ ស្គាល់
ការអាន	• **អានឮតួអក្សរនៃអក្ខរក្រម**
	• រៀបអក្សរតាមអក្ខរក្រម (ក្នុងវគ្គដែលបានរៀនរួចហើយ)
	• ប្រើវិធីងាយៗដើម្បីអានពាក្យ និងយល់ន័យនៃពាក្យ និងអត្ថបទខ្លីៗ: o ប្រើវិធីផ្សំសូរ ដើម្បីអានព្យញ្ជនៈផ្សំបានត្រឹមត្រូវ o ប្រើការចំណាំពាក្យមួយព្យាង្គ ពីរព្យាង្គដែលធ្លាប់ប្រើញឹកញាប់ o ប្រកបនិងផ្សំសូរព្យញ្ជនៈ និងស្រៈ o ប្រើទីសេចក្តី (រូបភាពបញ្ជាក់) o ភ្ជាប់ពាក្យទៅនឹងរូបភាព
ការសរសេរ	• បង្ហាញចលនាដៃបានត្រឹមត្រូវ ក្នុងការប្រើប្រាស់សំភារៈសរសេរនានា ដើម្បីចំលង និងគូររូបភាព
	• ចំលង និងសរសេរអក្សរទាំងអស់នៃអក្ខរក្រម បានត្រឹមត្រូវ
	• ហៅពាក្យងាយៗ (ធ្វើអក្ខរវិញ្ញាស) ពាក្យមួយព្យាង្គ និង ពាក្យពីរព្យាង្គបានត្រឹមត្រូវ
	• សរសេរឈ្មោះខ្លួនឯង
	• សរសេរតាមអានពាក្យ និងកន្សោមពាក្យងាយៗខ្លីៗ
	• សរសេរចំណងជើងរូបភាពវត្ថុ ទីកន្លែង មនុស្ស សត្វ និងរុក្ខជាតិដែលធ្លាប់ស្គាល់
ធ្វើការជាក្រុម	• ស្តាប់ និងធ្វើការជាដៃគូ ជាមួយនឹងអ្នកដទៃ

កំណត់សំគាល់: អក្សរដិតខ្មៅនៅក្នុងលទ្ធផលសិក្សាគឺដកចេញមកពីស្តង់ដា ជាចំណុចដែលកំណត់អោយសិស្សត្រូវតែសំរេចអោយបាន នៅដំណាច់ថ្នាក់ទី៣។

មេរៀនភាសាខ្មែរ ថ្នាក់ទី១

មេរៀនទី១ (៥២ ម៉ោ) **ទំព័រសៀវភៅ.ស**

• ស្គាល់សូរសំដីនិងសូរដទៃទៀត	
• និយាយនិងសំដែងកាយវិការគោរពជាក្រុម ឬជាបុគ្គល	៣
• អនុវត្ត និងចូលរួមក្នុងល្បែងដើរតួ ដោយប្រើសុជីវធម៌សង្គម និងការគោរព នៅពេលជួបគ្នា លាគ្នា អរគុណ និងឆ្លើយតបទៅនឹងពាក្យ "អរគុណ"	៣
• ចាប់ផ្តើមបង្ហាញសរិយាបថក្នុងការស្តាប់ ដោយយកចិត្តទុកដាក់ ដោយពុំមានការរំខាន	
• ឆ្លើយនឹងសំនួរងាយៗ ដោយផ្ទាល់មាត់	២
• ស្តាប់រឿងដែលមានរូបភាព និងពាក្យបញ្ជាក់: o យល់ន័យនៃពាក្យ ដែលបានស្តាប់ឮ ដោយមានរូបភាពបញ្ជាក់ o ចង្អុលបង្ហាញតួអក្សរដែលមានសូរសំលេងខុសៗគ្នា នៅក្នុងពាក្យដែលបានស្តាប់	
• ចាប់ផ្តើមរៀនច្រៀងចំរៀងតួអក្សរ	៦
• ចាប់ផ្តើមប្រើដីស ឬ ខ្មៅដៃ ដើម្បីគូសផ្នែកនៃតួអក្សរ	១១,១៧
• ចាប់ផ្តើមប្រើម្រាមដៃ និងដីស ដើម្បីភ្ជាប់ចំណុច និងសរសេរតួអក្សរ	២៩

មេរៀនទី២ (៥២ ម៉ោ)

ទំព័រសៀវភៅ.ស

• ណែនាំពីខ្លួនឯង ដោយប្រាប់ឈ្មោះ អាយុ និងថ្នាក់រៀន ហើយផ្តល់ព័តិមានងាយៗអំពីខ្លួន ឯង	៣៨,៣៩
• ស្តាប់ និងធ្វើតាមការណែនាំងាយៗមួយជំហាន ទាក់ទងទៅនឹងទំលាប់ក្នុងថ្នាក់រៀន • (ឧ. អង្គុយចុះ លើកដៃ...)	
• ប្រើពាក្យដែលទាក់ទងទៅនឹងវត្ថុនៅក្នុងថ្នាក់រៀន (តុ កៅអី សៀវភៅ ក្តារខៀន...)	២០,២១
• សួរសំនួរងាយៗ	
• ស្តាប់រឿង និងចូលរួមក្នុងការសូត្រកំណាព្យ និងច្រៀងចំរៀង: o ទះដៃតាមចង្វាក់ចំរៀង និងពាក្យជួន o រៀបរូបភាពតាមលំដាប់ព្រឹត្តិការណ៍នៃរឿងនិទាន	៤០ ៤០
• បង្ហាញប្រាប់ឈ្មោះវត្ថុ ឬ ឈ្មោះមនុស្សនៅក្នុងល្បែ ដែលបានស្តាប់	
• បន្តរៀនច្រៀងចំរៀងតួអក្សរ	៦
• ប្រើដីស ឬខ្មៅដៃ ដើម្បីគូសផ្នែកនៃតួអក្សរ	១១,១៧
• ប្រើម្រាមដៃ និងដីស ដើម្បីភ្ជាប់ចំណុច និងសរសេរតួអក្សរផ្សេងទៀត	២៩

មេរៀនទី៣ (៥២ម៉ោ) **ទំព័រស.ស**

• ចូលរួមក្នុងល្បែងដើរតួដើម្បីនិយាយនិងបង្ហាញកាយវិការផ្សេងៗក្នុងការគោរពមាតាបិតា និងសមាជិកគ្រួសារ បានត្រឹមត្រូវ	
• អនុវត្ត និងចូលរួមក្នុងល្បែងដើរតួ ដើម្បីណែនាំខ្លួនឯង និងផ្តល់ព័តិមានសំខាន់ៗអំពីខ្លួន	៦៨
• សូត្រមេសូត្រ និងច្រៀងចំរៀងងាយៗតាមគ្រូ	១០៥
• ស្គាល់ និងអានតួអក្សរមួយចំនួននៃអក្ខរក្រម	១២,១៣
• ស្គាល់ភាពខុសគ្នានៃសូរព្យញ្ជនៈ និងស្រៈមួយចំនួន : o បន្ទឺសូរនៃពាក្យដែលប្រើជាញឹកញាប់ o ព្យែករវាងព្យញ្ជនៈពួក"អ" និងពួក"អ៊"	១៤៦,១៤ ៧ ៥៨
• ស្គាល់ពាក្យដែលជាឈ្មោះខ្លួនឯង និងឈ្មោះមនុស្សក្នុងគ្រួសារ	៦៨,៨០
• អនុវត្តទំលាប់ល្អ ក្នុងការចាប់កាន់ខ្មៅដៃសរសេរ	
• គូសតាម និងសរសេរអក្សរនៃអក្ខរក្រម និងពាក្យមួយចំនួន	១២,១៣
• សរសេរឈ្មោះខ្លួនឯង (តាមគំរូ)	

មេរៀនទី៤ (៥២ម៉ោ) **ទំព័រស.ស**

• បញ្ជូនសារផ្ទាល់មាត់	
• ប្រើពាក្យ ខ្ញុំ អ្នក យើង (សព្វនាម) ជាប្រធាននៅក្នុងល្បែ	១២៣
• រាប់ឈ្មោះវត្ថុងាយៗនៅក្នុងថ្នាក់: o លេងល្បែងចំណាំវត្ថុ (ដាក់វត្ថុតូចៗចំនួន ៤ ឬ ៥ នៅលើតុ ដូចជា ថ្ម ស្លឹកឈើ ខ្មៅដៃ ក្រដាស អោយពេលវេលាសិស្សចំនួន ១៥ វិនាទី ដើម្បីមើល និងចំណាំ ហើយ គ្របវត្ថុទាំងនោះ អោយជិត ទើបអោយសិស្សហៅឈ្មោះវត្ថុទាំងនោះឡើងវិញ) ។ o លេងល្បែងសំនួរ " តើនេះជាអ្វី ?" ជាល្បែងសំរាប់សិស្សដទៃទៀតទាយថា វត្ថុនោះ គឺជាអ្វី នៅពេលដែលសិស្សម្នាក់ពណិនាអំពីវត្ថុនៅក្នុងបន្ទប់រៀននោះ	
• ស្តាប់រឿងដែលគេអានឮ ដោយយកចិត្តទុកដាក់ : o ប្រាប់ឡើងវិញ ផ្នែកពិសេសណាមួយ នៃរឿងដែលបានចងចាំ និងពណិនាពីតួអង្គ o ឆ្លើយនឹងសំនួរងាយៗ ទាក់ទងទៅនឹងព្រឹត្តិការណ៍នៃរឿង	៧០
• ហៅឈ្មោះតួអក្សរមួយចំនួនតាមអក្ខរក្រម	១២,១៣
• ស្គាល់ភាពខុសគ្នានៃសូរព្យញ្ជនៈ និងស្រៈមួយចំនួន	៤១
• អាន និងស្គាល់លក្ខណៈសំខាន់ៗនៃពាក្យមួយចំនួន ដែលប្រើញឹកញាប់ (ឧ. អក្សរខាងដើម ប្រវែង)	

• ចង្អុលបង្ហាញតួអក្សរ និង ពាក្យ នៅក្នុងឈ្មោះ	
• ហាត់កាន់ ខ្មៅដៃ និងប្រើចលនាដៃក្នុងការសរសេរបានល្អ	១២,១៣
• សរសេរអក្សរមួយចំនួន តាមលំដាប់ត្រឹមត្រូវ	
• សរសេរ និងធ្វើអក្ខរវិញ្ញាសពាក្យមួយព្យាង្គ មួយចំនួន ដែលប្រើញឹកញាប់	

មេរៀនទី៥ (៥២ម៉ោ) **ធំពាំរស.ស**

• បង្ហាញភាសានិយាយធម្មតាទាក់ទងទៅនឹងព័ត៌មានងាយៗស្តីពីឪពុកម្តាយឬអាណាព្យាបាល	
• ប្រើពាក្យដែលប្រើញឹកញាប់បានត្រឹមត្រូវ	៤៤,១៤៣
• ស្តាប់ការពណ៌នាផ្ទាល់ខ្លួនរបស់សមាជិកសហគមន៍ ដែលបានចូលមកក្នុងថ្នាក់រៀន ដើម្បីប្រាប់រឿងដែលទាក់ទងទៅនឹងព្រឹត្តិការណ៍នៅក្នុងភូមិដែលមិនអាចបំភ្លេចបាន ឬជីវិតរបស់ពួកគេផ្ទាល់ ហើយសួរសំនួរសមស្រប	
• ប្រើសព្វនាមកម្មសិទ្ធិ (ឧ. របស់ខ្ញុំ របស់អ្នក របស់នាង)	
• បង្ហាញរបៀបបើកមើលសៀវភៅ និងបើករកទំព័របានត្រឹមត្រូវ	
• ស្តាប់រឿង ដែលគេអានឮ ដោយយកចិត្តទុកដាក់ : o ប្រើផ្ទាំងក្រដាសសរសេរពាក្យ “នរណា?” “អ្វី?” “នៅពេលណា?” “នៅឯណា? ” នៅពេលប្រាប់ឡើងវិញ ឬសួរសំនួរអំពីរឿងខ្លី។ o ប្រាប់ឈ្មោះតួអង្គសំខាន់ៗក្នុងអត្ថបទនិងពណ៌នាអំពីចរិតលក្ខណៈមួយចំនួននៃតួអង្គ o បង្ហាញផ្នែកនៃរឿងដែលអមដោយរូបភាព	
• ភ្ជាប់ពាក្យទៅនឹងរូបភាព	៦១,៦៧
• បញ្ចេញសំលេង និងផ្សំព្យញ្ជនៈ និងស្រៈជាពាក្យ	១២,១៣
• ប្រើវិធីផ្សំសូរ ដើម្បីអានព្យញ្ជនៈផ្សំបានត្រឹមត្រូវ	១១៥
• ស្គាល់ពាក្យមួយព្យាង្គមួយចំនួន ដែលប្រើញឹកញាប់	១៣០
• បន្លឺសូរព្យញ្ជនៈខាងដើម និងខាងចុងនៃពាក្យខ្លី។	
• សរសេរ និងធ្វើអក្ខរវិញ្ញាសពាក្យមួយព្យាង្គ មួយចំនួន ដែលប្រើញឹកញាប់	

មេរៀនទី៦ (៤៨ម៉ោ) **ទំព័រស.ស**

• ប្រើពាក្យដែលទាក់ទងទៅនឹងទីតាំង ដែលខ្លួនរស់នៅ និងវត្ថុ (ខាងមុខ ខាងក្រោយ បន្ទាប់ ឆ្វេងស្តាំ លើ ក្រោម)	២០,២១
• ប្រាប់ទិសក្នុងការរកទីកន្លែង (ឧ. ទៅត្រង់ បត់ឆ្វេង)	
• ឆ្លើយនឹងសំនួរ "នៅឯណា" ដោយប្រើកន្សោមមានធ្នាក់ (ឧ. ក្នុងប្រអប់ ក្រោមផ្ទះ)	១១៩
• សំរួលសួរ និងការលើកដាក់សំលេង នៅពេលសួរសំនួរ	
• ស្តាប់រឿង ដែលគេអានឮ ដោយយកចិត្តទុកដាក់ : ហាត់និយាយសំដីសន្ទនាខ្លីៗ ដែលបានដកស្រង់ចេញមកពីរឿងដោយមានសំនួនវោហារសមស្រប	
• បង្ហាញគោលបំណងមួយចំនួននៃការអានរឿង (សំរាប់កែកំសាន្ត និងសំរាប់អប់រំ)	
• អានល្បះខ្លីៗ ដែលមានពាក្យប្រើជាញឹកញាប់	១២០
• ស្គាល់សញ្ញាខណ្ឌនៅចុងបញ្ចប់នៃល្បះ	
• សរសេរ និងប្រកបពាក្យដែលទាក់ទងទៅនឹងវត្ថុមួយចំនួន	២៤
• រៀបតួអក្សរមួយចំនួនតាមអក្ខរក្រម	

មេរៀនទី៧ (៤៨ម៉ោ) **ទំព័រស.ស**

• ប្រើពាក្យដែលទាក់ទងនៅនឹងចលនា (ឧ. ដើរ រត់ លោត ផ្លោះ)	១៤៣
• ប្រើកិរិយាដើម្បីពណ៌នាអំពីសកម្មភាព: o លេងល្បែង"សុខថា"ដើម្បីរៀនពាក្យបង្ហាញពីកិរិយា(ឧ. សិស្សប្តូរវេនដឹកនាំសកម្មភាព: សុខ និយាយថា "បិទភ្នែករបស់អ្នក" "លោតជើងឆ្វេង" ជាដើម)	
• បង្កើតតារាងពាក្យដែលបញ្ជាក់ពីសកម្មភាព	
• ស្តាប់ និងសូត្រមេសូត្រ និងច្រៀងចំរៀងខ្លីៗតាមគ្រូ	៤០ ១០៥
• ស្តាប់រឿង ដោយយកចិត្តទុកដាក់ ពេលគេអានរឿងជាច្រើនដង: o សំដែងល្បែងដើរតួ ដោយផ្អែកទៅលើសកម្មភាព ដែលពណ៌នានៅក្នុងអត្ថបទ	
• ប្រើរូបភាពបញ្ជាក់ ដើម្បីអានពាក្យ និងល្បះខ្លីៗ	
• សរសេតាមអានពាក្យ និងកន្សោមពាក្យខ្លីៗ	២៥

មេរៀនទី៨ (៤៦ម៉ោ) **ទំព័រស.ស**

• ប្រើគុណនាមក្នុងការពណ៌នាអំពីវត្ថុ សត្វ រុក្ខជាតិ និងមនុស្សដែលធ្លាប់ស្គាល់ (ឧ.ធំ តូច ក្រហម ខៀវ...)	១៤
• ពណ៌នារូបភាព ដោយប្រើពាក្យផ្ទាល់ខ្លួន	
• ស្តាប់រឿងដោយយកចិត្តទុកដាក់: o ប្រើរូបភាព ដើម្បីប៉ាន់ស្មានន័យនៃពាក្យដែលពុំធ្លាប់ស្គាល់ o ប្រាប់ឡើងវិញ នូវផ្នែកមួយចំនួននៃរឿង តាមរយៈល្បែងដើរតួ o បង្ហាញឈ្មោះរឿងដែលខ្លួនចូលចិត្ត ឬនឹកឃើញជាងគេ ហើយពន្យល់ពីមូលហេតុ	
• ចងក្រងជាសៀវភៅ នូវរូបភាពដែលខ្លួនបានគូរ និងពណ៌នាសង្ខេបពីការចូលចិត្ត និងមិនចូលចិត្តរបស់ខ្លួន ដោយយកសៀវភៅនោះទៅផ្ទះម្តងម្កាក់ ហើយបង្ហាញឪពុកម្តាយមើល	
• ធ្វើអក្ខរាវិញ្ញាសពាក្យពីរព្យាង្គ	

មេរៀនទី៩ (៤៦ម៉ោ) **ទំព័រស.ស**

• ពណ៌នាងាយៗអំពីសូរ ក្លិន រសជាតិ និងការប៉ះពាល់ ដោយប្រើគុណនាមបានសម ស្រប	
• ប្រើពាក្យដែលទាក់ទងទៅនឹងលំដាប់ពេលវេលា(ឧ. មុនដំបូង បន្ទាប់មក ចុងក្រោយ បង្អស់)	២៧
• សំដែងអំពីអារម្មណ៍ឆ្លើយតបទៅនឹងរឿង ដែលបានស្តាប់ (ឧ. គួរអោយចង់សើច ខ្ទល់ខ្វាយ ចាប់អារម្មណ៍)	
• ស្គាល់សញ្ញាសួរ	៥៩
• ធ្វើការបញ្ជាផ្ទាល់មាត់ (បើកទ្វារ ...)	
• ស្តាប់រឿង ដោយយកចិត្តទុកដាក់: o បង្ហាញចិត្តរំភើបរបស់តួអង្គនៅក្នុងអត្ថបទ(ឧ. ខឹង កើតទុក្ខ រំភើប នៅក្នុងសាច់រឿងដែលបានឮ)	
• សរសេរចំណងជើងរូបភាពវត្ថុ សត្វ	
• សរសេរតាមអានពាក្យ និងកន្សោមពាក្យខ្លីៗ	

មេរៀនទី១០ (៤៦ម៉ោ) **ទំព័រស.ស**

• ផ្តល់ការណែនាំផ្ទាល់មាត់ ពីរបៀបបំពេញកិច្ចការងាយៗមួយ (ឧ. ការដុសធ្មេញ)	
• ប្រើពាក្យត្រឹមត្រូវក្នុងការរាប់ឈ្មោះ ប្រភេទនៃសំលៀកបំពាក់ផ្សេងៗ	១៧០
• តំរូវពាក្យនឹងរូបភាពនៃសំលៀកបំពាក់	

• សួរ និងឆ្លើយសំនួរដែលទាក់ទងទៅនឹងសំលៀកបំពាក់ (ឧ. តើអាវគាត់មានពណ៌អ្វី?)	១៧១
• ប្រើពាក្យបានត្រឹមត្រូវ ក្នុងការរាប់ឈ្មោះចំណីអាហារធម្មតា	១៦៤
• តំរូវពាក្យនឹងរូបភាពនៃចំណីអាហារ	
• សួរ និងឆ្លើយសំនួរដែលទាក់ទងទៅនឹងបរិមាណ (ឧ. តើមានស៊ុតប៉ុន្មាននៅក្នុងកន្ត្រក?)	
• សរសេរចំណងជើងរូបភាពមនុស្ស ទីកន្លែង រុក្ខជាតិ	
• សរសេរតាមអានពាក្យ និងកន្សោមពាក្យខ្លី។	

ខ្លឹមសម្ព័ន្ធ ១: តារាងពាក្យដែលប្រើញឹកញាប់

- ពាក្យនៅក្នុងបញ្ជីខាងក្រោម គឺជាពាក្យដែលប្រើញឹកញាប់ នៅក្នុងស្តង់ដាកម្មវិធីសិក្សា លទ្ធផលសិក្សា និងខ្លឹមសារខាងលើ ដែលជាជំនួយដល់អ្នកសិក្សាក្នុងការអាន បានយ៉ាងរត់មាត់។
- គ្រូបត្រូវបង្រៀនសិស្សអោយស្គាល់ពាក្យទាំងនេះ ក្នុងបរិបទតាមការអានអត្ថបទនានា នៅក្នុងថ្នាក់រៀន ។
- វិធីនេះ អាចជួយអោយសិស្សចេះពាក្យគន្លឹះជាច្រើន នៅពេលអានអត្ថបទថ្មីៗ ឬអត្ថបទដែលពុំធ្លាប់អាន ពីមុនមក។
- ពាក្យទាំងនេះត្រូវបានជំរុញតាមរយៈសកម្មភាពសិក្សាដទៃទៀត ដើម្បីអោយសិស្សអាចស្គាល់ និងចេះអានពាក្យផ្សេងៗទៀត តាមរយៈបរិបទ ។
- សំរាប់ថ្នាក់ទី១ ពាក្យដែលប្រើញឹកញាប់នៅក្នុងបញ្ជីដូចខាងក្រោមនេះ មាន ៤០ ពាក្យ:

ខ្ញុំ	យើង	វា	ពួកគេ	ឯង	អ្នក	គាត់	នាង	បាទ/ចាស
ម្តាយ	ឪពុក	ថ្ងៃ	ឆ្កែ					
ទៅ	មក	បាន	គឺ	មាន	មើល	គឺជា	ចូលចិត្ត	ឃើញ
លេង	ទទួល	និយាយ						
លើ	នៃ	នេះ	និង	នៅលើ	ឆ្ងាយពី	នៅឯ	សំរាប់	នៅក្នុង
ធំ	តូច	វែង	ខ្លី					
របស់ខ្ញុំ	របស់អ្នក							

លទ្ធផលសិក្សាភាសាខ្មែរ ថ្នាក់ទី២

សមត្ថភាព	លទ្ធផលសិក្សា
ការស្តាប់	• **បញ្ចោញសំលេងអោយបានត្រឹមត្រូវ ពាក្យដែលមានសូរ អ និងសូរ អ៊**
	• **បង្ហាញឥរិយាបថក្នុងការស្តាប់ដោយយកចិត្តទុកដាក់ :** o **ភ្នែកសំលឹងទៅអ្នកនិយាយ** o សួរសំនួរ o ធ្វើតាមការណែនាំងាយៗ ពីរដំណាក់ បីដំណាក់ o **ប្រាប់បានពីពាក្យចូនក្នុងអត្ថបទកាព្យខ្លី ដែលបានស្តាប់** o **ប្រាប់ឡើងវិញពីលំដាប់ព្រឹត្តិការណ៍ តាមសាច់រឿង**
	• សូត្រកំណាព្យ ឬ ច្រៀងចំរៀងខ្លីៗ តាមគ្រូ ឬ អ្នកនាំមុខ (ឧ. តាមសិស្សដទៃជាដើម)
ការនិយាយ	• សួរសំនួរ ដើម្បីទទួលព័តិមានសំខាន់ៗអំពីអ្នកដទៃ
	• ធ្វើការជាក្រុម ដើម្បីសំដែងល្បែងដើរតួងាយៗ : o ណែនាំមនុស្សម្នាក់ អោយស្គាល់មនុស្សម្នាក់ទៀត o ដើរតួក្នុងសាច់រឿងខ្លីៗ
	• ពណិនា និងប្រៀបធៀបបានពីវត្ថុ ទីកន្លែង មនុស្ស សត្វ សកម្មភាព និងរុក្ខជាតិដែលធ្លាប់ស្គាល់
ការអាន	• **ប្រើវិធីងាយៗ ដើម្បីអានពាក្យ** និងល្បះខ្លីៗ **រួមមានពាក្យថ្មីងាយៗ:** o **ប្រើការវិភាគសូរ** ដើម្បីអានពាក្យដែលមានតួអក្សរមិនអាន និង ពាក្យដែលប្លែសូរសំលេង) o **វិភាគបរិបទ** (រូបភាព ពាក្យជុំវិញ) o អានពាក្យពីរព្យាង្គ ដែលធ្លាប់ប្រើញឹកញាប់ បានត្រឹមត្រូវ ដោយមិនបាច់ផ្សំឬប្រកប
	• ផ្គូផ្គងពាក្យមានន័យដូច និង ន័យផ្ទុយ ដែលធ្លាប់ស្គាល់
	• **ពណិនាអត្ថន័យសញ្ញាសុវត្ថិភាពនៅតាមផ្លូវ និងសញ្ញាគ្រោះថ្នាក់**
	• **អាន យល់បាន និងចង្អុលបង្ហាញនូវទាហរណ៍អំពីអត្ថបទផ្សេងៗ បានច្បាស់លាស់ រួមមានរឿងខ្លីៗ** ឈ្មោះរូបភាព ចំណងជើង រូបភាព **ព័តិមាន និងកំណាព្យ**
	• ឆ្លើយនឹងសំណួរ អ្វី អ្នកណា ឯណា ហេតុអ្វី នៅពេលណា ទាក់ទងទៅនឹងអត្ថបទ រឿងងាយៗ
ការសរសេរ	• **សរសេរអក្សរនៃអក្សរក្រម អោយបានស្អាត ត្រឹមត្រូវ**
	• **ជ្រើសរើសពាក្យដែលសមស្របយកមកបំពេញចន្លោះល្បះងាយៗ**
	• សរសេរល្បះងាយៗ ដើម្បីពណិនាអំពីវត្ថុ មនុស្ស និងទីកន្លែង ដែលឃើញក្នុងរូបភាព
	• **សរសេរតាមអានបានត្រឹមត្រូវ ដោយមានល្បឿនសមស្របនូវល្បះងាយៗ រួមមានពាក្យពីរព្យាង្គដែលធ្លាប់ស្គាល់ និងពាក្យថ្មីៗ**
	• ប្រើសញ្ញាសម្ព័ន្ធ ដើម្បីបញ្ចប់ល្បះ បានត្រឹមត្រូវ
	• ប្រើប្រភេទពាក្យសំខាន់ៗ (នាម កិរិយា និងគុណនាម) ដើម្បីសរសេរល្បះងាយៗ ក្នុងសំណេរផ្ទាល់ខ្លួន
ធ្វើការជាក្រុម	• ផ្តល់យោបល់ នៅពេលធ្វើការជាក្រុម

កំណត់សំគាល់: អក្សរខ្មៅដិតច្បាស់នៅក្នុងលទ្ធផលសិក្សាគឺដកចេញមកពីស្តង់ដា ជាចំណុចដែលកំណត់អោយសិស្សត្រូវតែសំរេចអោយបាននៅដំណាច់ឆ្នាំសិក្សាថ្នាក់ទី៣ ។

មេរៀនភាសាខ្មែរថ្នាក់ទី២

មេរៀនទី១ (៥០ម៉) **ទំព័រ.ស**

• ស្គាល់ និងប្រើកាយវិការគោរព ចំពោះគ្រូ និងសិស្សដទៃបាន សមរម្យ តាមកាល:ទេស:	៤,១០
• ណែនាំសិស្សម្នាក់ឱ្យសិស្សម្នាក់ទៀតស្គាល់និងណែនាំសិស្សអោយគ្រូស្គាល់និងបញ្ជោសមកវិញ	
• បង្ហាញឥរិយាបថក្នុងការស្តាប់ដោយយកចិត្តទុកដាក់តាមរយ:ភ្នែកសំលឹងមើលអ្នកនិយាយ	
• ស្តាប់រឿងនិទានខ្លីៗ ដែលគេបានអានឮ: o សួរសំនួរទាក់ទងទៅនឹងអត្ថបទដែលបានស្តាប់	
• សូត្រមេសូត្រ និងច្រៀងចំរៀងខ្លីៗតាមគ្រូ ឬអ្នកនាំមុខ	
• បង្ហាញឈ្មោះវត្ថុ និងមនុស្ស នៅក្នុងឃ្លា ឬល្បះ	
• អានពាក្យងាយៗមួយព្យាង្គ ពីរព្យាង្គ ដែលប្រើញឹកញាប់ ដោយមិនបាច់ផ្សំ ឬប្រកប	៧
• អានពាក្យដែលមានសូរ អ និងសូរអ៊ បានត្រឹមត្រូវ	៧
• បំពេញល្បះ ដើម្បីពណ៌នាវត្ថុ មនុស្ស និងទីកន្លែង ទាំងនៅក្នុងរូបភាព និងក្នុងជីវភាពប្រចាំថ្ងៃ ដោយប្រើពាក្យងាយៗ	២៦,៤០
• សរសេរតាមអានពាក្យដែលធ្លាប់ស្គាល់ និងពាក្យថ្មី	
• ប្រើឥរិយាបថបានត្រឹមត្រូវ ក្នុងការអង្គុយ កាន់បិច ឬខ្ចៅដៃសរសេរ	២០
• ប្រើចលនាម្រាមដៃ ដើម្បីគ្រប់គ្រងការសរសេរ នៅពេលរំកិលដើមដៃលើក្រដាស	
• សរសេរអក្សរផ្ចង់	

មេរៀនទី២ (៥០ម៉) **ទំព័រ ស.ស**

• ប្រើពាក្យបានសមរម្យ ក្នុងការធ្វើសំណូមពរផ្សេងៗ (ឧ.សូមទោស ខ្ញុំសូមទៅបន្ទប់ទឹកបន្តិចបានឬទេ? .....)	
• ឆ្លើយ "បាទ/ ចាស ឬ ទេ" បានត្រឹមត្រូវទៅនឹងសំនួរ (ឧ. តើអ្នកឮខ្ញុំនិយាយឬទេ?)	៥
• ឆ្លើយនឹងសំនួរ "ឯណា" ដោយប្រើធ្នាក់ដែលប្រើញឹកញាប់ (ឧ. ជិតទ្វារ ក្បែរកៅអី)	៥៥
• ហៅឈ្មោះវត្ថុនៅក្នុងថ្នាក់រៀន: o លេងល្បែងពាក្យ (ឧ.អោយសិស្សម្នាក់ជ្រើសរើសវត្ថុមួយ ដូចជា "បង្ហួច" ប៉ុន្តែពុំប្រាប់សិស្សដទៃទៀតអោយដឹងឡើយ សិស្សនោះនិយាយថា វត្ថុដែលខ្ញុំជ្រើសរើសនោះផ្តើមដោយអក្សរ"ប"ហើយអោយសិស្សដទៃទៀតទាយចំលើយ ដោយពិនិត្យមើលជុំវិញបន្ទប់ ដើម្បីសំលឹងរកវត្ថុ ដែលផ្តើមដោយអក្សរនោះ)	
• ប្រើ "ពាក្យ" ដើម្បីបង្ហាញឈ្មោះមនុស្ស សត្វ វត្ថុ និងទីកន្លែង (នាម)	៤៣
• ស្តាប់រឿងខ្លីៗ ដែលគេអានឮ: o បង្ហាញ និងពណ៌នាអំពីតួអង្គសំខាន់ៗ	

o សូរសំនួរទាក់ទងទៅនឹងអត្ថបទដែលបានស្តាប់	
• សូត្រកំណាព្យ និងច្រៀងចំរៀងខ្លីៗតាមគ្រូ ឬអ្នកនាំមុខ: o ប្រាប់ពាក្យចូនក្នុងកំណាព្យ ឬចំរៀង	
• អានពាក្យពីរព្យាង្ត ដែលប្រើញឹកញាប់(នៅដាច់តែឯង និងនៅក្នុងបរិបទ)	៦៣.៦៥
• អានពាក្យដែលស្គាល់ ដោយពុំចាំបាច់ប្រកប ឬផ្សំ	៧
• បង្ហាញពាក្យនីមួយៗ នៅក្នុងពាក្យផ្សំងាយៗ	៤៦
• ផ្គូផ្គងពាក្យចូនមួយចំនួន	១៤
• ធ្វើអក្ខរវិញ្ញាសពាក្យដែលប្រើញឹកញាប់ បានត្រឹមត្រូវ	៨
• សរសេរអក្សរផ្ទង់បានស្អាត ត្រឹមត្រូវ	
• សរសេរតាមអានល្បះងាយៗ	

មេរៀនទី៣ (៥០ម៉) **ទំព័រ.ស.ស**

• ធ្វើតាមការណែនាំពីរ ឬបីដំណាក់ (ឧ. កាន់ដៃគ្នា និងធ្វើជារង្វង់)	
• ប្រើសព្វនាមកម្មសិទ្ធិ (ឧ. របស់យើង/របស់គេ)	៤៩
• ពិភាក្សាគ្នាខ្លីអំពីសកម្មភាពដែលខ្លួនចូលចិត្តបំផុតនៅសាលារៀន	
• និយាយទៅកាន់មិត្តរួមថ្នាក់ ឬ គ្រូ ដោយសំលឹងមើលទៅអ្នកដែលស្តាប់	
• ស្តាប់ រឿងនិទានខ្លីៗ ដែលគេអានព្ម: o បង្ហាញនិងពណិនាខ្លី ៗ ពីព្រឹត្តិការណ៍ និងតួអង្គនៅក្នុងរឿង o សំដែងល្បែងដើរតួខ្លីៗតាមដំណើររឿង	
• ប្រើរូបភាពដើម្បីអានពាក្យ និងល្បះខ្លីៗ	
• សូត្រមេសូត្រ និងច្រៀងចំរៀងខ្លីៗតាមគ្រូ រឺអ្នកនាំមុខ o ប្រាប់ពាក្យចូនក្នុងកំណាព្យ ឬចំរៀង	៣២
• សរសេរល្បះងាយៗតាមគំនិតផ្ទាល់ខ្លួន ឆ្លើយតបទៅនឹងសំនួរ ឬ រូបភាព	
• សរសេរតាមអានល្បះងាយៗ	

មេរៀនទី ៤ (៥០ម៉) **ទំព័រស.ស**

• ផ្តល់ការណែនាំច្បាស់លាស់: o លេងល្បែង ដើម្បីហាត់ផ្តល់ការណែនាំ (ឧ. សិស្សម្នាក់ចងកន្សែងបិទមុខ ហើយសិស្សម្នាក់ទៀតដើរនៅក្បែរ ឬដើរពីក្រោយ ដើម្បីជួយប្រាប់សិស្សដែលបិទមុខនោះ ដើរកុំអោយប៉ះវត្ថុផ្សេងៗ ជុំវិញថ្នាក់រៀន	
• ប្រើ "ពាក្យ" ដើម្បីបង្ហាញសកម្មភាពផ្សេងៗ (កិរិយា)	៧៧
• ប្រើការលើកដាក់សំលេងបានត្រឹមត្រូវនៅក្នុងឃ្លា និងល្បះនៅពេលពណិនា	៧០

• សូត្រមេសូត្រ និងច្រៀងចំរៀង តាមបែបបទត្រឹមត្រូវ	១៣
• ផ្គូផ្គងរូបភាព នឹងចំណងជើងរូបភាព (ឧ. សិស្សគូររូបភាពនៃវត្ថុងាយៗ ដូចជាផ្ទះ រថយន្ត ដើមឈើ និងសរសេរចំណងជើងរូបភាពសំរាប់ផ្គូផ្គង ច្របល់រូបភាព ហើយប្តូរជាមួយនឹងសិស្សម្នាក់ទៀត សិស្សនីមួយៗត្រូវផ្គូចំណងជើងរូបភាពជាមួយនឹងរូបភាព)	
• ស្តាប់រឿងដែលគេអានញ: o ប៉ាន់ស្មានហេតុការណ៍ដែលនឹងអាចកើតឡើង នៅក្នុងរឿង	
• អានល្បះងាយៗ និងអានឡើងវិញ ប្រសិនបើចាំបាច់	៣៨,៨៥
• អានពាក្យដែលមានតួអក្សរមិនអាន	៥៧
• ចាប់ផ្តើមតែងល្បះងាយៗ	១៤៦
• ផ្គូផ្គងពាក្យន័យដូចមួយចំនួន	១៣៧

មេរៀនទី៥ (៥០ម៉) **ទំព័រស.ស**

• ប្រើពាក្យខ្លីៗដើម្បីរៀបរាប់អំពីសូរ ក្លិន រសជាតិ និងការប៉ះពាល់	
• ប្រើសេចក្តីណែនាំច្បាស់លាស់ ដើម្បីពន្យល់ដល់សិស្សដទៃទៀតអំពីរបៀបលេងល្បែងផ្សេងៗ	
• ស្តាប់រឿងដែលគេអានញ: o ប្រាប់ឡើងវិញពីសេចក្តីពណិនាអំពីមនុស្ស និងទីកន្លែងនៅក្នុងរឿងបានសមស្រប	
• ប្រើ "ពាក្យ" ដើម្បីបង្ហាញលក្ខណៈរបស់វត្ថុ សត្ត មនុស្ស (គុណនាម)	
• អានសំណេរផ្ទាល់ខ្លួនញ្ញ	
• បកស្រាយន័យនៃរូបភាព និងសញ្ញាងាយៗមួយចំនួន (សញ្ញា [√] [X] ☺😐☹)	
• សរសេរល្បះពីរ ឬបី នៅក្រោមប្រធានបទមួយ ដោយមានរូបភាពជាជំនួយ	១៥២
• ប្រើសញ្ញាសម្ព័ន្ធ ដើម្បីបញ្ចប់ល្បះ (សញ្ញាសូរ សញ្ញាឧទាន សញ្ញាខណ្ឌ)	
• រៀបល្បះងាយៗដែលដាក់ចំរុះគ្នា ដើម្បីឱ្យមានន័យត្រឹមត្រូវតាមលំដាប់	
• អានល្បះ និងជ្រើសរើសពាក្យសមស្រប ដើម្បីបំពេញក្នុងចន្លោះ ដោយប្រើរូបភាពជំនួយ	២៤
• ផ្គូផ្គងពាក្យន័យផ្ទុយមួយចំនួន	១៣៧
• សរសេរតាមអាន ពាក្យនិងល្បះ បានត្រឹមត្រូវ	

មេរៀនទី៦ (៥០ម៉) **ទំព័រស.ស**

• លេងល្បែងពាក្យជាក្រុម ដើម្បីបន្ថែមគុណនាមបញ្ជាក់ន័យអោយនាម (ឧ.អោយពាក្យមួយ ដល់ក្រុមសិស្សនីមួយៗដូចជា ពាក្យ **ថ្ម** ជាដើម ហើយក្រុមសិស្សនីមួយៗនោះត្រូវបន្ថែមគុណនាមមួយ ដូចជា **ធំ រឹង ត្រើម មុត ស្រួច** នៅបន្ទាប់ពាក្យនោះ)	
• ស្តាប់រឿងដែលគេអានញ: o ប្រៀបធៀបហេតុការណ៍នៅក្នុងរឿង និងហេតុការណ៍ជាក់ស្តែងដែលខ្លួនបានជួបប្រទះ	

o ពិភាក្សារកដំណោះស្រាយបញ្ហាដែលបង្ហាញនៅក្នុងរឿង(ឧ.ប្រសិនបើខ្ញុំមានរឿង បែបហ្នឹង ខ្ញុំនឹង...)	
• ស្ងប្រកែលំអ នៅពេលអានដើម្បីយល់អត្ថន័យ	
• អានពាក្យដែលមាន: o តួអក្សរមិនអាន o តួអក្សរប្តូរសូរសំលេង	
• យល់បានព័ត៌មានក្នុងផ្ទាំងក្រដាសធំ ផ្លាកសញ្ញា និងរូបភាព	
• ជ្រើសរើសពាក្យសមស្រប ដើម្បីបំពេញពាក្យដែលបាត់ នៅក្នុងល្បះ	២៤

មេរៀនទី៧ (៥០ម៉) ទំព័រស.ស

• ស្តាប់ការនិយាយរបស់នរណាម្នាក់(ឧ.ឱពុកម្តាយ សមាជិកសហគមន៍ នគរបាល ឬបុគ្គលិកសុខាភិបាល) ដើម្បីផ្តល់ព័ត៌មានអំពីប្រធានបទ ឬព្រឹត្តិការណ៍អ្វីមួយ	
• សួរសំនួរដែលទាក់ទងទៅនឹងប្រធានបទ	
• ស្តាប់រឿងដែលគេអានញ: o បង្ហាញពាក្យបញ្ជាក់អំពីសកម្មភាពដែលកើតឡើង (នៅកន្លែងណាមួយ នៅពេលណា ហេតុអ្វី និង យ៉ាងដូចម្តេច)	
• ប្រកបពាក្យពុ្ទ ដោយប្រើឈ្មោះអក្សរ	៥
• ផ្គូផ្គងពាក្យន័យដូច និងន័យផ្ទុយ	៥៧
• ប្រើនាមនៅក្នុងការសរសេរល្បះងាយ៦	
• សរសេរតាមអានពាក្យ និងល្បះបានត្រឹមត្រូវ	

មេរៀនទី៨ (៤៨ម៉) ទំព័រស.ស

• ចាប់ផ្តើមប្រើបទានុក្រម	
• ស្តាប់រឿងដែលគេអានញ: o ពណិនាពីសកម្មភាព និងអារម្មណ៍របស់តួអង្គមួយចំនួន ដោយប្រើពាក្យផ្ទាល់ខ្លួន	
• អានពាក្យមួយចំនួនដែលពុំធ្លាប់ស្គាល់ ដោយវិភាគពាក្យនៅជុំវិញ	
• សរសេរសេចក្តីពណិនាខ្លី៦ ដោយប្រើពាក្យជាគុណនាមដើម្បីបន្ថែមន័យទៅលើនាម	
• ប្រើកិរិយាផ្សេង៦ នៅក្នុងសំណេរផ្ទាល់ខ្លួន	
• តែងល្បះងាយ៦ដែលបំរើគោលបំណងផ្សេង៦(ឧ.ពណិនាអំពីវត្ថុប្រាប់ពីអ្វីដែលកើតឡើង)	
• ចង្អុលបង្ហាញឧទាហរណ៍អំពីអត្ថបទផ្សេង៦រួមមានរឿងនិទានខ្លី៦ចំណងជើងរូបភាពឬកំណាព្យ	
• សរសេរតាមអាន	

មេរៀនទី៩ (៤៨ម៉ោ) **ទំព័រសៀវភៅ**

• ប្រៀបធៀបទីកន្លែង វត្ថុ ឬមនុស្សដែលធ្លាប់ស្គាល់បានត្រឹមត្រូវ	
• សូត្រមេសូត្រឮៗ ទៅតាមបែបបទ និងមនោសញ្ចេតនា	៥៨
• អាន និងស្តាប់រឿង ដែលគេអានឮ: o ពណ៌នាអំពីតួអង្គណាមួយក្នុងរឿង ដោយពុំចាំបាច់ប្រាប់ឈ្មោះតួអង្គនោះ ហើយអោយសិស្សឯទៀត ទាយឈ្មោះតួអង្គនោះ	
• សរសេរល្បះងាយៗដែលបំរើអោយគោលបំណងផ្សេងៗ (ឧ.ពណ៌នាអំពីសកម្មភាព ប្រាប់អំពីអ្វីដែលកើតឡើង)	៧៤
• អានសំណេរផ្ទាល់ខ្លួនឮ និងធ្វើការកែលំអ	
• ជ្រើសរើសពាក្យត្រឹមត្រូវ ដើម្បីបំពេញល្បះ	៩៩
• ប្រើគុណនាមផ្សេងៗនៅក្នុងសំណេរផ្ទាល់ខ្លួន	
• សរសេរតាមអាន	

មេរៀនទី១០ (៤៨ម៉ោ) **ទំព័រសៀវភៅ**

• ពណ៌នាអំពីសកម្មភាពដែលធ្លាប់ស្គាល់ ឬធ្លាប់ធ្វើ	
• សូត្រមេសូត្រឬច្រៀងចំរៀងជាក្រុម	
• អាន និងស្តាប់រឿងដែលគេអានឮ: o ធ្វើសេចក្តីសន្និដ្ឋានអំពីអារម្មណ៍រីករាយរបស់តួអង្គ o វិភាគបរិបទដើម្បីយល់ន័យនៃពាក្យដែលពុំធ្លាប់ស្គាល់	
• អាន និងប្រាប់ឡើងវិញអំពីព័ត៌មាននៅក្នុងសេចក្តីប្រកាស ដោយប្រើពាក្យផ្ទាល់ខ្លួន	
• សរសេរល្បះងាយៗពីរឬបី ដើម្បីបំរើអោយគោលបំណងផ្សេងៗ (ពណ៌នាពីមនុស្ស សត្វ និងទីកន្លែង ដែលកើតឡើង)	
• សរសេរតាមអាន	

លទ្ធផលសិក្សាភាសាខ្មែរ ថ្នាក់ទី៣

សមត្ថភាព	**លទ្ធផលសិក្សា**
ការស្តាប់	• **បង្ហាញឥរិយាបថក្នុងការស្តាប់ដោយយកចិត្តទុកដាក់ :** o **សួរសំនួរដែលទាក់ទង** o ធ្វើតាមការណែនាំងាយៗ បីដំណាក់ បួនដំណាក់ o **និទានរឿងខ្លីៗ ឡើងវិញ បានច្បាស់ត្រឹមត្រូវ** o ឆ្លើយនឹងសំនួរនៅក្នុងរឿងនិទានខ្លីៗ បន្ទាប់ពីស្តាប់ ដើម្បីបង្កើនការយល់ដឹង
	• **សូត្រកំណាព្យខ្លី ឬ ចំរៀងខ្លីៗ តាមបែបបទបានត្រឹមត្រូវ ទៅអ្នកស្តាប់ដែលធ្លាប់ស្គាល់ (ក្នុងថ្នាក់ សាលារៀន គ្រួសារ)**
ការនិយាយ	• **រៀបចំ និងអនុវត្តកិច្ចការទាំងឡាយ ដើម្បីរបមូលព័ត៌មានសំខាន់ៗ (ឧ. ធ្វើការអង្កេត រួចផ្តល់ព័ត៌មានពីសមាជិកគ្រួសារ និង មិត្តភក្តិ)**
	• **ធ្វើការជាក្រុមដើម្បីហ្វឹកហាត់ និងសំដែងល្បែងដើរតួខ្លីៗ ដែលបំរើអោយគោលបំណងមួយចំនួន ឧ.** o **បង្ហាញពីការប្រើប្រាស់ពាក្យសំដី និងអាកប្បកិរិយាសមរម្យនៅក្នុងគ្រួសារ សាលារៀន និង សង្គម** o **សំដែងរឿងមួយ**
	• **ប្រើប្រាស់ពត៌មានអំពីប្រធានបទដែលធ្លាប់ស្គាល់តាមរយៈការបង្ហាញ (ឧទ្ទេស) ការនិយាយខ្លីៗ បានច្បាស់លាស់ ដោយប្រើ សំដី(សំលេង និងល្បឿន) បានសមរម្យ**
ការអាន	• អាន និងយល់កថាខណ្ឌងាយៗ បានច្បាស់លាស់
	• រកពាក្យន័យដូច និងន័យផ្ទុយ
	• **ពន្យល់បានត្រឹមត្រូវពីអត្ថន័យរបស់សញ្ញាសាមញ្ញាមួយចំនួនរួមមាន សញ្ញាសុវត្ថិភាពតាមផ្លូវសាធារណៈ និងសញ្ញាគ្រោះថ្នាក់**
	• **អាន យល់បាន និងចង្អុលបង្ហាញឧទាហរណ៍ងាយៗនៃប្រភេទអត្ថបទផ្សេងៗដូចជារឿងរឿង។ រូបគំនូរមានចំណងជើង ព័ត៌មានក្នុងកំណត់សំគាល់នានា និង កំណាព្យ**
	• **ប៉ាន់ស្មានការវិវត្តរបស់ដំណើររឿង និងប្រាប់បានពីសេចក្តីលំអិតសំខាន់ៗនៃអត្ថបទងាយៗ ដោយឆ្លើយនឹងសំនួរ អ្វី អ្នកណា ឯណា ពេលណា ហេតុអ្វី និងយ៉ាងដូចម្តេច** នៅក្នុងព័ត៌មានបង្ហាញត្រង់
ការសរសេរ	• **សរសេរអក្សរនៃអក្ខរក្រម ដោយប្រើគំរូត្រឹមត្រូវ តាមទំរង់អក្សរផ្គង់**
	• **សរសេរតាមអានបានត្រឹមត្រូវ (ដោយមានល្បឿនសមស្រប)នូវអត្ថបទខ្លីៗ រួមមានពាក្យពីរព្យាង្គដែលធ្លាប់ស្គាល់ និងពាក្យថ្មីៗ**
	• **រៀបចំការសរសេរនិងសរសេរកថាខណ្ឌងាយៗយ៉ាងតិចបីល្អះ អំពីមនុស្ស ទីកន្លែង និងព្រឹត្តិការណ៍ដែលធ្លាប់ស្គាល់ដើម្បីបំរើគោលបំណងផ្សេងៗ**
	• **ពិភាក្សានិងសរសេរ(ជាក្រុម)ការបញ្ចាប់សាច់រឿងតាមបែបផ្សេងៗដើម្បីបំពេញក្នុងរឿងនិទានខ្លី**
	• **ប្រើសញ្ញាខណ្ឌ ដកឃ្លា ចុះបន្ទាត់ សញ្ញាសួរ សញ្ញា អ (មូសិកទន្ត) សញ្ញា អ៊ី (ត្រីសព្ទ) និងសញ្ញាបន្តក់បានត្រឹមត្រូវ**
	• **ចង្អុលបង្ហាញ និងប្រើប្រាស់បានត្រឹមត្រូវ ក្នុងសំណេរផ្ទាល់ខ្លួន នូវប្រភេទពាក្យសំខាន់ៗ រួមមាន នាម គុណនាម កិរិយា** និង សព្វនាម
ធ្វើការជាក្រុម	• **ស្តាប់អ្នកដទៃនិយាយ ដោយយកចិត្តទុកដាក់ និងចូលរួមបញ្ចេញយោបល់បានសមរម្យ**

កំណត់សំគាល់: អក្សរខ្មៅដិតច្បាស់នៅក្នុងលទ្ធផលសិក្សាគឺដកចេញមកពីស្តង់ដា ជាចំណុចដែលកំណត់អោយសិស្សត្រូវតែសំរេច អោយបាននៅដំណាច់ឆ្នាំសិក្សាថ្នាក់ទី៣ ។

មេរៀនភាសាខ្មែរថ្នាក់ទី៣

មេរៀនទី ១ (៦០ម៉ោ) **ទំព័រសៀវភៅ**

• ស្គាល់ និងប្រើប្រាស់កាយវិការ និងភាសា ក្នុងការគោរព តាមស្ថានភាពនានាទាំងនៅក្នុងសាលា និងក្រៅសាលា	៧៨
• អនុវត្តកិច្ចការងាយៗ ដើម្បីឆ្លើយតបទៅនឹងការណែនាំ និងសំណូមពរ	៣២
• បង្ហាញ ហៅឈ្មោះ និងពណ៌នាអំពីវត្ថុនានា	១០,១១
• ស្តាប់រឿងដែលគេអានឮ: o ឆ្លើយនឹងសំនួរងាយៗ ដើម្បីពង្រីកការយល់ដឹង	៨៦
• អានស្ងាត់ និងអានឮរឿងខ្លីៗ: o ប្រាប់បានពីសេចក្តីលំអិតសំខាន់ៗ	៥៤-៥៥
• ព្យែកពាក្យដែលមានសូរសំលេងស្រដៀងគ្នា	
• បង្កើនការយល់ដឹងបន្ថែមនូវពាក្យដែលធ្លាប់ប្រើញឹកញាប់	១៤៤
• សរសេរតាមអានល្បះមួយចំនួន	
• តែងល្បះងាយៗតាមរូបភាព	
• ប្រើសញ្ញាខណ្ឌក្នុងសំណេរផ្ទាល់ខ្លួនបានត្រឹមត្រូវ	

មេរៀនទី២(៥០ម៉ោ)

សួរ និងឆ្លើយសំនួរទាក់ទងនឹងសុខភាព អាកាសធាតុ សកម្មភាពប្រចាំថ្ងៃ	៤,៥,២៦,
• បង្ហាញការសំរួលភាសានិយាយ ទៅតាមបរិបទតាមរយៈល្បែងដើរតួ (ឧ. ប្រៀបធៀបការនិយាយទៅកាន់អ្នកលក់ (ទិញ្ញរបស់) និងការនិយាយធម្មតាទៅកាន់បង ប្អូនស្រី)	
• ស្តាប់រឿងដែលគេអានឮ: o ឆ្លើយនឹងសំនួរ “ហេតុអ្វី” និង “ដូចម្តេច”	៧៨,៨៦,១៤៩ ,១៥៧
• អានស្ងាត់ និងអានឮរឿងខ្លីៗ: o ប្រាប់បានពីសេចក្តីលំអិតសំខាន់ៗ	៧៧,៨៥,១៤៩, ១៥៧
• ប្រាប់និយមន័យនៃ “នាម” បានត្រឹមត្រូវ	
• អានចំណងជើងរូបភាព	
• សរសេរល្បះងាយៗ ដោយខ្លួនឯង ដោយប្រើនាមបានត្រឹមត្រូវ	២៧,៣៥,
• សរសេរតាមអានអត្ថបទខ្លីៗ បានត្រឹមត្រូវ	

មេរៀនទី៣ (៥២ម៉ោ) **ទំព័រស.ស**

• ធ្វើតាមការណែនាំបី ឬ បួនដំណាក់	
• ប្រើការលើកដាក់សំលេងនៅក្នុងឃ្លា និងល្បះ	
• សូត្រកំណាព្យ និងច្រៀងចំរៀង ដោយមានការប្រើអារម្មណ៏ និងទឹកមុខ	៧០,៧១,៨៦
• ស្តាប់រឿងដែលគេអានឮ: o ឆ្លើយនឹងសំនួរ ហេតុអ្វី និងដូចម្តេច o និទានរឿងឡើងវិញ តាមលំដាប់នៃព្រឹត្តិការណ៏សំខាន់ៗ	៧៧,៨៥, ១៥៧
• អានស្ងាត់ និងអានឮរឿងខ្លីៗ: o ប្រាប់បានពីសេចក្តីលំអិតសំខាន់ៗ	៧៩,១៤៩ ១៥៩
• ប្រាប់និយមន័យនៃគុណនាមបានត្រឹមត្រូវ	
• សរសេរល្បះងាយៗ ដោយប្រើនាម គុណនាម បានត្រឹមត្រូវ	២៧,២៨,៣៥
• សរសេរតាមអានអត្ថបទខ្លីៗបានត្រឹមត្រូវ	

មេរៀនទី៤ (៥២ម៉ោ) **ទំព័រសស**

• ថាឡើងវិញ និងរៀបសេចក្តីណែនាំឡើងវិញ ដើម្បីបង្កើនភាពច្បាស់លាស់	
• ស្តាប់កំណាព្យដែលគេអានឮ: o ស្តាល់ និងផ្គូផ្គងពាក្យចួន o អោយឧទាហរណ៏អំពីពាក្យន័យដូច និងន័យផ្ទុយ	
• អានកំណាព្យស្ងាត់ៗ និងអានឮ o សូត្រកំណាព្យ ដោយខ្លួនឯង និងជាក្រុម ឬជាដៃគូ	៧០,៧១,៨៦ ៨៧
• ប្រាប់និយមន័យនៃកិរិយាបានត្រឹមត្រូវ	
• សរសេរតាមអានអត្ថបទខ្លី បានល្បឿន	
• សរសេរល្បះងាយៗ ដោយប្រើនាម កិរិយា និងគុណនាមបានត្រឹមត្រូវ	៣៥,៣៦, ៦៤,១២៣

មេរៀនទី៥ (៥០ម៉ោ) **ទំព័រស.ស**

• ផ្តល់ការណែនាំច្បាស់លាស់ អំពីរបៀបធ្វើកិច្ចការ ឬធ្វើដំណើរទៅកន្លែងណាមួយ	
• អានល្បះៗ ដោយល្បឿនសមស្រប	
• ស្តាប់អត្ថបទព័ត៌មានខ្លីៗ ដែលគេអានឮ: o សួរសំនួរដែលទាក់ទង o បង្ហាញប្រធានបទនៃអត្ថបទព័ត៌មាន	
• អាន និងធ្វើតាមការណែនាំងាយៗ ដើម្បីសំរេចកិច្ចការអ្វីមួយ (ឧ. ការបត់ក្រដាស)	៣៩
• រៀបសេចក្តីណែនាំដែលគេបានច្របល់បញ្ចូលគ្នា អោយមានលំដាប់ត្រឹមត្រូវវិញ	៣៩
• រៀបចំ និងតែងកថាខណ្ឌងាយៗ អំពីប្រធានបទមួយ អោយបានយ៉ាងតិច ចំនួន៣ល្បះ	៧២
• រៀបលំដាប់នាម និងគុណនាមបានត្រឹមត្រូវ	២៧,៤៣
• សរសេរតាមអានអត្ថបទ	

មេរៀនទី៦ (៤៨ម៉ោ) **ទំព័រស.ស**

• ស្តាប់អត្ថបទព័ត៌មានខ្លីៗ ដែលគេអានឮ: o បង្ហាញប្រធានបទសំខាន់ និងចំណុចពិស្តារមួយចំនួននៃអត្ថបទព័ត៌មានថ្មីៗ	១០១
• ប្រើវិធីផ្សេងៗ រួមទាំងការវិភាគបរិបទ ដើម្បីសន្និដ្ឋានន័យនៃពាក្យដែលមិនធ្លាប់ស្គាល់	១០១
• អាន បកស្រាយសេចក្តីប្រកាសព័ត៌មានងាយៗ: o ប្រាប់ឡើងវិញនូវព័ត៌មាន ដោយប្រើពាក្យផ្ទាល់ខ្លួន	
• ប្រើសញ្ញាសួរបានត្រឹមត្រូវនៅក្នុងសំណេរផ្ទាល់ខ្លួន	១១,១២
• រៀបចំ និងតែងកថាខណ្ឌងាយៗ ទាក់ទងទៅនឹងប្រធានបទដែលធ្លាប់ស្គាល់អោយបានយ៉ាងតិច ៣ល្បះ	៥៦
• សរសេរអក្សរផ្ចង់បានស្អាត និងត្រឹមត្រូវ	
• សរសេរតាមអានអត្ថបទ	

មេរៀនទី៧ (៤៦ម៉ោ) **ទំព័រស.ស**

• រៀបចំ និងអនុវត្តកិច្ចការប្រមូលព័ត៌មាន ដោយសួរសំនួរ និងស្តាប់ចំលើយ (ឧ. ធ្វើការអង្កេតពីសមាជិកគ្រួសារខ្លួន ឬមិត្តភក្តិអំពីចំណីអាហារដែលពួកគេចូលចិត្ត ឬចំនួនបងប្អូន ប្រុសស្រី...)	
• ស្តាប់រឿងដែលគេអានឮ: o រៀបចំល្បែងដើរតួជាក្រុម តាមផ្នែកនៃរឿង	៥៣
• អាន និងបកស្រាយព័ត៌មានក្នុងកំណត់សំគាល់នានា	
• ចង្អុលបង្ហាញ និងប្រើប្រាស់សញ្ញា អ បានត្រឹមត្រូវ	

• សរសេរកថាខណ្ឌខ្លីមួយ តាមបែបនិទានអំពីព្រឹត្តិការណ៍មួយ	៩៦
• បង្ហាញ និងប្រើប្រាស់ថ្នាក់ពាក្យសំខាន់ៗបានត្រឹមត្រូវនៅក្នុងសំណេររបស់ខ្លួន(នាម កិរិយា និង គុណនាម)	២៧.២៨.៣៥ ១៣៩
• សរសេរតាមអានអត្ថបទ	

មេរៀនទី៨ (៤៦ម៉ោ) **ធំពាំរស.ស**

• ឡើងបង្ហាញព័ត៌មានខ្លីៗទាក់ទងទៅនឹងប្រធានបទធ្លាប់ស្គាល់តាមគំរោងគំនិតដែលរៀបចំ	
• ស្តាប់ និងអានអត្ថបទព័ត៌មានខ្លីៗ: o សង្ខេប និងប្រាប់ឡើងវិញនូវព័ត៌មានសំខាន់ ដោយប្រើពាក្យផ្ទាល់ខ្លួន o បង្ហាញហេតុ និងផល o បង្ហាញ និងអោយឧទាហរណ៍អំពីពាក្យន័យដូច និងពាក្យន័យផ្ទុយ	១៤០,១៤១
• ប្រើពាក្យភ្ជាប់ដើម្បីបញ្ជាក់ពីទំនាក់ទំនងហេតុនិងផលដូចជា"ពីព្រោះ"និង"ដូច្នេះហើយ" ក្នុងសំដីផ្ទាល់មាត់	១៤០,១៤១
• ចង្អុលបង្ហាញ និងប្រើប្រាស់សញ្ញា អ៊ិ (ត្រីសព្ទ) បានត្រឹមត្រូវ	
• សរសេរកថាខណ្ឌមួយបានច្បាស់លាស់ ត្រឹមត្រូវ បន្ទាប់ពីបានត្រៀមលក្ខណៈរួច: o សរសេរបង្កើនចំនួនពាក្យ ដោយពុំមានកំហុសអក្ខរាវិរុទ្ធ o អនុវត្តវិធីស្វ័យកែលំអនៅក្នុងការពិនិត្យកែសំរួលសំណេរផ្ទាល់ខ្លួន (ពាក្យដែលមិនត្រឹមត្រូវ) o ប្រើសញ្ញាសម្ព័ន្ធនៅក្នុងសំណេរផ្ទាល់ខ្លួន	៦៤ ១១,១២
• សរសេរបញ្ជីមួយ (ឧ. បញ្ជីទិញអីវ៉ាន់)	
• សរសេរតាមអានអត្ថបទ	

មេរៀនទី៩ (៤៦ម៉ោ) **ធំពាំរស.ស**

• ពន្យល់ពីអត្ថន័យរបស់សញ្ញាសុវត្ថិភាព តាមផ្លូវសាធារណៈ	
• បង្ហាញ និងអោយឧទាហរណ៍ពីពាក្យន័យដូច និងពាក្យន័យផ្ទុយ	៦៨,៦៩
• ស្តាប់រឿងនិទានវែង ដែលគេអានឮ: o ឆ្លើយនឹងសំនួរ o រៀបព្រឹត្តិការណ៍តាមលំដាប់	៥៤,៥៥
• អានកំណាព្យខ្លីៗ : o ប្រាប់ពាក្យជួន o ឆ្លើយនឹងសំណួរ	
• ពិភាក្សា និងសរសេរសេចក្តីបញ្ចប់ផ្សេងៗ សំរាប់រឿងដែលចប់ និងរឿងមិនទាន់ចប់	
• សរសេរតាមអានអត្ថបទខ្លីៗ	១២០

មេរៀនទី ១០ (៤៤ម៉ោ) **ទំព័រស.ស**

• ពន្យល់អត្ថន័យនៃព័ត៌មានក្នុងរូបគំនូរមានចំណងជើងបានត្រឹមត្រូវ	
• ស្តាប់ និងអានរឿង៖ o ឆ្លើយនឹងសំនួរ អ្វី នរណា ឯណា ហេតុអ្វី ពេលណា យ៉ាងដូចម្តេច o រៀបព្រឹត្តិការណ៍តាមលំដាប់ o និទានរឿងឡើងវិញ	១៤៤
• ចង្អុលបង្ហាញ និងប្រើប្រាស់សញ្ញា បន្តក់ បានត្រឹមត្រូវ	
• សរសេរកថាខណ្ឌមួយ បានច្បាស់លាស់ ដោយល្បឿនសមស្រប បន្ទាប់ពីបានត្រៀមលក្ខណៈជាស្រេច o សរសេរបង្កើនចំនួនពាក្យ ដោយពុំមានកំហុសអក្ខរាវិរុទ្ធ o អនុវត្តស្វ័យកែលំអនៅក្នុងការពិនិត្យ កែសំរួលសំណេរផ្ទាល់ខ្លួន (ពាក្យដែលអានមិន ដាច់ ឬពុំត្រឹមត្រូវ) o ប្រើសញ្ញាបន្តក់នៅក្នុងសំណេរផ្ទាល់ខ្លួន	
• សរសេរតាមអត្ថបទ	

ឧបសម្ព័ន្ធ២: ពាក្យដែលប្រើញឹកញាប់

- ពាក្យនៅក្នុងបញ្ជីខាងក្រោម គឺពាក្យសំខាន់ៗដែលប្រើញឹកញាប់ នៅក្នុងស្តង់ដាកម្មវិធីសិក្សា លទ្ធផល សិក្សា និងខ្លឹមសារ ខាងលើ ដែលជាជំនួយដល់អ្នកសិក្សាក្នុងការអានបានយ៉ាងរត់មាត់។
- គ្រូត្រូវបង្រៀនសិស្សអោយស្គាល់ពាក្យទាំងនេះនៅក្នុងបរិបទនៅពេលអានរឿងនានានៅក្នុងថ្នាក់រៀន។
- វិធីនេះ អាចជួយអោយសិស្សចេះពាក្យគន្លឹះជាច្រើន នៅពេលអានអត្ថបទថ្មីៗ ឬអត្ថបទដែលពុំធ្លាប់អានពី មុនមក ។
- ពាក្យទាំងនេះត្រូវបានជំរុញតាមរយៈសកម្មភាពសិក្សាដទៃទៀត ដើម្បីអោយសិស្សអាចស្គាល់ និងចេះអាន ពាក្យផ្សេងៗទៀត តាមបរិបទបញ្ជាក់។
- នៅក្នុងថ្នាក់ទីពានេះមានពាក្យមួយចំនួនដែលប្រើញឹកញាប់នៅក្នុងថ្នាក់ ទី១ (ខ្លឹមសារថ្នាក់ទី១)ដែលត្រូវបាន បញ្ចូលក្នុងនេះ ដូចខាងក្រោម:

ឈ្មោះ	ដើមឈើ	មនុស្ស	ទ្វារ	យប់	បាល់	ទឹក	ទីនោះ	ត្រែ	បុរស
ក្មេងប្រុស	ក្មេងស្រី	ផ្ទះ	សាលា	ពេលណា	កន្លែងណា	បងប្អូនប្រុស	បងប្អូនស្រី	ពេល	ចុងក្រោយ
របស់យើង	ហេតុអ្វី	ខ្លះ	យើង	របស់គេ	ពួកគេ	គាត់	នរណា	អ្វី	
ល្អ	ថ្មី	ពីរ	ចាស់	មួយ	បី	បន្ទាប់	កន្លះ	នោះ	បន្តិចបន្តួច
ដំបូង	ជាច្រើន	ច្រើនជាង							
មក	ចេញ	ជីក	មាន	ចូលចិត្ត	ជួយ	រុញ	ចង់បាន	ចុះ	ស្រលាញ់
ទាញ	រត់	ឃើញ	ទៅ	ត្រូវតែ	យក	ធ្វើ			
ប៉ុន្តែ	ប្រសិនបើ		ម្តងទៀត	ជាមួយ	មួយទៀត	ក្រោយ	មិនមែន	ពីព្រោះ	ឥឡូវ

លទ្ធផលសិក្សាភាសាខ្មែរ ថ្នាក់ទី៤

សមត្ថភាព	លទ្ធផលសិក្សា
ការស្តាប់	• បង្ហាញឥរិយាបថក្នុងការស្តាប់ដោយយកចិត្តទុកដាក់នៅពេលចូលរួមសកម្មភាព ជាដៃគូ ក្រុមនិងក្នុងថ្នាក់
	• ស្តាប់និងថាឡើងវិញនូវចំណុចសំខាន់ៗនៃអត្ថបទ(អត្ថបទដែលគេអានឮនិងការធ្វើបទបង្ហាញ របស់អ្នកដទៃ)
	• ធ្វើតាមការណែនាំច្រើនជំហាន ដើម្បីធ្វើកិច្ចការមួយ
ការនិយាយ	• ប្រើភាសានិយាយ ដោយមានភាពច្បាស់លាស់ ត្រឹមត្រូវ ហើយពិស្តារ សំរាប់បំរើអោយគោលបំណង ផ្សេងៗ ដូចជា: o ប្រាប់ទិសទៅរកកន្លែងណាមួយ o ពណ៌នាអំពីមនុស្ស ទីកន្លែង និងវត្ថុ o បង្ហាញពីការមិនចូលចិត្ត និងការចូលចិត្ត o ផ្តល់ការណែនាំតាមលំដាប់លំដោយត្រឹមត្រូវ o បង្ហាញពីការប្រើប្រាស់ និងការសន្សនាតាមទូរស័ព្ទ
	• ចេះរបៀបប្រើប្រាស់ពាក្យសំដីផ្លាស់ប្តូរទៅតាមស្ថានភាពនានា (ឧ. នៅកន្លែងលេង នៅក្នុងថ្នាក់រៀន)
	• សំរួលសួរសំលេង និងបែបបទនៃការនិយាយស្តីបានសមស្របទៅតាមស្ថានភាព និងអ្នកស្តាប់ ដូចជា ការលក់ ការទិញ ការសន្សនាតាមទូរស័ព្ទ
	• ពណ៌នាពីប្រសិទ្ធភាពនៃកាយវិការ ឥរិយាបថ និងទឹកមុខ ចំពោះអ្នកស្តាប់
ការអាន	• អានដោយខ្លួនឯង ដើម្បីអោយយល់រឿង កំណាព្យ និងអត្ថបទពិតកថាងាយៗ: o ព្យែករវាងអត្ថបទប្រឌិតកថា និងពិតកថា o ប្រើពាក្យ តួអង្គ កាលអាកាស និងដំណើររឿង ក្នុងការពិភាក្សា និងឆ្លើយសំនួរដែលទាក់ទងទៅនឹងសាច់រឿង o ពិភាក្សាអំពីរបៀបបញ្ចប់រឿងផ្សេងៗ និងបង្ហាញពីតំលៃអប់រំនៃរឿង o បង្ហាញពីចំណាប់អារម្មណ៍របស់អ្នកអានចំពោះរឿង
	• អនុវត្តវិធីស្វ័យកែលំអ នៅពេលអាន ដើម្បីយល់ន័យ: o អានឡើងវិញ o អានដើម្បីយល់ន័យ និងទីសេចក្តី o បញ្ចេញសំលេង
	• ប្រើចំណេះដឹងនៃលំដាប់តួអក្សរ (អក្សរខាងដើម និងអក្សរបន្ទាប់) ដើម្បីបើកវចនានុក្រម
	• ស្គាល់ផ្នែកផ្សេងៗនៃសៀវភៅ (ឧ. អារម្ភកថា តារាងមាតិកា ចំណងជើងជំពូក និងបទានុក្រម)

	• ប្រើឧទាហរណ៍ពីអត្ថបទដែលអាន ដើម្បី: o បង្ហាញគុណនាម និងទំនាក់ទំនងរវាងគុណនាម និងនាម o បង្ហាញពីផ្នែកដែលទាក់ទងទៅនឹងល្បះ o បង្ហាញសព្ទនាម និងដឹងអំពីរបៀបប្រើសព្ទនាមជំនួសនាម o បង្ហាញ និងពន្យល់ពីរបៀបប្រើប្រាស់អព្ភន្តរសញ្ញា
ការសរសេរ	• **សរសេរអត្ថបទខ្លីៗ សំរាប់បំពេីគោលបំណង និងអ្នកអាន ខុសៗគ្នា រួមមាន:** o **រឿងនិទានមួយ** o អត្ថបទអធិប្បាយដែលមានលក្ខណៈកាន់តែពិស្តារ o អត្ថបទដែលបង្ហាញពីគំនិតមួយ
	• **បំពេញអោយបានត្រឹមត្រូវនូវទំរង់បែបបទនានា ដូចជា កំរងសំនួរ ពាក្យសុំចូលរៀន និង ពាក្យសុំ ច្បាប់ឈប់សំរាក**
	• សរសេរតាមអានអត្ថបទខ្លីៗ
	• **ចង្កុលបង្ហាញនិងប្រើប្រាស់បានត្រឹមត្រូវក្នុងសំណេរផ្ទាល់ខ្លួន:** o នាមសាធារណ៍ និងនាមអសាធារណ៍ o **សព្ទនាម និងគុណកិរិយា** o សញ្ញាលេខទោ សញ្ញាទណ្ឌឃាត សញ្ញាក្បៀសបើកបិទ(អព្ភន្តរសញ្ញា) សញ្ញាអស្តារ
	• ប្រើវិធីផ្សេងៗគ្នា ដើម្បីធ្វើអក្ខរវិញ្ញាស នៅក្នុងសំណេររបស់ខ្លួន: o ធ្វើអក្ខរវិញ្ញាសពាក្យដែលប្រើញឹកញាប់ បានត្រឹមត្រូវ o ដឹងពីការធ្វើអក្ខរវិញ្ញាស ខុស និងត្រូវ o ប្រើចំណេះដឹងពីរូបរាងតួអក្សរដែលធ្លាប់ស្គាល់ ដើម្បីប្រកបពាក្យថ្មី
	• រៀបចំសំណេរដោយផ្ទិតផ្ទង់ និងឡើងបង្ហាញបានត្រឹមត្រូវ
ធ្វើការជាក្រុម	• ចូលរួមចំណែកក្នុងការងារក្រុម

កំណត់សំគាល់: អក្សរខ្មៅដិតច្បាស់នៅក្នុងលទ្ធផលសិក្សាគឺដកចេញមកពីស្តង់ដា ជាចំណុចដែលកំណត់អោយសិស្សត្រូវតែសំរេចអោយបាន នៅដំណាច់ឆ្នាំសិក្សាថ្នាក់ទី៦ ។

មេរៀនភាសាខ្មែរ ថ្នាក់ទី៤

មេរៀនទី១ (៣៨ ម៉ោ)

ទំព័រសៀវភៅ

• ចូលរួមធ្វើការណែនាំ តាមក្រុមតូច។	
• បង្ហាញវិរិយាបថក្នុងការស្តាប់ប្រកបដោយប្រសិទ្ធភាព ពេលស្តាប់រឿងដែលគេអានឮ : o ពិភាក្សាអំពីព្រឹត្តិការណ៍នៃរឿង o បង្ហាញចរិតលក្ខណៈរបស់តួអង្គ o ប៉ាន់ស្មានអ្វីដែលកើតឡើងនៅពេលបន្ទាប់	១២៦ ៦ ៦
• អានរឿងខ្លី។ ដោយខ្លួនឯង: o បង្ហាញព្រឹត្តិការណ៍នៃរឿង	១២៧
• អនុវត្តវិធីស្វ័យកែលំអនៅពេលអានដើម្បីយល់ន័យ: o អានឡើងវិញ o អានដោយបញ្ចេញសំលេងច្បាស់លាស់	១៦ ១៦
• ចង្អុលបង្ហាញ និងប្រើប្រាស់នាមសាធារណ៍ នៅក្នុងសំណេរផ្ទាល់ខ្លួន	
• សរសេរតាមអានអត្ថបទខ្លី o ធ្វើអក្ខរាវិញ្ញាសពាក្យដែលប្រើញឹកញាប់បានត្រឹមត្រូវ	
• រៀបចំសំណេរដោយផ្ទិតផ្ទង់ និងឡើងបង្ហាញបានត្រឹមត្រូវ	

មេរៀនទី២ (៣៨ ម៉ោ)

ទំព័រសៀវភៅ

• ប្រើភាសានិយាយដោយមានភាពច្បាស់លាស់ត្រឹមត្រូវក្នុងការប្រាប់ទិសទៅរកកន្លែងណាមួយ ដោយធ្វើការជា ដៃគូ	
• បង្ហាញវិរិយាបថក្នុងការស្តាប់ប្រកបដោយប្រសិទ្ធភាព ពេលស្តាប់រឿងនិទាន ដែលគេអានឮ : o ពិភាក្សាអំពីដំបូន្មានរឿង o បង្ហាញអារម្មណ៍និងមនោសញ្ចេតនារបស់តួអង្គ	១៧ ៦៤
• អានរឿងខ្លី។ ដោយខ្លួនឯង: o បង្ហាញព្រឹត្តិការណ៍នៃរឿង o ប្រើពាក្យតួអង្គនិងកាលអាកាសក្នុងការពិភាក្សានិងឆ្លើយសំនួរដែលទាក់ទងទៅនឹងសាច់រឿង	១៣៨ ១៣៧
• អនុវត្តវិធីស្វ័យកែលំអនៅពេលអានដើម្បីយល់ន័យនៃពាក្យដែលមិនធ្លាប់ស្គាល់: o អានឡើងវិញ o អានដើម្បីយល់ទីសេចក្តី (បរិបទ) o ប្រើចំណេះដឹងអំពីលំដាប់តួអក្សរដើម្បីបើកបទានុក្រមនិងវចនានុក្រម	១០៣
• ដកស្រង់ឧទាហរណ៍ចេញពីអត្ថបទដើម្បី: o បង្ហាញគុណនាម និងទំនាក់ទំនងរវាងគុណនាម និងនាម	៦៨
• សរសេរតាមអានអត្ថបទខ្លី។:	

o ធ្វើអក្ខរវិញ្ញាសពាក្យដែលប្រើញឹកញាប់បានត្រឹមត្រូវ o ដឹងពីការធ្វើអក្ខរវិញ្ញាស ខុស និងត្រូវ o ប្រើចំណេះដឹងពីរូបរាងតួអក្សរដែលធ្លាប់ស្គាល់ ដើម្បីប្រកបពាក្យថ្មី	១៣ ១៣
• រៀបចំសំណេរដោយផ្ទិតផ្ទង់ និងឡើងបង្ហាញបានត្រឹមត្រូវ	

មេរៀនទី៣ (៣៨ ម៉) **ទំព័រស.ស**

• អភិវឌ្ឍល្បែងដើរតួងាយៗជាដៃគូអំពីបែបបទនៃការនិយាយស្តីទៅតាមស្ថានភាពផ្សេងៗ(ឧ.ក្នុងទីធ្លាសាលា ធ្យែបនឹងក្នុងថ្នាក់រៀន ឬ នៅក្នុងផ្សារ)	
• បង្ហាញតរិយាបថក្នុងការស្តាប់ប្រកបដោយប្រសិទ្ធភាព ពេលស្តាប់រឿងនិទាន ដែលគេអានញ : o ប្រាប់ដំណើររឿងឡើងវិញបានត្រឹមត្រូវ o ពិភាក្សាពីការប្រែប្រួលនៃដំណើររឿងមួយចំនួន និងផលប៉ះពាល់ផ្នែកផ្សេងទៀតនៃរឿង	៦៥
• អានរឿងខ្លីៗ ដោយខ្លួនឯង: o ប្រើពាក្យដំណើររឿងនៅក្នុងការពិភាក្សានិងឆ្លើយនឹងសំនួរដែលទាក់ទងនឹងសាច់រឿង o ប្រើវិធីស្វ័យកែលំអមួយចំនួនដើម្បីយល់ន័យនៃពាក្យដែលពុំធ្លាប់ស្គាល់រួមទាំងការប្រើបទានុក្រម	១២៧ ១០៣
• ដកស្រង់ឧទាហរណ៍ចេញពីអត្ថបទ និងពន្យល់ពីការប្រើ: o អព្ភន្តរសញ្ញា ឬក្បៀសបើកបិទ	១៥៥
• រៀបចំ ព្រាង កែលំអ និងសរសេរសំរេចរឿងខ្លីងាយមួយ ដែលបង្កើតឡើងដោយខ្លួនឯង រួមមាន: o តួអង្គឯក o ព្រឹត្តិការណ៍សំខាន់មួយ o កាលអាកាសច្បាស់លាស់មួយ • សរសេរតាមអានអត្ថបទខ្លីៗ	
• បង្ហាញ និងប្រើនៅក្នុងអត្ថបទសំណេរផ្ទាល់ខ្លួន : o សញ្ញាក្បៀសបើកបិទ	
• រៀបចំសំណេរដោយផ្ទិតផ្ទង់ និងឡើងបង្ហាញបានត្រឹមត្រូវ	

មេរៀនទី៤ (៣៨ ម៉) **ទំព័រស.ស**

• បង្ហាញតរិយាបថក្នុងការស្តាប់ដោយយកចិត្តទុកដាក់: o ធ្វើតាមការណែនាំច្រើនជំហាន តាមគ្រូ ឬតាមសិស្សដទៃ	
• ប្រើភាសានិយាយដោយមានភាពច្បាស់លាស់ត្រឹមត្រូវ: o ផ្តល់ការណែនាំច្បាស់លាស់ និងតាមលំដាប់លំដោយត្រឹមត្រូវ	
• អានអត្ថបទព័តិមានងាយៗ ដោយខ្លួនឯង: o បង្ហាញពីប្រធានបទ និងគំនិតសំខាន់ៗនៅក្នុងកថាខណ្ឌ o សង្ខេបគំនិតសំខាន់ៗនៅក្នុងកថាខណ្ឌនីមួយៗ	៦២ ៦៦

o ប្រាប់ អំណះអំណាងលើអត្ថបទពិតកថា (មិនមែនជាអត្ថបទ ប្រឌិតកថា) o អនុវត្តវិធីស្ប័យកែលំអ ដើម្បីអានអោយយល់ន័យនៃពាក្យថ្មី	
• ប្រើសៀវភៅព័តិមាន ដើម្បីរកព័តិមានស្តីពីប្រធានបទដែលបានជ្រើសរើស o យល់ និងប្រើចំណងជើងជំពូក ដើម្បីរកព័តិមាន	
• ដកស្រង់ឧទាហរណ៍ចេញពីអត្ថបទ និងពន្យល់ពីការប្រើ: o នាមអសាធារណ៍	
• រៀបចំ ព្រាង កែលំអ និងសរសេរសំរេចអត្ថបទព័តិមានខ្លីមួយស្តីពីប្រធានបទដែលបានជ្រើសរើសដោយខ្លួនឯង	
• បំពេញលំហាត់ ទាក់ទងទៅនឹងពាក្យដែលខ្ចះ	៨២
• ចង្អុលបង្ហាញ និងប្រើប្រាស់នាមសាធារណ៍ និងអសាធារណ៍បានត្រឹមត្រូវនៅក្នុងសំណេរផ្ទាល់ខ្លួន	៤៤
• រៀបចំសំណេរដោយផ្ទិតផ្ទង់ និងឡើងបង្ហាញបានត្រឹមត្រូវ	

មេរៀនទី៥ (៣៨ ម៉) **ទំព័រស.ស**

• បង្ហាញតំរិយាបថក្នុងការស្តាប់ដោយយកចិត្តទុកដាក់: o ស្តាប់រឿងនិទានដែលគេអានញ និងពណិនាអំពីតួអង្គក្នុងរឿងនោះ	
• ប្រើភាសានិយាយដោយមានភាពច្បាស់លាស់ត្រឹមត្រូវ: o ធ្វើការជាក្រុមតូច ដើម្បីរៀបចំ ល្បែងដើរតួក្នុងរឿងខ្លីៗ ក្រោយពីបានស្តាប់ ឬបានអានរួច	១៣៤
• អានរឿងនិទាន ដោយខ្លួនឯង: o អនុវត្តវិធីស្ប័យកែលំអ ដើម្បីយល់ន័យនៃពាក្យថ្មីៗ	
• ដកស្រង់ឧទាហរណ៍ពីអត្ថបទដែលមានសព្ទនាមដើម្បីបង្ហាញសព្ទនាមនិងដឹងអំពីរបៀបប្រើសព្ទនាម ជំនួសនាម	១00
• រៀបចំ ព្រាង កែលំអ និងសរសេរសំរេចអត្ថបទខ្លី ពណិនាអំពីមនុស្ស ឬទីកន្លែង	១៧៨
• សរសេរតាមអានអត្ថបទខ្លី	
• បង្ហាញ និង ប្រើប្រាស់ត្រឹមត្រូវនៅក្នុងសំណេរផ្ទាល់ខ្លួន: o គុណនាម និងពាក្យបំពេញន័យ នៅក្នុងសំណេរបានត្រឹមត្រូវ	
• រៀបចំសំណេរដោយផ្ទិតផ្ទង់ និងឡើងបង្ហាញបានត្រឹមត្រូវ	

មេរៀនទី៦ (៣៨ ម៉) **ទំព័រស.ស**

• ធ្វើការជាក្រុមដើម្បីសំដែងល្បែងដើរតួ ដោយប្រើប្រាស់ភាសានិយាយបានច្បាស់លាស់ នៅពេល និយាយទូរស័ព្ទ ទៅកាន់មិត្តម្នាក់	
• បង្ហាញតំរិយាបថក្នុងការស្តាប់ប្រកបដោយប្រសិទ្ធភាព តាមរយ:ការសន្ទនាតាមទូរស័ព្ទ	
• អានរឿងនិទានខ្លីៗ ដោយខ្លួនឯង:	

o បង្ហាញ និងពិភាក្សាពីមូលហេតុនៃព្រឹត្តិការណ៍ o បង្ហាញ និងពិភាក្សាពីអារម្មណ៍របស់តួអង្គ o អនុវត្តវិធីស្វ័យកែលំអ ដើម្បីយល់ន័យនៃពាក្យថ្មីៗ	
• រៀបចំ ព្រាង កែលំអ និងសរសេរសំរេចអត្ថបទរឿងនិទានខ្លីមួយ ដោយមានការពណិនាពីតួអង្គ និងទីកន្លែងបាន ច្បាស់លាស់ត្រឹមត្រូវ	១៦៧
• បំពេញលំហាត់ ទាក់ទងទៅនឹងពាក្យដែលខ្វះ	
• បង្ហាញ និងប្រើប្រាស់សញ្ញាអស្ចារនៅក្នុងសំណេរផ្ទាល់ខ្លួន បានត្រឹមត្រូវ	
• រៀបចំសំណេរដោយផ្ទិតផ្ទង់ និងឡើងបង្ហាញបានត្រឹមត្រូវ	

មេរៀនទី៧ (៣៨ ម៉ោ) **ទំព័រសៀវភៅ.ស**

• ឡើងបង្ហាញក្នុងក្រុមតូចៗ ឬក្នុងថ្នាក់ ពីការចូលចិត្ត និងការមិនចូលចិត្ត ទៅតាមប្រធានបទដែលបានជ្រើសរើស (ឧ. តន្ត្រី ចំណីអាហារ ទីកន្លែង)	
• បង្ហាញឥរិយាបថក្នុងការស្តាប់ប្រកបដោយប្រសិទ្ធភាព ពេលស្តាប់អត្ថបទព័ត៌មាន: o ឆ្លើយនឹងសំនួរ អ្វី ឯណា ហេតុអ្វី យ៉ាងដូចម្តេច o ប្រាប់ពីហេតុ និងផល	
• អាន និងយល់អត្ថបទពត៌មាន: o ឆ្លើយនឹងសំនួរ អ្វី ឯណា ហេតុអ្វី យ៉ាងដូចម្តេច o អនុវត្តវិធីស្វ័យកែលំអនៅពេលអានដើម្បីយល់ន័យនៃពាក្យថ្មីៗ o បង្ហាញពីផ្នែកដែលទាក់ទងទៅនឹងល្បះ	១៧0
• រកគុណកិរិយា និងពន្យល់ពីការប្រើប្រាស់គុណកិរិយា ក្នុងអត្ថបទដកស្រង់	
• សរសេរតាមអានអត្ថបទខ្លីៗ	
• បំពេញទំរង់បែបបទបានត្រឹមត្រូវទាក់ទងទៅនឹងអត្ថបទព័ត៌មានមួយចំនួន : o ពាក្យសុំចូលរៀន o កំរងសំនួរ	
• ចងុលបង្ហាញ និងប្រើប្រាស់កិរិយា និងគុណកិរិយា បានត្រឹមត្រូវក្នុងសំណេរផ្ទាល់ខ្លួន	៥៨
• រៀបចំសំណេរដោយផ្ទិតផ្ទង់ និងឡើងបង្ហាញបានត្រឹមត្រូវ	

មេរៀនទី៨ (៣៨ ម៉ោ) **ទំព័រសៀវភៅ.ស**

• ប្រើភាសានិយាយ ដើម្បីបង្កើនភាពច្បាស់លាស់ នៅពេលសូត្រកំណាព្យក្នុងក្រុមតូច ឬក្នុងថ្នាក់ទាំងមូល ដោយប្រើកាយវិការ ឥរិយាបថ និងទឹកមុខបានត្រឹមត្រូវ	
• បង្ហាញឥរិយាបថក្នុងការស្តាប់ប្រកបដោយប្រសិទ្ធភាព ពេលស្តាប់កំណាព្យដែលសូត្រដោយសិស្សដទៃ: o បង្ហាញគំនិតសំខាន់ៗ នៅក្នុងកំណាព្យ	

o ប្រាប់ពាក្យចួន	
• អានកំណាព្យខ្លីៗ ដោយខ្លួនឯង: o ប្រាប់ឡើងវិញ ពីអត្ថន័យកំណាព្យ ដោយប្រើពាក្យផ្ទាល់ខ្លួន o អនុវត្តវិធីស្វ័យកែលំអ ដើម្បីយល់ន័យនៃពាក្យដែលពុំធ្លាប់ស្គាល់	៦២ ៦២
• រៀបចំ ព្រាង កែលំអ និងសរសេរសំរេចនូវអត្ថបទដែលបង្ហាញពីគំនិតមួយ	១៧៨
• សរសេរតាមអានកំណាព្យខ្លីៗ	
• បង្ហាញ និងប្រើប្រាស់ឈ្មោះបានត្រឹមត្រូវនៅក្នុងសំណេរផ្ទាល់ខ្លួន: o គុណនាម និងនាម	៨
• រៀបចំសំណេរដោយផ្ទិតផ្ទង់ និងឡើងបង្ហាញបានត្រឹមត្រូវ	

មេរៀនទី ៩ (៣៨ម៉ោ) **ទំព័រសៀវភៅ.....**

• ប្រើភាសានិយាយ ដើម្បីបង្កើនភាពច្បាស់លាស់ នៅពេលសំដែងមតិអំពីប្រធានបទណាមួយ ដោយប្រើកាយវិការ តរិយាបថ និងទឹកមុខបានត្រឹមត្រូវ	
• បង្ហាញតរិយាបថក្នុងការស្តាប់ប្រកបដោយប្រសិទ្ធភាព ពេលស្តាប់ការសំដែងទស្សនៈរបស់សិស្សដទៃ: o ប្រាប់ឡើងវិញនូវមតិយោបល់ដែលបានស្តាប់ o អោយឧទាហរណ៍អំពីការប្រើកាយវិការ តរិយាបថ និងទឹកមុខបានត្រឹមត្រូវ	
• អានអត្ថបទខ្លីៗ ដោយខ្លួនឯង ដែលបង្ហាញពីទស្សនៈ: o ពន្យល់ពីគំនិតសំខាន់ៗនៃអត្ថបទ o អនុវត្តវិធីស្វ័យកែលំអ ដើម្បីយល់ន័យនៃពាក្យដែលពុំធ្លាប់ស្គាល់	១៧៣ ១៧៣
• ចង្អុលបង្ហាញសញ្ញាទណ្ឌឃាត និងប្រាប់ពីរបៀបប្រើសញ្ញានេះ	
• បំពេញលំហាត់ ទាក់ទងទៅនឹងពាក្យដែលខ្វះ	
• រៀបចំសំណេរដោយផ្ទិតផ្ទង់ និងឡើងបង្ហាញបានត្រឹមត្រូវ	

មេរៀនទី១០ (៣៨ ម៉ោ) **ទំព័រសៀវភៅ.....**

• ប្រើភាសានិយាយ ដើម្បីបង្កើនភាពច្បាស់លាស់ ក្នុងការរៀបចំការឡើងសូត្រកំណាព្យតាមក្រុម: o ធ្វើការជាក្រុមប្រកបដោយប្រសិទ្ធភាព ដើម្បីពិភាក្សាពីបែបបទផ្សេងៗនៃការសូត្រកំណាព្យ o ហាត់ និងសូត្រកំណាព្យជាក្រុម	
• បង្ហាញតរិយាបថក្នុងការស្តាប់ប្រកបដោយប្រសិទ្ធភាព ពេលស្តាប់ចំរៀងរបស់ក្រុមសិស្សដទៃ: o ប្រាប់បានពីពាក្យចួន o ប្រាប់ឡើងវិញពីគំនិតសំខាន់នៃចំរៀង	១១២
• អានកំណាព្យ ដោយខ្លួនឯង: o ប្រាប់ពីអត្ថន័យនៃវគ្គនីមួយៗ o អនុវត្តវិធីស្វ័យកែលំអ ដើម្បីយល់ន័យនៃពាក្យថ្មីៗ	

• បង្ហាញពីការប្រើប្រាស់សញ្ញាលេខទោ នៅក្នុងសំណេរផ្ទាល់ខ្លួន	
• រៀបចំ ព្រាង កែលំអ និងសរសេរសំរេចនូវកំណាព្យខ្លីមួយ	
• សរសេរតាមអានកំណាព្យខ្លី។	
• រៀបចំសំណេរដោយផ្ទិតផ្ទង់ និងឡើងបង្ហាញបានត្រឹមត្រូវ	

លទ្ធផលសិក្សាភាសាខ្មែរ ថ្នាក់ទី៥

សមត្ថភាព	លទ្ធផលសិក្សា
ការស្តាប់	• បង្ហាញឥរិយាបថក្នុងការស្តាប់ ដោយយកចិត្តទុកដាក់ ពេលចូលរួមសកម្មភាព ជាដៃគូ ជាក្រុមនិងក្នុងថ្នាក់
	• ស្តាប់ និងថាឡើងវិញនូវចំណុចសំខាន់ៗនៃអត្ថបទដែលបានស្តាប់ (ទាំងអត្ថបទដែលអានឮ និងការធ្វើបទបង្ហាញរបស់អ្នកដទៃ) o **ញែកភាពខុសគ្នារវាងការពិត និងគំនិត នៅពេលស្តាប់ពត៌មានផ្សេងៗ**
	• ធ្វើតាមការណែនាំផ្ទាល់មាត់ ដើម្បីបំពេញកិច្ចការមួយ
ការនិយាយ	• ប្រើប្រាស់ភាសានិយាយ ដោយមានភាពច្បាស់លាស់ ត្រឹមត្រូវ ហើយពិស្តារ សំរាប់បំរើអោយគោលបំណងផ្សេងៗ ដូចជា: o ចូលរួមសំដែងជាក្រុម ឬ ទោល ក្នុងការសូត្រកំណាព្យ ប្រកបដោយប្រសិទ្ធភាព o **ចូលរួមល្បែងដើរតួមិនមានការព្រាងទុក (ឧ. ការសំភាសន៍ដែលទាមទារអោយសិស្សសួរ និងឆ្លើយសំនួរបាន)** o ធ្វើការអញ្ជើញ និងឆ្លើយតបនឹងការអញ្ជើញ
	• ប្រើប្រាស់កាយវិការ និងទឹកមុខ នៅពេលនិយាយក្នុងស្ថានភាពផ្សេងៗ
	• **ប្រើល្បឿន ភាពសូរ ការលើកដាក់សំលេង និងការបន្លឺពាក្យច្បាស់ ដើម្បីបង្កើនអត្ថន័យនៅពេលនិយាយ ឬអានឮ**
ការអាន	• អាន ដោយខ្លួនឯង និងយល់អត្ថន័យនៃរឿង កំណាព្យ និងអត្ថបទពិតកថា
	• **អាន និងយល់បានប្រភេទអត្ថបទ (ពិតកថា) ផ្សេងៗ ដែលមានពាក្យពហុព្យាង្គ រួមមានទាំងអត្ថបទ ការសែតការណែនាំច្រើនជំហាន សេចក្តីប្រកាសពត៌មាន និងកាលវិភាគងាយៗ និងបង្ហាញពីគោលបំណង របស់អត្ថបទ និងប្រភេទអ្នកអាន**
	• **អានដើម្បីយល់ និងបកស្រាយរឿង (ប្រឌិតកថា) ដែលមានលក្ខណៈកាន់តែស្មុគស្មាញ ដោយបង្កើត និងឆ្លើយសំនួរ ដែលទាក់ទងទៅនឹងតួអង្គ ព្រឹត្តិការណ៍ និងកាលអាកាសនៃរឿង:** o ផ្តល់មូលហេតុអំពីតួអង្គដោយគំនិតផ្ទាល់ខ្លួន o ធ្វើការសន្និដ្ឋានអំពីគំនិតដែលបង្កប់នៅក្នុងរឿង
	• អានដើម្បីយល់នូវអត្ថបទកំណាព្យនានា: o បង្ហាញពីរបៀបប្រើប្រាស់ពាក្យដើម្បីយល់ន័យនៅក្នុងអត្ថបទកំណាព្យរួមទាំងពាក្យចួន និងពាក្យផ្ចួន
	• ប្រើវិធីផ្សេងៗ នៅពេលអាន ដើម្បីយល់អត្ថបទ: o ធ្វើកំណត់ត្រា o សួរសំនួរ

	• **ប្រើវិធីផ្សេងៗ ដើម្បីយល់ន័យពាក្យ និងអត្ថបទដែលមិនធ្លាប់ស្គាល់ ដូចជាការប្រើប្រាស់វចនានុក្រម បទានុក្រម និងបរិបទ**
	• ប្រើឧទាហរណ៍ពីអត្ថបទដែលបានអាន ដើម្បី : o បង្ហាញគុណនាម និងចំនាក់ចំនងរវាងគុណនាម និងនាម o បង្ហាញពីឈ្មោះ និងផ្នែកដែលទាក់ទងទៅនឹងល្បះ o បង្ហាញសព្ទនាម និងដឹងអំពីរបៀបប្រើសព្ទនាមជំនួសនាម o បង្ហាញអំពីប្រធាន និងកិរិយាបង្គោល នៅក្នុងល្បះ o បង្ហាញ និងពន្យល់ពីរបៀបប្រើប្រាស់អព្ភន្តរសញ្ញា
ការសរសេរ	• **សរសេរអត្ថបទខ្លីៗ សំរាប់បំរើអោយ គោលបំណង និងអ្នកអានខុសៗគ្នា ដែលរួមមាន:** o រឿងនិទានមួយ o **អត្ថបទបែបបញ្ចុះបញ្ចូល ដែលបង្ហាញពីគំនិតមួយ** o **លិខិតផ្ទាល់ខ្លួន** o **កំណត់ត្រាប្រចាំថ្ងៃ** o កំណាព្យខ្លី
	• ចង្អុលបង្ហាញនិងប្រើប្រាស់បានត្រឹមត្រូវក្នុងសំណេរផ្ទាល់ខ្លួន: o ប្រភេទរបស់នាម (នាមករណ: នាមការក:) o ប្រភេទរបស់សព្ទនាម (សព្ទនាមបុរិស: សព្ទនាមចង្អុល សព្ទនាមសំនួរ សព្ទនាមឈ្មោះ) o ប្រភេទរបស់គុណនាម (គុណនាមកម្មសិទ្ធិ និងគុណនាមប្រក្រតី) o សញ្ញារះមុខ សញ្ញាចុចពីរ សញ្ញាឧទាន
	• អនុវត្តវិធីផ្សេងៗគ្នា ដើម្បីធ្វើអក្ខរវិញ្ញាស នៅក្នុងសំណេរផ្ទាល់ខ្លួន: o ពិនិត្យមើលការប្រកប ឬ អក្ខរវិញ្ញាស ដោយប្រើវចនានុក្រម o ស្គាល់ពាក្យសូរដូច
	• រៀបចំសំណេរដោយផ្ទិតផ្ទង់ និងឡើងបង្ហាញបានត្រឹមត្រូវ
ធ្វើការជាក្រុម	• រៀបចំផែនការ និងចូលរួមចំណែកក្នុងការងារក្រុម

កំណត់សំគាល់: អក្សរខ្មៅដិតច្បាស់នៅក្នុងលទ្ធផលសិក្សា គឺដកចេញមកពីស្តង់ដា ជាចំណុចដែលកំណត់អោយសិស្ស ត្រូវតែសំរេចអោយបាននៅដំណាច់ឆ្នាំសិក្សាថ្នាក់ទី៦ ។

មេរៀនភាសាខ្មែរ ថ្នាក់ទី៥

មេរៀនទី១: (៣២ ម៉ោ) **ទំព័រ ស.ស**

• បង្ហាញឥរិយាបថក្នុងការស្តាប់ប្រកបដោយប្រសិទ្ធភាពចំពោះរឿងដែលកាន់តែមានលក្ខណៈស្មុគស្មាញ ដែលគេអាន ឮ : o ពិភាក្សា និងសួរសំណួរដែលទាក់ទងទៅនឹងរឿង o បង្ហាញចរិតលក្ខណៈរបស់តួអង្គ o ប្រៀបធៀបតួអង្គមួយចំនួន o ប៉ាន់ស្មានព្រឹត្តិការណ៍ដែលនឹងកើតឡើងនៅ ពេលបន្ទាប់	៣២ ៧៣
• អានរឿងខ្លី ដោយខ្លួនឯង: o ប្រាប់ព្រឹត្តិការណ៍នៃរឿង o ឆ្លើយនឹងសំនួរ ទាក់ទងទៅនឹងតួអង្គ កាលអាកាស និងដំណើររឿង	២០ ២០
• អនុវត្តវិធីស្វ័យកែលំអ ដើម្បីយល់ន័យនៃពាក្យថ្មី o អានឡើងវិញ o បញ្ចេញសំលេងបានច្បាស់	៥ ៥
• ស្គាល់ និងប្រាប់បានពីប្រភេទនៃគុណនាម	
• សរសេរតាមអានអត្ថបទ: o ធ្វើអក្ខរាវិញ្ញាសពាក្យដែលប្រើញឹកញាប់បានត្រឹមត្រូវ o ដឹងពីការធ្វើអក្ខរាវិញ្ញាស ខុស និងត្រូវ o ប្រើចំណេះដឹងពីរូបរាងតួអក្សរ ដើម្បីប្រកបពាក្យដែលពុំធ្លាប់ស្គាល់	
• បំពេញលំហាត់ ទាក់ទងទៅនឹងពាក្យដែល ខ្វះ	៩៥
• រៀបចំសំណេរដោយផ្ទិតផ្ទង់ និងឡើងបង្ហាញបានត្រឹមត្រូវ	

មេរៀនទី២: (៣២ ម៉ោ) **ទំព័រ ស.ស**

• អានរឿងខ្លី ដោយខ្លួនឯង: o ប្រាប់ពីព្រឹត្តិការណ៍នៃរឿង o ពិភាក្សាអំពីតំលៃអប់រំនៃរឿង o បង្កើតនិងឆ្លើយសំនួរមួយចំនួនដែលទាក់ទងទៅនឹងអារម្មណ៍មនោសញ្ចេតនារបស់តួអង្គ កាលអាកាស និងដំណើររឿង o ឆ្លើយនឹងសំនួរ ដោយផ្អែកទៅលើអំណះអំណាងដកស្រង់ចេញពីសាច់រឿង	២០ ៣២ ៥៧ ៥៧
• អនុវត្តវិធីស្វ័យកែលំអ ដើម្បីយល់ន័យនៃពាក្យពហុព្យាង្គ	
• ធ្វើការជាដៃគូ ដើម្បីបង្កើត និងសំដែងល្បែងដើរតួក្នុងក្រុមតូច ឬ ក្នុងថ្នាក់ទាំងមូល តាមផ្នែកណាមួយនៃរឿង ខ្លី:	

o ប្រើកាយវិការ តរិយាបថ និង ទឹកមុខ	
• បង្ហាញតរិយាបថក្នុងការស្តាប់ប្រកបដោយប្រសិទ្ធភាព នៅពេលអ្នកដទៃកំពុងសំដែងល្បែងដើរតួ	
• ប្រើឧទាហរណ៍ពីអត្ថបទដែលបានអានដើម្បី : o ស្រង់គុណនាមប្រក្រតីនិងបង្ហាញទំនាក់ទំនងរវាង គុណនាមនិងនាម	
• រៀបចំ ព្រាង កែលំអ និងសរសេរសំរេចនូវរឿងនិទានខ្លីមួយ(ដោយអនុវត្តវិធីស្វ័យកែលំអ រួមទាំងប្រើវចនានុក្រម)	១១៥
• សរសេរពាក្យ សូរដូចនិងពាក្យមួយចំនួនក្នុងអត្ថបទដែលខ្លួនសរសេរ	
• សរសេរតាមអានអត្ថបទ	
• រៀបចំសំណេរដោយផ្ទិតផ្ទង់ និងឡើងបង្ហាញបានត្រឹមត្រូវ	

មេរៀនទី ៣ (៣០ ម៉ោ) **ទំព័រ.ស.ស**

• ប្រើភាសានិយាយ ដើម្បីបង្កើនភាពច្បាស់លាស់ ក្នុងការរៀបចំការឡើងសូត្រកំណាព្យដែលវែង ក្នុងក្រុមតូច ឬក្នុងថ្នាក់ ដោយប្រើកាយវិការ និងទឹកមុខ ប្រកបដោយប្រសិទ្ធភាព: o ប្រើក៏រិតសូរ ការលើកដាក់សំលេង និងការបន្ទឺពាក្យច្បាស់ ដើម្បីបង្កើនអត្ថន័យ	
• បង្ហាញតរិយាបថក្នុងការស្តាប់ប្រកបដោយប្រសិទ្ធភាព ពេលស្តាប់ការសូត្រកំណាព្យរបស់ក្រុមសិស្សដទៃ: o ប្រាប់ឡើងវិញពីគំនិតសំខាន់នៃកំណាព្យ o ប្រាប់បានពីពាក្យចូន	៦៥ ៦៥
• អានកំណាព្យវែង ដោយខ្លួនឯង: o ប្រាប់ពីអត្ថន័យនៃកំណាព្យ ដោយប្រើពាក្យផ្ទាល់ខ្លួន o អនុវត្តវិធីស្វ័យកែលំអ ដើម្បីយល់ន័យនៃពាក្យថ្មីៗ	១៤២ ១៤៣
• ចង្អុលបង្ហាញ និងប្រើប្រាស់គុណនាមកម្មសិទ្ធិបានត្រឹមត្រូវនៅក្នុងសំណេរផ្ទាល់ខ្លួន	
• រៀបចំកែលំអ និងសរសេរសំរេចនូវកំណាព្យខ្លីមួយ	
• សរសេរតាមអានកំណាព្យខ្លីៗ	
• អោយឧទាហរណ៏ ពាក្យសូរដូចមួយចំនួន	
• រៀបចំសំណេរដោយផ្ទិតផ្ទង់ និងឡើងបង្ហាញបានត្រឹមត្រូវ	

មេរៀនទី៤: (៣០ ម៉ោ) **ទំព័រ ស.ស**

• អានសេចក្តីរាយការណ៏សារព័តិមានងាយៗ ដោយខ្លួនឯង: o ប្រាប់ចំណុចសំខាន់ៗនៃរបាយការណ៏សារព័តិមានមួយ(ចំណងជើងអត្ថបទ សេចក្តីដកស្រង់សំដី មតិយោបល់) o បង្ហាញថា អត្ថបទនោះនិយាយពីអ្វី o បង្កើត និងឆ្លើយសំនួរមួយចំនួនដែលទាក់ទងទៅនឹងចំណុចសំខាន់ៗនៃអត្ថបទ	

o ឆ្លើយនឹងសំនួរ ដោយផ្អែកទៅលើអំណះអំណាងដកស្រង់ចេញពីអត្ថបទ o ប្រាប់ពីព្រឹត្តិការណ៍ និងមតិនៅក្នុងរបាយការណ៍ • អនុវត្តវិធីស្វ័យកែលំអ ដើម្បីយល់ន័យនៃពាក្យថ្មីៗ	
• ធ្វើការជាដៃគូ ដើម្បីអានសេចក្តីដកស្រង់នៅក្នុងអត្ថបទកាសែត និងរៀបចំល្បែងដើរតួពីការសំភាសន៍រវាងអ្នក សំភាសន៍និងអ្នកដែលត្រូវគេសំភាសន៍: o បង្កើតសំនួរ និងចំលើយបន្ថែម o ដើរតួ ជាក្រុម ឬ ជាមួយសិស្សទាំងអស់ក្នុងថ្នាក់	
• បង្ហាញតរិយាបថក្នុងការស្តាប់ប្រកបដោយប្រសិទ្ធភាព នៅពេលអ្នកដទៃកំពុងសំដែងល្បែងដើរតួ: o ប្រាប់ឡើងវិញនូវសំនួរមួយចំនួនដែលបានសួរនៅពេលសំដែង	
• ប្រាប់បានពីប្រភេទនៃសព្ទនាម និងប្រើសព្ទនាមក្នុងសំណេរផ្ទាល់ខ្លួន	
• រៀបចំ ព្រាង កែលំអ និងសរសេរសំរេចនូវរបាយការណ៍កាសែតខ្លីមួយ ដែលទាក់ទងទៅនឹងប្រធានបទដែលបានជ្រើសរើស ដោយខ្លួនឯង: o ធ្វើតាមចំណុចសំខាន់ៗនៃរបាយការណ៍ (ចំណងជើងអត្ថបទ សេចក្តីដកស្រង់សំដី មតិ យោបល់)	
• សរសេរតាមអានអត្ថបទ	
• បំពេញលំហាត់ ទាក់ទងទៅនឹងពាក្យដែលខ្វះ	៩៥
• រៀបចំសំណេរដោយផ្ទិតផ្ទង់ និងឡើងបង្ហាញបានត្រឹមត្រូវ	

មេរៀនទី៥: (៣០ ម៉ោ) **ធំពីរ ស.ស**

• ធ្វើការជាដៃគូ ដើម្បីរៀបចំ និងផ្តល់ព័តិមានច្បាស់លាស់ដល់ដៃគូអំពីព្រឹត្តិការណ៍ប្រឌិត ឬការពិតដែលនឹង កើតឡើងនៅក្នុងពេលអនាគតឆាប់ៗ រួមមានទាំងការបញ្ជាក់ពីទីតាំង	
• បង្ហាញតរិយាបថក្នុងការស្តាប់ប្រកបដោយប្រសិទ្ធភាព នៅពេលស្តាប់ព័តិមាន	២0
• ធ្វើកំណត់សំគាល់ ដោយសរសេរព័តិមានសំខាន់ៗមួយចំនួន	
• អានសេចក្តីប្រកាស ឬសេចក្តីជូនដំណឹងមួយចំនួន ដោយខ្លួនឯង: o ធ្វើតាមចំណុចសំខាន់ៗនៃសេចក្តីប្រកាសឬសេចក្តីជូនដំណឹង(សង្ខេបព័តិមាន សេចក្តីពណិនាមានកំណត់ មតិមិនផ្ទាល់) o ប្រាប់បាន ពីខ្លឹមសារនៃសេចក្តីប្រកាស ឬសេចក្តីជូនដំណឹងនោះ o ប្រាប់ពីគោលបំណង និងអ្នកអានសេចក្តីប្រកាស ឬសេចក្តីជូនដំណឹង o បង្កើតនិងឆ្លើយសំនួរទាក់ទងទៅនឹងចំណុចសំខាន់ៗនៃសេចក្តីប្រកាសឬសេចក្តីជូនដំណឹង o ឆ្លើយនឹងសំនួរដោយផ្អែកទៅលើអំណះអំណាងដកស្រង់ចេញពីសេចក្តីប្រកាស ឬសេចក្តីជូនដំណឹង o បង្ហាញអំណះអំណាងថា សេចក្តីប្រកាស ឬសេចក្តីជូនដំណឹងមិនមែនជាអត្ថបទប្រឌិតកថា	
• អនុវត្តវិធីស្វ័យកែលំអ ដើម្បីយល់ន័យនៃពាក្យពហុព្យាង្គ	
• ប្រាប់បានពីសព្ទនាមបុរិស: និងប្រើប្រាស់បានត្រឹមត្រូវ ក្នុងសំណេរផ្ទាល់ខ្លួន	

• រៀបចំ ព្រាង កែលំអ និងសរសេរសំរេច សេចក្តីប្រកាស ឬសេចក្តីជូនដំណឹងខ្លីមួយ ដែលទាក់ទងទៅនឹង ប្រធានបទ ដែលបានជ្រើសរើសដោយខ្លួនឯង: o ធ្វើតាមចំណុចសំខាន់ៗនៃសេចក្តីប្រកាសឬសេចក្តីជូនដំណឹង(ព័តិមានពិតសេចក្តីពណិនាមានកំណត់មតិមិនផ្ទាល់)	
• សរសេរតាមអានអត្ថបទ	
• រៀបចំសំណេរដោយផ្ទិតផ្ទង់ និងឡើងបង្ហាញបានត្រឹមត្រូវ	

មេរៀនទី៦: (៣០ ម៉ោ) **ទំព័រ ស.ស**

• អានកំណត់ត្រាប្រចាំថ្ងៃ ដោយខ្លួនឯង: o ប្រាប់ពីចំណុចសំខាន់ៗនៃកំណត់ត្រា - ក្នុងទំរង់ជាបុរសទីមួយ - មានមតិ យោបល់ផ្ទាល់ខ្លួនច្រើន - មានការពណិនាច្រើន	
• អនុវត្តវិធីស្វ័យកែលំអ ដើម្បីយល់ន័យនៃពាក្យពហុព្យាង្គ	៥២
• ធ្វើការជាដៃគូប្តូរវេនដើម្បីរៀបចំការពណិនាផ្ទាល់មាត់ទាក់ទងទៅនឹងហេតុការណ៏ណាមួយដែលបានដកស្រង់ ចេញពីកំណត់ត្រាប្រចាំថ្ងៃ ដោយប្រាប់ពីទស្សន:របស់អ្នកសរសេរកំណត់ត្រាប្រចាំថ្ងៃ	
• ឡើងបង្ហាញផ្ទាល់មាត់ជាដៃគូ ឬបង្ហាញដល់សិស្សទាំងអស់	
• ចង្អុលបង្ហាញ និងប្រើប្រាស់សញ្ញារះមុខបានត្រឹមត្រូវ នៅក្នុងសំណេរផ្ទាល់ខ្លួន	
• បង្ហាញតរិយាបថក្នុងការស្តាប់ប្រកបដោយប្រសិទ្ធភាព នៅពេលអ្នកដទៃកំពុងបង្ហាញដោយផ្ទាល់មាត់ដោយពណិនាពី ព្រឹត្តិការណ៏ដកស្រង់ពីកំណត់ត្រាប្រចាំថ្ងៃ	
• រៀបចំ ព្រាង កែលំអ និងសរសេរសំរេចនូវកំណត់ត្រាប្រចាំថ្ងៃ ដែលទាក់ទងទៅនឹងរឿងឬចំណុចដែលបានជ្រើសរើស ដោយខ្លួនឯង: o ប្រាប់ពីចំណុចសំខាន់ៗនៃកំណត់ត្រាប្រចាំថ្ងៃ	
• សរសេរតាមអានអត្ថបទ	
• រៀបចំសំណេរដោយផ្ទិតផ្ទង់ និងឡើងបង្ហាញបានត្រឹមត្រូវ	

មេរៀនទី៧: (៣០ ម៉ោ) **ទំព័រ ស.ស**

• ស្តាប់សំបុត្រផ្ទាល់ខ្លួនរបស់នរណាម្នាក់ ដោយពុំស្គាល់ឈ្មោះអ្នកសរសេរ ឬ អ្នកទទួល: o តាមខ្លឹមសារនៃសំបុត្រ: - អោយយោបល់អំពីភេទ អាយុរបស់អ្នកសរសេរ និងអ្នកទទួល - អោយយោបល់អំពីរយៈពេលដែលពួកគេ (អ្នកសរសេរ និងអ្នកទទួល) ស្គាល់គ្នា o ផ្តល់មូលហេតុមួយចំនួន ដើម្បីគាំទ្រមតិ ដែលដកស្រង់ចេញមកពីសំបុត្រ	

• អានសំបុត្រផ្ទាល់ខ្លួនដោយខ្លួនឯង៖ o ប្រាប់ពីចំណុចសំខាន់ៗនៃសំបុត្រផ្ទាល់ខ្លួន - មានមតិ យោបល់ផ្ទាល់ខ្លួនច្រើន - មានការពណ៌នាច្រើន o ឆ្លើយនឹងសំនួរទាក់ទងទៅនឹងសំបុត្រផ្ទាល់ខ្លួន ដើម្បីបង្ហាញការយល់ដឹង	
• ប្រើវិធីស្ទ័យកែលំអ ដើម្បីយល់ន័យនៃពាក្យពហុព្យាង្គ	៥២
• រកឧទាហរណ៏ក្នុងអត្ថបទដែលបានអាន ៖ o ឈ្នាប់ និងផ្នែកដែលទាក់ទងនឹងល្បះ	
• រៀបចំ ព្រាង កែលំអនិងសរសេរសំរេច សំបុត្រផ្ទាល់ខ្លួនទៅមនុស្សម្នាក់ អំពីប្រធានបទ ដែលបានជ្រើសរើសដោយខ្លួនឯង៖ o ប្រើចំណុចសំខាន់ៗនៃសំបុត្របុគ្គល	១៦៧
• សរសេរតាមអានអត្ថបទ	
• បង្ហាញ និងប្រើប្រាស់ប្រភេទផ្សេងៗនៃគុណនាម រួមទាំងគុណនាមពណ៌នា គុណនាមកំរិត ក្នុងសំណេរផ្ទាល់ខ្លួន បានត្រឹមត្រូវ	
• រៀបចំសំណេរដោយផ្ចិតផ្ចង់ និងឡើងបង្ហាញបានត្រឹមត្រូវ	

មេរៀនទី៨៖ (៣០ ម៉) **ទំព័រ ស.ស**

• អានអត្ថបទឃោសនាងាយៗ ដែលបង្ហាញពីទស្សនៈមួយ៖ o បង្ហាញពីប្រធានបទសំខាន់នៃអត្ថបទ o បង្ហាញពីទស្សនៈរបស់អ្នកសរសេរ ក្នុងប្រធានបទ o បង្ហាញពីការពិត និងទស្សនៈ ចេញពីអត្ថបទ o បង្ហាញមូលហេតុមួយចំនួន គាំទ្រទស្សនៈរបស់អ្នកសរសេរ	
• អនុវត្តវិធីស្ទ័យកែលំអ ដើម្បីយល់ន័យនៃពាក្យពហុព្យាង្គ	
• ប្រើឧទាហរណ៏ពីអត្ថបទដែលបានអាន ដើម្បី ៖ o បង្ហាញប្រធាន និងកិរិយាបង្គោលក្នុងល្បះ	
• រៀបចំ ព្រាង កែលំអ និងសរសេរសំរេច នូវអត្ថបទឃោសនាងាយៗ ដែលទាក់ទងទៅនឹងប្រធានបទដែល បានជ្រើសរើសដោយខ្លួនឯង	
• ឡើងធ្វើបទបង្ហាញខ្លីមួយ អោយក្រុមតូចៗ ឬសិស្សទាំងអស់ស្តាប់៖ o ពន្យល់ពីប្រធានបទនៃអត្ថបទសំណេរបែបឃោសនា o ពន្យល់ពីមតិផ្ទាល់ខ្លួន លើប្រធានបទ និងផ្តល់មូលហេតុមួយចំនួន ដើម្បីគាំទ្រមតិនោះ o ឆ្លើយនឹងសំនួររបស់អ្នកស្តាប់អំពីមតិនេះ	
• បង្ហាញឥរិយាបថក្នុងការស្តាប់ប្រកបដោយប្រសិទ្ធភាពនៅពេលស្តាប់ការនិយាយ(បទបង្ហាញ) អំពីគំនិត៖	

○ សួរសំនួរដែលទាក់ទងទៅនឹងគំនិត	
• សរសេរតាមអានអត្ថបទ	
• រៀបចំសំណេរដោយផ្ទិតផ្ទង់ និងឡើងបង្ហាញបានត្រឹមត្រូវ	

មេរៀនទី ៩ (៣០ ម៉ោ) **ទំព័រសៀវភៅ**

• ប្រើភាសានិយាយ ដើម្បីបង្កើនភាពច្បាស់លាស់ ក្នុងការរៀបចំការឡើងសូត្រកំណាព្យអោយក្រុមតូចៗ ឬសិស្សទាំងអស់ស្តាប់ ដោយប្រើកាយវិការ និងទឹកមុខត្រឹមត្រូវ: ○ ប្រើកិរិតសូរ ការលើកដាក់សំលេង និងការបន្ធឺពាក្យច្បាស់ ដើម្បីបង្កើនអត្ថន័យ	
• បង្ហាញឥរិយាបថក្នុងការស្តាប់ប្រកបដោយប្រសិទ្ធភាព ពេលស្តាប់ការសូត្រកំណាព្យរបស់ក្រុមសិស្សដទៃ: ○ ប្រាប់ឡើងវិញពីគំនិតសំខាន់នៃកំណាព្យ ○ ប្រាប់បានពីពាក្យចូន	 ៥២ ៥២
• អានកំណាព្យវែង ដោយខ្លួនឯង: ○ ប្រាប់ពីអត្ថន័យនៃវគ្គនីមួយៗ ដោយប្រើពាក្យផ្ទាល់ខ្លួន ○ អនុវត្តវិធីស្វ័យកែលំអ ដើម្បីយល់ន័យនៃពាក្យថ្មីៗ	
• ចង្អុលបង្ហាញ និងប្រើប្រាស់សញ្ញាចុចពីរបានត្រឹមត្រូវ ក្នុងសំណេរផ្ទាល់ខ្លួន	
• រៀបចំ ព្រាង កែលំអ និងសរសេរសំរេចនូវកំណាព្យខ្លីមួយ	
• សរសេរតាមអានកំណាព្យខ្លីៗ	
• រៀបចំសំណេរដោយផ្ទិតផ្ទង់ និងឡើងបង្ហាញបានត្រឹមត្រូវ	

មេរៀនទី ១០ (៣០ ម៉ោ) **ទំព័រសៀវភៅ**

• អានការណែនាំច្រើនជំហានដោយខ្លួនឯង (ការណែនាំអំពីការដំឡើងសំភារៈ របៀបធ្វើម្ហូប ស្បៀវភៅសំរាប់ជូសជុល) ○ បង្ហាញចំណុចសំខាន់ៗនៃការណែនាំ (សេចក្តីសង្ខេបព័ត៌មានពិត សេចក្តីពណ៌នាមានកំណត់និងមតិមិនផ្ទាល់) ○ ឆ្លើយនឹងសំនួរដែលទាក់ទង ដើម្បីបង្ហាញពីការយល់ដឹង	
• អនុវត្តវិធីស្វ័យកែលំអ ដើម្បីយល់ន័យនៃពាក្យពហុព្យាង្គ ដែលមិនធ្លាប់ស្គាល់	
• ប្រើសញ្ញាឧទានបានត្រឹមត្រូវ ក្នុងសំណេរផ្ទាល់ខ្លួន	
• រៀបចំ ព្រាង កែលំអ និងសរសេរសំរេចនូវការណែនាំច្រើនជំហាន តាមប្រធានបទដែលបានជ្រើសរើសដោយខ្លួនឯង : ○ ធ្វើតាមចំណុចសំខាន់ៗនៃការណែនាំ	
• រៀបចំការណែនាំផ្ទាល់មាត់ ទាក់ទងទៅនឹងសកម្មភាពបត់ក្រដាស	
• ធ្វើការជាដៃគូ ដោយប្តូរវេនឡើងនិយាយ និងធ្វើតាមការណែនាំ ដើម្បីបំពេញសកម្មភាពបត់ក្រដាស	

លទ្ធផលសិក្សាភាសាខ្មែរ ថ្នាក់ទី៦

សមត្ថភាព	**លទ្ធផលសិក្សា**
ការស្តាប់	• បង្ហាញឥរិយាបថក្នុងការស្តាប់ ដោយយកចិត្តទុកដាក់ នៅពេលចូលរួមសកម្មភាពជាដៃគូ ជាក្រុម និងក្នុងថ្នាក់
	• ស្តាប់និងចាប់ផ្តើមវិញ្ញូវចំណុចសំខាន់ៗនៃអត្ថបទដែលបានស្តាប់(ទាំងអត្ថបទដែលគេអានឮនិងការធ្វើបទបង្ហាញ របស់អ្នកដទៃ)៖ o **ស្តាប់ កត់ត្រា និងឆ្លើយតបទៅនឹងគំនិត និងសេចក្តីលំអិតដែលបានបង្ហាញដោយសិស្ស ដទៃទៀត**
	• ផ្តល់យោបល់ពីការប្រើប្រាស់ កាយវិការ និងទឹកមុខ នៅពេលអ្នកដទៃនិយាយ
	• សង្ខេប និងរាយការណ៍បានត្រឹមត្រូវ ពីលទ្ធផលពិភាក្សារបស់ក្រុម
ការនិយាយ	• ប្រើប្រាស់ភាសានិយាយបានត្រឹមត្រូវ ច្បាស់លាស់ ហើយពិស្តារ ទៅតាមគោលបំណងផ្សេងៗ ៖ o អាន ឬ ប្រាប់រឿងឡើងវិញដល់អ្នកស្តាប់ដែលមានវ័យក្មេងជាង o **បង្ហាញគំនិតផ្ទាល់ខ្លួន ដោយប្រាប់ហេតុផលច្បាស់លាស់ លើប្រធានបទដែលសិស្សជ្រើស រើសដល់អ្នកស្តាប់ ដែលធ្លាប់ស្គាល់** . ហ្វឹកហាត់ និងកែលំអបទបង្ហាញផ្ទាល់មាត់អោយសិស្សក្នុងថ្នាក់ស្តាប់ . ប្រើរូបគំនូរ ឬ កំណត់ត្រានៅលើក្តារខៀន ឬ ក្រដាស ដើម្បីជាជំនួយសំរាប់និយាយ
	• **ប្រើសួរសំលេង និងការលើកដាក់សំលេង** ធ្វើជាតួអង្គផ្សេងៗ **នៅពេលអានរឿង**
	• ចង្អុលបង្ហាញភាពខុសគ្នាមួយចំនួនរវាងភាសានិយាយ និងភាសាសរសេរ
ការអាន	• អានដោយខ្លួនឯង និងយល់អត្ថន័យនៃរឿង កំណាព្យ និងអត្ថបទពិតកថា
	• **អាន ដើម្បីយល់អត្ថន័យនៃអត្ថបទពិតកថាផ្សេងៗ:** o **បង្ហាញពីអ្នកអាន និងគោលបំណងផ្សេងៗនៃអត្ថបទពិតកថា** o រកពត៌មានក្នុងអត្ថបទពិតកថា o ធ្វើតាមការណែនាំនៅក្នុងអត្ថបទ o ប្រាប់ឡើងវិញនូវសេចក្តីពន្យល់ ដែលទាក់ទងទៅនឹងហេតុការណ៍ o បកស្រាយរូបតំណាងផ្សេងៗ ដែលមានលក្ខណៈកាន់តែស្មុគស្មាញ
	• **អាន ដើម្បីយល់ន័យរឿង និងកំណាព្យនានា:** o **បង្ហាញអារម្មណ៍ របស់តួអង្គក្នុងរឿង** o ទាញសេចក្តីសន្និដ្ឋានអំពីគំនិតដែលបង្កប់នៅក្នុងរឿង o ប្រាប់ឡើងវិញនូវផ្នែកមួយចំនួនក្នុងរឿង ទៅតាមទស្សនៈរបស់អ្នកនិទានផ្សេងៗ o សរសេរសង្ខេបអត្ថបទប្រឌិតកថា

	• **ប្រើវិធីផ្សេងៗ នៅពេលអាន ដើម្បីយល់ន័យនៃអត្ថបទ**ដែលមានលក្ខណៈកាន់តែស្មុគស្មាញ: o អានឡើងវិញ o **អានដើម្បីយល់ន័យ និងទីសេចក្តី** o កត់ត្រា និងសង្ខេបពត៌មានសំខាន់ៗ o សួរសំនួរ o **ប្រើវចនានុក្រម** • ដកស្រង់ឧទាហរណ៍ចេញពីអត្ថបទ ដែលអាន : o បង្ហាញពាក្យន័យដូច និងន័យផ្ទុយ
ការសរសេរ	• **សរសេរ អត្ថបទវែង សំរាប់បំរើអោយគោលបំណង និងអ្នកអានខុសៗគ្នាដែលរួមមាន:** o **រឿងនិទាន ដែលមានតួអង្គច្រើន** o អត្ថបទណែនាំ និងអត្ថបទពត៌មាន o **អត្ថបទបែបបញ្ចុះបញ្ចូល ដែលបង្ហាញពីគំនិតមួយ** o កំណាព្យ
	• **ប្រើ សញ្ញាផាត់លើ (សំយោគសញ្ញា)** សញ្ញាវង់ក្រចក **បានត្រឹមត្រូវ**
	• ពង្រីកចំណេះដឹងផ្នែកវាក្យសព្ទ ក្នុងសំណេរផ្ទាល់ខ្លួន ដោយប្រើវាក្យសព្ទដែលចេះតាមរយៈអំណាន
	• ប្រើទំរង់ដូចជា តារាង ចំណុចមូល លេខលំដាប់ គំនូសដើម្បីបង្កើនភាពច្បាស់លាស់នៅក្នុងអត្ថបទណែនាំ និងអត្ថបទ ព័ត៌មាន
ធ្វើការជាក្រុម	• **អោយឈ្មោះមនុស្សដែលមានតួនាទីក្នុងក្រុម(ឧ.ប្រធានអ្នកកត់ត្រា)និងរួមចំណែកក្នុងការងារក្រុមតាមតួនាទីខុសៗគ្នា**

កំណត់សំគាល់: អក្សរខ្មៅដិតច្បាស់នៅក្នុងលទ្ធផលសិក្សាគឺដកចេញមកពីស្តង់ដា ជាចំណុចដែលកំណត់អោយសិស្សត្រូវតែ សំរេចអោយបាននៅដំណាច់ឆ្នាំសិក្សាថ្នាក់ទី៦ ។

មេរៀនភាសាខ្មែរ ថ្នាក់ទី៦

មេរៀនទី១: (៣០ ម៉ោ) **ចំពាំរ ស.ស**

• បង្ហាញឥរិយាបថក្នុងការស្តាប់ប្រកបដោយប្រសិទ្ធភាព ពេលស្តាប់កំណាព្យដែលអានលឺ: o កត់ត្រាគំនិតសំខាន់ៗ នៅក្នុងកំណាព្យ o ឆ្លើយនឹងសំនួរដែលទាក់ទងទៅនឹងកំណាព្យ	 ៦ ៦
• ជ្រើសរើសកំណាព្យ អាន ឮ : o ហាត់ និងឡើងអានអោយសិស្សក្រុមតូច ឬសិស្សក្នុងថ្នាក់រៀនស្តាប់: - ប្រើការលើកដាក់សំលេង ទឹកមុខ និងកាយវិការ ស្របទៅនឹងន័យក្នុងអត្ថបទ	៤៣
• អានកំណាព្យដែលបានជ្រើសរើស ដោយខ្លួនឯង: o អនុវត្តវិធីស្វ័យកែលំអ ដើម្បីយល់ន័យនៃពាក្យពហុព្យាង្គ - អានដើម្បីយល់ទីសេចក្តី - បញ្ចេញសំលេង - ប្រើវចនានុក្រម o ឆ្លើយនឹងសំនួរដែលទាក់ទងទៅនឹងកំណាព្យ ដើម្បីបង្ហាញការយល់ដឹង	 ៤៣ ៤៣ ១៦១ ១៦១
• ចង្អុលបង្ហាញ និងប្រើប្រាស់គុណនាមចំនួនបានត្រឹមត្រូវ	
• រៀបចំ ព្រាង កែលំអ និងសរសេរសំរេចនូវកំណាព្យខ្លីមួយ	
• បង្ហាញពាក្យន័យដូចមួយចំនួន ទៅនឹងពាក្យដែលប្រើនៅក្នុងកំណាព្យរបស់ខ្លួន	
• រៀបចំសំណេរដោយផ្ទិតផ្តង់ និងឡើងបង្ហាញបានត្រឹមត្រូវ	

មេរៀនទី២: (៣០ ម៉ោ) **ចំពាំរ ស.ស**

• ជ្រើសរើសរឿងខ្លីមួយ ដើម្បីអាន ឮ អោយសិស្សតូច១ស្តាប់ : o ឆ្លើយនឹងសំនួរដែលទាក់ទងទៅនឹងរឿងនិទាន ដើម្បីបង្ហាញការយល់ដឹង o ធ្វើការជាដៃគូដើម្បីរៀបចំនិងហាត់អានរឿងរួមទាំងធ្វើការបញ្ចេញសំលេងនិងការលើកដាក់សំលេង តាមតួអង្គផ្សេងៗ o ឡើងអានរឿងអោយសិស្សតូច១ស្តាប់ដោយប្រើប្រាស់កាយវិការទឹកមុខនិងឥរិយាបថ ប្រកបដោយប្រសិទ្ធភាព	៤៩
• ប្រើប្រាស់គុណនាមសំនួរបានត្រឹមត្រូវ ក្នុងសំណេរផ្ទាល់ខ្លួន	
• បង្ហាញឥរិយាបថក្នុងការស្តាប់ប្រកបដោយប្រសិទ្ធភាព ពេលស្តាប់រឿងដែល គេអាន ឮ : o ផ្តល់យោបល់ស្ថាបនាពីការបង្ហាញសមត្ថភាពដើម្បីជួយអោយដៃគូអានកាន់តែមានលក្ខណៈប្រសើរឡើង	

• សរសេររបាយការណ៍មួយស្តីពីការអានរឿងអោយសិស្សតូចៗស្តាប់: ○ ផ្តល់សេចក្តីសង្ខេបរឿង និងពន្យល់មូលហេតុនៃការជ្រើសរើស ○ ដៅសំគាល់ផ្នែកណាដែលលំបាកឬផ្នែកណាដែលមានលក្ខណៈគួរអោយចាប់អារម្មណ៍ នៅពេលអាន ○ ពណ៌នាពីប្រតិកម្មរបស់អ្នកស្តាប់ ○ វាយតំលៃលើការអាន នូវចំណុចល្អ និងចំណុចដែលត្រូវកែលំអ	
• រៀបចំសំណេរដោយផ្ទិតផ្ទង់ និងឡើងបង្ហាញបានត្រឹមត្រូវ	

មេរៀនទី៣: (៣២ ម៉ោ) **ទំព័រ ស.ស**

• អានអត្ថបទព័ត៌មាន ដែលមានតារាង និងដ្យាក្រាម : ○ អនុវត្តវិធីស្វ័យកែលំអ ដើម្បីយល់ន័យនៃពាក្យពហុព្យាង្គ ដែលមិនធ្លាប់ស្គាល់ ○ បង្ហាញគោលបំណងផ្សេងៗ និងអ្នកអាន ○ សង្ខេបចំណុចសំខាន់ៗនៃព័ត៌មាន នៅក្នុងអត្ថបទ ○ រកចំលើយដើម្បីឆ្លើយនឹងសំនួរទាក់ទងពត៌មានក្នុងអត្ថបទ	
• ចង្អុលបង្ហាញ និងប្រើប្រាស់គុណនាមចង្អុលបានត្រឹមត្រូវ	
• សរសេរអត្ថបទព័ត៌មានខ្លីមួយ អំពីប្រធានបទដែលធ្លាប់ស្គាល់: ○ ប្រើទំរង់ ដូចជាតារាង លេខ ឬចំណុចមូលខ្មៅ ដើម្បីបង្ហាញព័ត៌មានអោយកាន់តែច្បាស់លាស់	
• ប្រើអត្ថបទព័ត៌មាន សំណេរផ្ទាល់ខ្លួន ជាមូលដ្ឋានសំរាប់ឡើងបង្ហាញដល់ក្រុមតូចៗ ឬសិស្សទាំងអស់ស្តាប់ ដែលទាក់ទងទៅនឹងប្រធានបទនោះ: ○ ប្រើគំនូរ ឬកំណត់ត្រានៅលើក្តារខៀន ឬផ្ទាំងក្រដាស ដើម្បីជួយអោយអ្នកស្តាប់ងាយយល់	
• បង្ហាញវិធីយាបថក្នុងការស្តាប់ប្រកបដោយប្រសិទ្ធភាព ពេលស្តាប់ការឡើងបង្ហាញព័ត៌មាន: ○ បង្ហាញប្រធានបទសំខាន់នៃអត្ថបទ ○ កត់ត្រាចំណុចសំខាន់ៗនៃព័ត៌មានក្នុងអត្ថបទ	
• សរសេរពាក្យន័យផ្ទុយ នឹងពាក្យមួយចំនួននៅក្នុងអត្ថបទដែលខ្លួនសរសេរ	
• សរសេរតាមអានអត្ថបទ	
• រៀបចំសំណេរដោយផ្ទិតផ្ទង់ និងឡើងបង្ហាញបានត្រឹមត្រូវ	

មេរៀនទី៤: (៣០ ម៉ោ) **ទំព័រ ស.ស**

• អានរឿងខ្លីៗ ដោយខ្លួនឯង: ○ បង្ហាញពីព្រឹត្តិការណ៍នៃរឿង ○ ពិភាក្សាពីតំលៃអប់រំនៃរឿង ○ បង្កើតនិងឆ្លើយសំនួរមួយចំនួនដែលទាក់ទងទៅនឹងចំលើយតបរបស់តួអង្គក្នុងស្ថានភាពមួយចំនួននៃរឿង (តើចំលើយតបនេះបញ្ជាក់ពីអ្វីដែលទាក់ទងទៅនឹងអារម្មណ៍របស់តួអង្គ?តើអារម្មណ៍របស់តួអង្គត្រូវបានបង្ហាញត្រង់ឬបង្កប់ឬបង្ហាញទាំងពីរនៅក្នុងរឿងនោះដែរឬទេ?	១១៧ ១២៩

○ តើចំលើយតបផ្សេងៗទៀត របស់តួអង្គមាន អ្វីខ្លះទៀត?) ○ ឆ្លើយនឹងសំនួរ ដោយមានអំណះអំណាង ក្នុងរឿង	១២៩
• អនុវត្តវិធីស្ទ័យកែលំអមួយចំនួន ដើម្បីយល់ន័យនៃពាក្យពហុព្យាង្គ ដែលមិនធ្លាប់ស្គាល់	
• ចង្អុលបង្ហាញ និងប្រើប្រាស់កិរិយាអកម្មបានត្រឹមត្រូវ	
• រៀបចំ ព្រាង កែលំអ និងសរសេរសំរេចនូវរឿងនិទានវែង ដែលមានតួអង្គច្រើន (ដោយអនុវត្តវិធីស្ទ័យកែលំអមួយចំនួន រួមទាំងវចនានុក្រម)	
• ប្រើសញ្ញាផាត់លើបានត្រឹមត្រូវក្នុងសំណេរផ្ទាល់ខ្លួន	
• រៀបចំសំណេរដោយផ្ទិតផ្ទង់ និងឡើងបង្ហាញបានត្រឹមត្រូវ	
• បង្ហាញឥរិយាបថក្នុងការស្តាប់ប្រកបដោយប្រសិទ្ធភាព ពេលស្តាប់រឿងនិទានមួយចំនួន ដែលសិស្សដទៃទៀឡើង បង្ហាញ ដោយអាន ឮ : ○ កត់សំគាល់ផ្នែកណាល្អ នៃរឿងនិងផ្តល់មូលហេតុនៃការជ្រើសរើស	

មេរៀនទី ៥: (៣០ ម៉ោ) **ទំព័រ ស.ស**

• អានរឿងខ្លីៗ ដោយខ្លួនឯង: ○ បង្ហាញពីព្រឹត្តិការណ៍នៃរឿង ○ ពិភាក្សាពីតំលៃអប់រំនៃរឿង	១១៧
• ចង្អុលបង្ហាញនិងប្រើប្រាស់កិរិយាសកម្មបានត្រឹមត្រូវ	
• ជ្រើសរើសព្រឹត្តិការណ៍មួយក្នុងរឿងនិងសរសេរឡើងវិញហាក់ដូចជាតួអង្គណាមួយផ្តល់ទស្សនៈរបស់ខ្លួន នៅក្នុងព្រឹត្តិការណ៍នោះ: ○ ប្រើវាក្យសព្ទ ដែលបានមកពីអំណាននៃរឿងនិទានផ្សេងៗ នៅក្នុងរឿងរបស់ខ្លួន ○ ប្រើសញ្ញាសម្ព័ន្ធត្រឹមត្រូវនៅក្នុងសំណេររបស់ខ្លួន	
• អានផ្នែកដែលសរសេរឡើងវិញ អោយសិស្សក្នុងថ្នាក់ ឬតាមក្រុមស្តាប់	
• បង្ហាញឥរិយាបថក្នុងការស្តាប់ប្រកបដោយប្រសិទ្ធភាព ពេលស្តាប់រឿងដែលត្រូវបានសរសេរឡើងវិញ ○ បង្ហាញថាតួអង្គមួយណាដែលកំពុងនិយាយរឿងប្រាប់	
• សរសេរតាមអានអត្ថបទ	
• រៀបចំសំណេរដោយផ្ទិតផ្ទង់ និងឡើងបង្ហាញបានត្រឹមត្រូវ	

មេរៀនទី៦: (៣០ ម៉ោ) **ទំព័រ ស.ស**

• បង្ហាញឥរិយាបថក្នុងការស្តាប់ប្រកបដោយប្រសិទ្ធភាពពេលស្តាប់គ្រូពន្យល់តួនាទីផ្សេងៗដែលនឹងត្រូវ ធ្វើនៅក្នុងអង្គប្រជុំផ្លូវការជាក្រុម(ប្រធានអ្នកកត់ត្រា)និងអំពីឥរិយាបថដែលរំពឹងទុករបស់ក្រុមនៅក្នុង អង្គប្រជុំ (ការប្តូរវេន ការស្តាប់ដោយគ្មានការរំខាន)	

• ធ្វើការតាមក្រុមតូចៗ ដើម្បីពិភាក្សាពីទស្សនៈផ្សេងៗរបស់មនុស្ស (ឧ. មិនត្រូវអោយមានវិន័យនៅក្នុងសាលា ឬ ក្មេងស្រីសំខាន់ជាងក្មេងប្រុស)៖ o ជ្រើសរើសប្រធាន និងអ្នកកត់ត្រាក្នុងក្រុម o ធ្វើការពិភាក្សាអំពីបញ្ហាជាមួយមនុស្សម្នាក់ៗ(រួមទាំងប្រធានបទនិងកំណត់ត្រា) ម្នាក់ៗត្រូវចូលរួម ផ្តល់យោបល់យ៉ាងតិចណាស់ម្តង o អ្នកកត់ត្រាត្រូវរាយការណ៍ដល់ក្រុមអំពីកំណត់ត្រាដែលបានកត់លើចំណុចសំខាន់ៗនៅក្នុងការពិភាក្សា ហើយក្រុមត្រូវធ្វើការពិនិត្យថា តើកំណត់ត្រានោះត្រឹមត្រូវដែរឬទេ	
• អានអត្ថបទខ្លីមួយដោយខ្លួនឯង ដែលបង្ហាញពីមតិ ឬ ទស្សនៈដែលទាក់ទងទៅនឹងបញ្ហានោះ : o ឆ្លើយទៅនឹងសំណួរដែលទាក់ទងទៅនឹងបញ្ហានោះ ព្រមទាំងផ្តល់មូលហេតុ ដើម្បីគាំទ្រ	
• សង្កេត និងកត់ត្រាភាពខុសគ្នាមួយចំនួននៃភាសានិយាយ និងសរសេរ	
• សរសេរតាមអានអត្ថបទមួយដែលផ្តល់នូវមតិមួយ	
• ប្រើសញ្ញាវង់ក្រចកនៅក្នុងសំណេរផ្ទាល់ខ្លួនបានត្រឹមត្រូវ	
• ធ្វើលំហាត់ ដោយបំពេញពាក្យដែលខ្វះ	
• រៀបចំសំណេរដោយផ្ទិតផ្ទង់ និងឡើងបង្ហាញបានត្រឹមត្រូវ	

មេរៀនទី៧: (៣០ ម៉) **ទំព័រ ស.ស**

• ធ្វើការជាដៃគូ ដើម្បីអនុវត្តការផ្តល់ការណែនាំ និងធ្វើតាមការណែនាំ (ឧ. សិស្សទី១គូររូបងាយៗពីរនៅលើផ្ទាំងក្រដាសដោយពុំអោយសិស្សម្នាក់ទៀតឃើញរួចសិស្សទី១ណែនាំអោយសិស្សទី២គូរតាមរូបនោះ)	
• ពិនិត្យមើលភាពត្រឹមត្រូវនៃការណែនាំ ដោយធ្វើការប្រៀបធៀបរូបដែលគូរបន្ទាប់មកធ្វើលំហាត់នោះឡើងវិញ ប៉ុន្តែ នៅពេលនេះ សិស្សត្រូវសរសេរការណែនាំ និងធ្វើតាមការណែនាំដោយអាន	
• អានអត្ថបទខ្លីមួយដោយខ្លួនឯង ដែលផ្តល់ពីការណែនាំអោយធ្វើអ្វីមួយ: o ឆ្លើយទៅនឹងសំណួរដែលទាក់ទងទៅនឹងអត្ថបទស្តីពីការណែនាំ	១១២
• ចង្អុលបង្ហាញ និងប្រើប្រាស់សព្ទនាមសំណួរបានត្រឹមត្រូវ	
• សង្កេត និងកត់ត្រាភាពខុសគ្នាមួយចំនួនអំពីភាសានិយាយ និងសរសេរ	
• សរសេរតាមអានអត្ថបទណែនាំមួយ	
• ជ្រើសរើសប្រធានបទស្រដៀងគ្នា និងសរសេរអត្ថបទខ្លី ដែលផ្តល់ការណែនាំអោយធ្វើអ្វីមួយ (ឧ. រប្យៀបលេងល្បែងកំសាន្ត)	
• រៀបចំសំណេរដោយផ្ទិតផ្ទង់ និងឡើងបង្ហាញបានត្រឹមត្រូវ	

មេរៀនទី៨: (៣០ ម៉ោង) **ខែ: ស.ស**

• បង្ហាញតរិយាបថក្នុងការស្តាប់ប្រកបដោយប្រសិទ្ធភាព ពេលស្តាប់កំណាព្យ ដែលគេអាន ឮ : o កត់ត្រាគំនិតសំខាន់ៗ នៅក្នុងកំណាព្យ o ឆ្លើយនឹងសំនួរដែលទាក់ទងទៅនឹងកំណាព្យ	១៣៥
• ជ្រើសរើសកំណាព្យ អាន ឮ ៗ ដោយធ្វើការជាក្រុម • ហាត់ សាកល្បង និងឡើងអានអោយសិស្សក្នុងថ្នាក់រៀនស្តាប់: o ប្រើការលើកដាក់សំលេង ទឹកមុខ និងកាយវិការ ស្របទៅនឹងន័យក្នុងអត្ថបទ	
• អានកំណាព្យដែលបានជ្រើសរើស ដោយខ្លួនឯង: o អនុវត្តវិធីស្វ័យកែលំអ ដើម្បីយល់ន័យនៃពាក្យពហុព្យាង្គ o ឆ្លើយនឹងសំនួរដែលទាក់ទងទៅនឹងកំណាព្យ ស្របទៅនឹងន័យក្នុងកំណាព្យ	៤៣ ៤៣
• ប្រើប្រាស់សព្ទនាមចង្អុលបានត្រឹមត្រូវ	
• រៀបចំ ព្រាង កែលំអ និងសរសេរសំរេចកំណាព្យខ្លីមួយ	
• បង្ហាញពាក្យន័យដូច ន័យផ្ទុយនិងពាក្យសូរដូចទៅនឹងពាក្យមួយចំនួនដែលប្រើនៅក្នុងកំណាព្យរបស់ខ្លួន	
• រៀបចំសំណេរដោយផ្ទិតផ្តង់ និងឡើងបង្ហាញបានត្រឹមត្រូវ	

មេរៀនទី៩: (៣២ ម៉ោង) **ខែ: ស.ស**

• បង្ហាញតរិយាបថក្នុងការស្តាប់ប្រកបដោយប្រសិទ្ធភាពពេលស្តាប់អត្ថបទវែងក្នុងការសែតដែលគេអានឮ o បង្ហាញពីគោលបំណងនៃសេចក្តីរាយការណ៍ o ឆ្លើយនឹងសំនួរដែលទាក់ទងទៅនឹងសេចក្តីរាយការណ៍	
• អានអត្ថបទវែងក្នុងការសែត (សេចក្តីរាយការណ៍) ដោយខ្លួនឯង: o បង្ហាញពីគោលបំណងនៃសេចក្តីរាយការណ៍ o ឆ្លើយនឹងសំនួរដែលទាក់ទងទៅនឹងសេចក្តីរាយការណ៍ o បង្ហាញព្រឹត្តិការណ៍ និងទស្សន:នៅក្នុងសេចក្តីរាយការណ៍ o ផ្តល់មូលហេតុដែលអ្នកនិពន្ធបញ្ចូលរបាយការណ៍នេះក្នុងការសែត	
• អនុវត្តវិធីស្វ័យកែលំអ ដើម្បីយល់ន័យនៃពាក្យថ្មីៗ	
• បង្ហាញ និងប្រើប្រាស់ឈ្នាប់នៅក្នុងល្បះ	
• រៀបចំ ព្រាង កែលំអ និងសរសេរសំរេចសេចក្តីរាយការណ៍វែងនៅក្នុងការសែត តាមប្រធានបទ ដែលខ្លួនជ្រើស រើស: o បង្ហាញចំណុចសំខាន់ៗនៃអត្ថបទការសែត o ប្រើវាក្យសព្ទមួយចំនួនដែលបានមកពីអំណាននៃអត្ថបទការសែត ក្នុងសំណេរផ្ទាល់ខ្លួន	
• ប្រើសញ្ញាសម្ព័ន្ធនៅក្នុងសំណេរផ្ទាល់ខ្លួនបានត្រឹមត្រូវ	

• សរសេរតាមអានអត្ថបទមួយ	
• រៀបចំសំណេរដោយផ្ទិតផ្ទង់ និងឡើងបង្ហាញបានត្រឹមត្រូវ	

មេរៀនទី១០ : (៣០ ម៉ោ) **ទំព័រសៀវភៅ.ស**

• អានរឿងនិទានវែង ដោយខ្លួនឯង: o អនុវត្តវិធីស្វ័យកែលំអ ដើម្បីយល់ន័យនៃពាក្យថ្មីៗ	
• សរសេរសេចក្តីសង្ខេបរឿងនិទានដោយបញ្ជាក់: o អាយុរបស់អ្នកអាន អនុសាសន៍ដល់អ្នកអានដោយផ្តល់ហេតុ ផល o តួអង្គនៅក្នុងរឿង ភាពល្អិតល្អន់នៃការពណ៌នាអំពីតួអង្គ o លក្ខណៈរំភើបដែលធ្វើអោយអ្នកអានចាប់អារម្មណ៍ o ផ្នែកដែលល្អប្រសើរជាងគេនៅក្នុងរឿងនោះ o ផ្នែកដែលត្រូវកែលំអ	
• ប្រើសញ្ញាសម្ព័ន្ធនៅក្នុងសំណេរផ្ទាល់ខ្លួនបានត្រឹមត្រូវ	
• រៀបចំសំណេរដោយផ្ទិតផ្ទង់ និងឡើងបង្ហាញបានត្រឹមត្រូវ	
• បង្ហាញឥរិយាបថក្នុងការស្តាប់ប្រកបដោយប្រសិទ្ធភាព ពេលស្តាប់សេចក្តីសង្ខេប ដែលគេអាន ឮ : o បង្ហាញចំណុចស្រប និងចំណុចបដិសេធទៅនឹងសេចក្តីសង្ខេបនេះ	
• ចង្អុលបង្ហាញ និងប្រើប្រាស់សព្ទនាមឈ្មោះបានត្រឹមត្រូវ	

លទ្ធផលសិក្សាភាសាខ្មែរ ថ្នាក់ទី ៧

សមត្ថភាព	លទ្ធផលសិក្សា
ការស្តាប់	• ស្តាប់ កត់ត្រា សង្ខេបគំនិតសំខាន់ៗនៃអត្ថបទផ្សេងៗ ដែលបានស្តាប់
ការនិយាយ	• ប្រើរបៀបអាន ក៏រិតសួរសំលេង ការលើកដាក់សំលេងបានត្រឹមត្រូវច្បាស់លាស់ក្នុងពេលសន្ទនាតាមបរិបទផ្សេងៗ: o ឡើងបង្ហាញ (រៀបរាប់)ពីបទពិសោធ សួរ និងផ្តល់ព័តិមាន ធ្វើការអញ្ជើញ និងឆ្លើយតប នឹងការអញ្ជើញ o និទានរឿងឡើងវិញ o ឡើងសូត្រកំណាព្យ o រៀបចំ និងឡើងអានរឿងល្ខោន
	• ធ្វើទំនាក់ទំនងការងារជាដៃគូ ជាក្រុមតូច និងសិស្សក្នុងថ្នាក់ ប្រកបដោយប្រសិទ្ធភាព
	• ប្រើពាក្យសង្ឃសព្ទ និងរាជសព្ទមួយចំនួន ពេលនិយាយទៅកាន់អ្នកទាំងនោះ
ការអាន	• អានប្រឌិតកថាផ្សេងៗ (ព្រេងកថា ទេវកថា ល្ខោន និទានកថា...) និង បង្ហាញពី: o តួអង្គឯក និងតួអង្គរង o កាលអាកាស o តំលៃអប់រំនៃរឿង o វិភាគភាសាមួយចំនួនដែលប្រើប្រាស់នៅក្នុងអត្ថបទ (បុគ្គលិកកម្ម និមិត្តរូប ភាសាច្បាស់លាស់)
	• បង្ហាញគំនិតសំខាន់ដែលបង្ហាញត្រង់ និងគំនិតសំខាន់ដែលបង្កប់ក្នុងរឿង
	• **អានអត្ថបទកាព្យជាច្រើនបទ (កាកគតិ ពំនោល កុជង្គលីលា ព្រហ្មគីតិ បន្ទោលកាក...):** o បង្ហាញពីចំណាប់ចូន ផ្ទួន រណ្តំ o បង្ហាញពីកាព្យមាត្រ o បង្ហាញពីគំនិតសំខាន់ដែលបង្កប់នៅក្នុងកំណាព្យ o ផ្តល់យោបល់ក្នុងការជ្រើសរើសពាក្យមួយចំនួន ដែលប្រើក្នុងកំណាព្យប្រកបដោយប្រសិទ្ធភាព o វិភាគភាសាមួយចំនួនដែលប្រើប្រាស់នៅក្នុងអត្ថបទ (បុគ្គលិកកម្ម និមិត្តរូប ភាសាច្បាស់លាស់)
	• អានអត្ថបទប្រចាំថ្ងៃ និងអត្ថបទប្រឌិតកថា អត្ថបទសារព័តិមាន ពាក្យស្លោក និងពាក្យបណ្តៅ: o ចង្អុលបង្ហាញពីគោលបំណង និងអ្នកស្តាប់ /អ្នកអាន o ចង្អុលបង្ហាញ និងសង្ខេបគំនិតសំខាន់ៗ o វិភាគភាសាមួយចំនួនដែលអ្នកនិពន្ធប្រើប្រាស់ក្នុងអត្ថបទ (បុគ្គលិកកម្ម និមិត្តរូប ភាសាច្បាស់លាស់)

	• ប្រើវិធីផ្សេងៗ ដើម្បីយល់ន័យនៃពាក្យពហុព្យាង្គៈ o វិភាគទំរង់ពាក្យ o ប្រើទីសេចក្តី (ឧបបទ ទំហៀបដូច ទំហៀបផ្ទុយ...) o ពាក្យបន្ថែមដើម និងពាក្យបន្ថែមចុង
ការសរសេរ	• **សរសេរអត្ថបទ ដោយប្រើទំរង់ខុសគ្នា ដែលបំរើ អោយគោលបំណង និងអ្នកអានខុសៗគ្នា រួមមានៈ** o រឿងនិទានដែលមានកាលអាកាសច្រើន o អត្ថបទល្ខោនខ្លី ងាយៗ o អត្ថបទពិតកថា (ការអញ្ជើញ សេចក្តីណែនាំ ...)
	• **តែងកំណាព្យចំនួនពាវគ្គ ដោយប្រើបទពីរយ៉ាងតិចក្នុងចំណោមបទកាកគតិ ព្រហ្មគីតិ ពំនោលភុជង្គលីលា បន្ទោលកាក និងបទពាក្យ៧**
	• បំពេញទំរង់បែបបទងាយៗ តាមគំរូដែលគេអោយ (សលាកប័ត្រ ប័ណ្ណបណ្ណាល័យ...)
	• បង្ហាញ និងប្រើប្រាស់ផ្នាក់ពាក្យ ដូចជា នាម គុណនាម កិរិយា គុណកិរិយា សព្វនាម ប្រភេទល្បះមួយចំនួន និងទំរង់ល្បះ ទោល នៅក្នុងសំណេរផ្ទាល់ខ្លួន
	• បង្ហាញ និងប្រើប្រាស់ ចំណុចរាយ ដង្កៀប ទៅជា មកពី គូសពីរនិង ជើងក្អែកនៅក្នុងសំណេរផ្ទាល់ខ្លួន
ធ្វើការជាក្រុម	• ចូលរួមយ៉ាងសកម្មក្នុងការជួយដៃគូ ឬក្រុម ដើម្បីបំពេញការងារ

កំណត់សំគាល់ៈ អក្សរខ្មៅដិតច្បាស់នៅក្នុងលទ្ធផលសិក្សាគឺដកចេញមកពីស្តង់ដា ជាចំណុចដែលកំណត់អោយសិស្ស ត្រូវតែសំរេចអោយបាននៅដំណាច់ឆ្នាំសិក្សាថ្នាក់ទី៩។

មេរៀនភាសាខ្មែរ ថ្នាក់ទី ៧

មេរៀនទី ១: (២២ ម៉ោង) **ទំព័រ ស.ស**

• ណែនាំ ផ្តល់ព័តិមាន ពីខ្លួនឯងទៅអ្នកដទៃ	១២-១៨៨
• បង្ហាញតរិយាបថក្នុងការស្តាប់ប្រកបដោយប្រសិទ្ធភាព ពេលស្តាប់ការណែនាំ: o ថាឡើងវិញអំពីព័តិមានខ្លះដែលបានស្តាប់ ពីអ្នកដទៃ	
• អានឧទាហរណ៍ពីព្រេងកថា ដោយខ្លួនឯង: o ឆ្លើយសំនួរ ដើម្បីបង្ហាញការយល់ដឹងពីអត្ថន័យនៃរឿង o បង្ហាញពីលក្ខណៈពិសេសនៃព្រេងកថា o បង្ហាញពីតំលៃអប់រំនៃព្រេងកថា	៩
• ស្វ័យកែលំអ ដើម្បីយល់ន័យនៃពាក្យដែលពុំធ្លាប់ស្គាល់ ដោយប្រើវិធីផ្សេងៗ	៣៨-៥៣
• បំពេញចំរង់សំណេរបែបប្រឌិត បន្ទាប់ពីអានរឿងព្រេង: o រៀបចំ ព្រេង កែលំអ និងសរសេរសំរេចនូវកិច្ចការសំណេរខ្លី ៗ ជាអត្ថបទកាសែត ដែលពណិនាអំពីឧបត្តិហេតុ ស្រង់ចេញពីរឿងព្រេង រួមទាំងរឿងប្រឌិតមួយចំនួន	៨
• ប្រើសញ្ញាសម្ព័ន្ធចំណុចរាយ នៅក្នុងសំណេរផ្ទាល់ខ្លួនបានត្រឹមត្រូវ	
• បង្ហាញពាក្យន័យដូច និងពាក្យន័យផ្ទុយមួយចំនួន ធៀបទៅនឹងពាក្យដែលប្រើនៅក្នុងរឿងព្រេង	៧
• សរសេរតាមអានអត្ថបទ	
• រៀបចំសំណេរដោយផ្ទិតផ្ទង់ និងឡើងបង្ហាញបានត្រឹមត្រូវ	២៨
• ប្រាប់និងបង្ហាញប្រភេទល្បះមួយចំនួន (ល្បះបញ្ជាក់)	

មេរៀនទី ២: (២២ ម៉ោង) **ទំព័រ ស.ស**

• អានឧទាហរណ៍ពីទេវកថា ដោយខ្លួនឯង o ឆ្លើយសំនួរ ដើម្បីបង្ហាញពីតួអង្គឯក និងតួអង្គរង និង បង្ហាញពីការយល់ដឹងពីអត្ថន័យនៃរឿង o បង្ហាញពីលក្ខណៈពិសេសនៃទេវកថា o បង្ហាញពីតំលៃអប់រំនៃទេវកថា	១០ ១៨ ១៧
• ប្រើវិធីស្វ័យកែលំអ ដើម្បីយល់ន័យនៃពាក្យដែលពុំធ្លាប់ស្គាល់	១៩-១០៦
• រៀបចំ និងឡើងនិយាយប្រាប់ក្រុមសិស្ស ឬថ្នាក់រៀន: o និយាយមានភាពច្បាស់លាស់ និងសំនួនវោហារច្បាស់លាស់ o ភ្នែកសំលឹងទៅអ្នកស្តាប់ និងប្រើកាយវិការបានយ៉ាងមានប្រសិទ្ធភាព	
• បង្ហាញតរិយាបថក្នុងការស្តាប់ប្រកបដោយប្រសិទ្ធភាព ពេលស្តាប់សិស្សផ្សេងទៀតឡើងនិយាយរំលឹកចំណុច សំខាន់ៗនៃរឿង	

• បំពេញទំរង់សំណេរបែបប្រឌិតមួយ បន្ទាប់ពីអានរឿងព្រេង: o ប្រាប់ឡើងវិញពីឧបត្តិហេតុក្នុងរឿងព្រេងដោយប្រើសព្វនាមបុរិស:តាមទស្សន:របស់តួអង្គណាមួយ	២១
• ប្រើសញ្ញាសម្ព័ន្ធដង្សៀប នៅក្នុងសំណេរផ្ទាល់ខ្លួនបានត្រឹមត្រូវ	
• សរសេរតាមអានអត្ថបទ	
• រៀបចំកិច្ចការសំណេរដោយផ្ទិតផ្ទង់ និងឡើងបង្ហាញបានត្រឹមត្រូវ	២៨
• ប្រាប់និងបង្ហាញប្រភេទល្បះមួយចំនួន (ល្បះសំនួរ)	

មេរៀនទី ៣: (២២ ម៉ោង) **ទំព័រ ស.ស**

• អាននិងសូត្រកំណាព្យបទភុជង្គលីលា ពំនោល បន្ទោលកាក : o ឆ្លើយនឹងសំនួរ ដើម្បីបង្ហាញពីការយល់ដឹងពីអត្ថន័យនៃកំណាព្យ o បង្ហាញពាក្យចួន ផ្ទួន រណ្តំ និងកាព្យមាត្រ o បង្ហាញពីការប្រើប្រាស់ពាក្យផ្ទួននៅក្នុងកំណាព្យ	៣៤ ៣៥
• ប្រើវិធីស្ងួយកែលំអ ដើម្បីយល់ន័យនៃពាក្យដែលពុំធ្លាប់ស្គាល់	
• រៀបចំ និងឡើងសូត្រកំណាព្យបទភុជង្គលីលា តាមបទត្រឹមត្រូវ	
• បង្ហាញឥរិយាបថក្នុងការស្តាប់ប្រកបដោយប្រសិទ្ធភាព ពេលស្តាប់សិស្សដទៃសូត្រកំណាព្យ	
• រៀបចំ ព្រាង កែលំអ និងសរសេរសំរេចកំណាព្យបទភុជង្គលីលា ពំនោលបន្ទោលកាកយ៉ាងតិចបំផុតពាក្យ	
• បង្ហាញពីលក្ខណៈ និងភាសាអធិប្បាយ ដែលអ្នកនិពន្ធប្រើនៅក្នុងកំណាព្យ (និមិត្តរូប)	១១៣
• បង្ហាញ និងប្រើប្រាស់ប្រភេទសព្វនាមមួយចំនួន (សព្វនាមកម្មសិទ្ធិ សព្វនាមចង្អុល)	
• រៀបចំសំណេរដោយផ្ទិតផ្ទង់ និងឡើងបង្ហាញបានត្រឹមត្រូវ	

មេរៀនទី ៤: (២៤ ម៉ោង) **ទំព័រ ស.ស**

• អាន រឿងនិទានដែលមានរាជស័ព្ទ: o ឆ្លើយនឹងសំនួរ និងបង្ហាញពីការយល់ដឹងពីអត្ថន័យនៃរឿងនិទាន	២០២
• ប្រើវិធីស្ងួយកែលំអ ដើម្បីយល់ន័យនៃពាក្យដែលពុំធ្លាប់ស្គាល់	៣៨
• សរសេរអត្ថបទសំរាប់ល្បែងដើរតួខ្លី រួមទាំងពាក្យឧទាហរណ៍មួយចំនួន ដែលជារាជស័ព្ទ	
• រៀបចំ សំណេរដោយផ្ទិតផ្ទង់ និងឡើងបង្ហាញបានត្រឹមត្រូវ	២០៤
• ហាត់ និងអានអត្ថបទសំរាប់ល្បែងដើរតួខ្លី អោយក្រុមសិស្ស ឬថ្នាក់រៀនស្តាប់ឬ មើល: o ប្រើពាក្យសំរាប់និយាយទៅកាន់ព្រះរាជាឬរាជវង្ស បានត្រឹមត្រូវ o បង្ហាញពាក្យដែលប្រើជាមួយព្រះរាជានិងពន្យល់ពីការប្រើពាក្យទាំងនោះ (នៅពេលមើល និងស្តាប់ការឡើងអានអត្ថបទសំណេរសំរាប់ល្បែងដើរតួខ្លី)	
• ប្រាប់ និងបង្ហាញបានពីប្រភេទនាមមួយចំនួន (នាមករណៈឬនាមករណ៍ និងនាមការកៈឬនាមការក៍)	១៣៣

មេរៀនទី ៥: (២៤ ម៉ោង) **ទំព័រស.ស**

• បង្ហាញតរិយាបថក្នុងការស្តាប់ប្រកបដោយប្រសិទ្ធភាពេលស្តាប់សិស្សដទៃអានឮ o ឆ្លើយនឹងសំនួរ ដើម្បីបញ្ជាក់ការយល់ន័យអោយបានច្បាស់លាស់ o បង្ហាញពីការយល់ដឹងពីអត្ថន័យនៃព័តិមានដែលគេបានអាន	៩០ ១៣០
• បង្ហាញពីការប្រើប្រាស់ក៏រិតសូរសំលេង ការលើកដាក់សំលេង របៀបអានបានត្រឹមត្រូវច្បាស់លាស់ ពេល: o សួរ និងផ្តល់ព័តិមានទៅវិញទៅមក o អញ្ជើញ និងឆ្លើយតបការអញ្ជើញ o សំដែងល្បែងដើរតួពីការសន្ទនាតាមទូរស័ព្ទ	 ១៦៩
• អានឧទាហរណ៍នៃរឿងនិទានខ្លី ៗ រួមទាំងការបង្ហាញពីកាតព្វកិច្ចរបស់ពលរដ្ឋបានត្រឹមត្រូវ: o ឆ្លើយនឹងសំនួរ ដើម្បីបង្ហាញពីការយល់ដឹងពីអត្ថន័យនៃរឿងនិទាន o បង្ហាញឧទាហរណ៍នៃការពណិនាពីកាតព្វកិច្ចរបស់ពលរដ្ឋដែលស្រង់ចេញពីរឿងនិទានបានត្រឹមត្រូវ	 ២០៤
• ហាត់បំពេញចំរង់បែបបទដែលប្រើប្រាស់នៅក្នុងជីវភាពប្រចាំថ្ងៃបានត្រឹមត្រូវ: o សលាកប័ត្រ (ក្រដាសពតិមាន) o ប័ណ្ណបណ្ណាល័យ	១៤
• ប្រើសញ្ញាជើងក្អែក (+) នៅក្នុងសំណេរផ្ទាល់ខ្លួនបានត្រឹមត្រូវ	
• សរសេរតាមអានអត្ថបទ	
• រៀបចំកិច្ចការសំណេរដោយផ្ទិតផ្ទង់ និងឡើងបង្ហាញបានត្រឹមត្រូវ	
• ប្រាប់ និងបង្ហាញបានពីប្រភេទកិរិយាមួយចំនួន (កិរិយាសុទ្ធ និងកិរិយាហេតុ)	

មេរៀនទី ៦: (២២ ម៉ោង) **ទំព័រស.ស**

• អាន ពិភាក្សា និងឆ្លើយសំនួរទាក់ទងទៅនឹងការផ្សាយពាណិជ្ជកម្មមួយចំនួន: o បង្ហាញពីផលិតផល ឬព្រឹត្តិការណ៍ដែលកំពុងតែផ្សព្វផ្សាយ o បង្ហាញពីរបៀបផ្សព្វផ្សាយ ទាក់ទាញសាធារណជន ចំពោះផលិតផល ឬ ព្រឹត្តិការណ៍ណាមួយ o បង្ហាញពីព័តិមាននៅក្នុងការផ្សាយពាណិជ្ជកម្ម ដែលមាននិងពុំមានសារប្រយោជន៍ o បង្ហាញ និងព្យែករវាងការពិត និងគំនិតនៅក្នុងការផ្សាយពាណិជ្ជកម្ម	
• ឡើងបង្ហាញពីការផ្សាយពាណិជ្ជកម្មខ្លីមួយអោយក្រុមសិស្សឬថ្នាក់រៀនស្តាប់(ដូចជា ការផ្សាយពាណិជ្ជកម្មលើផ្ទាំងក្រដាសធំ កាសែត ទស្សនាវដ្តី ទូរទស្សន៍ វិទ្យុ): o បង្ហាញពីផលិតផល ឬព្រឹត្តិការណ៍ដែលកំពុងតែផ្សាយពាណិជ្ជកម្ម o បង្ហាញពីរបៀបផ្សព្វផ្សាយ ទាក់ទាញសាធារណជន ចំពោះផលិតផល ឬ ព្រឹត្តិការណ៍ណាមួយ o ផ្តល់យោបល់ផ្ទាល់ខ្លួនពីការផ្សាយពាណិជ្ជកម្ម ប្រកបដោយប្រសិទ្ធភាព	

• សរសេរ រៀបចំ រៀបរៀង និងឡើងបង្ហាញពីការផ្សាយពាណិជ្ជកម្ម តាមសារព័ត៌មានអំពីផលិតផលដែលខ្លួនជ្រើសរើស: o ប្រើព្រឹត្តិការណ៍ និងគំនិត o ប្រើភាសាបញ្ចុះបញ្ចូល o ប្រើរូបភាពបកស្រាយ និងការឡើងធ្វើការបង្ហាញប្រកបដោយប្រសិទ្ធភាព	
• បង្ហាញ និងប្រើប្រាស់ប្រភេទល្បះមួយចំនួន ក្នុងសំណេររបស់ខ្លួន (ល្បះបញ្ជា ឧទាន)	៤២-១៦៩
• រៀបចំសំណេរដោយផ្ទិតផ្ទង់ និងឡើងបង្ហាញបានត្រឹមត្រូវ	

មេរៀនទី ៧: (២២ ម៉ោង) **ឆមាស.ស**

• ស្តាប់កំណាព្យបទកាកគតិ ព្រហ្មគីតិ ដែលគេអានឮៗ: o ឆ្លើយសំនួរ ដើម្បីបង្ហាញពីការយល់ដឹងពីអត្ថន័យនៃកំណាព្យ	
• អាន និងសូត្រកំណាព្យបទកាកគតិ ព្រហ្មគីតិ : o ឆ្លើយសំនួរ ដើម្បីបង្ហាញពីការយល់ដឹងពីអត្ថន័យនៃកំណាព្យ o បង្ហាញពាក្យច្បូន និងកាព្យមាត្រ o បង្ហាញពីការប្រើប្រាស់ពាក្យផ្ទួននៅក្នុងកំណាព្យ	
• ប្រើវិធីស្វ័យកែលំអ ដើម្បីយល់ន័យនៃពាក្យដែលពុំធ្លាប់ស្គាល់	
• រៀបចំ ព្រោង កែលំអ និងសរសេរសំរេចកំណាព្យបទកាកគតិ ព្រហ្មគីតិ យ៉ាងតិចបំផុត៣ វគ្គ	
• បង្ហាញពីលក្ខណៈ និងភាសាអធិប្បាយ(បុគ្គលិកកម្ម)ដែលអ្នកនិពន្ធប្រើនៅក្នុងកំណាព្យ	១៦២
• បង្ហាញ និងប្រាប់ពីប្រភេទគុណកិរិយាមួយចំនួន (គុណកិរិយាកន្លែង គុណកិរិយាកាល គុណកិរិយាសំនួរ)	៧៥-១១៨
• រៀបចំសំណេរដោយផ្ទិតផ្ទង់ និងឡើងបង្ហាញបានត្រឹមត្រូវ	

មេរៀនទី ៨: (២៤ ម៉ោង) **ឆមាស.ស**

• ចូលរួមក្នុងការអានអត្ថបទល្ខោន: o បង្ហាញពីធាតុ និងទំរង់នៃអត្ថបទល្ខោន o ឆ្លើយនឹងសំនួរ ដើម្បីបង្ហាញពីការយល់ដឹងពីអត្ថន័យនៃអត្ថបទល្ខោន o បង្ហាញពីការប្រើប្រាស់ភាសាយ៉ាងមានប្រសិទ្ធភាព នៅក្នុងអត្ថបទល្ខោន	
• ប្រើវិធីស្វ័យកែលំអ ដើម្បីយល់ន័យនៃពាក្យដែលពុំធ្លាប់ស្គាល់	
• ធ្វើចំណែកថ្នាក់ពាក្យក្នុងអត្ថបទល្ខោន តាមក្រុមពាក្យ (នាម កិរិយា និងគុណនាម)	
• អានផ្នែកណាមួយនៃរឿងល្ខោន ដោយប្រើកិរិតសូរសំលេងការលើកដាក់សំលេងបានត្រឹមត្រូវច្បាស់លាស់តាមសំដីតួអង្គ	

• បង្ហាញតរិយាបថក្នុងការស្តាប់ប្រកបដោយប្រសិទ្ធភាពពេលស្តាប់សិស្សដទៃទ្បើងអានផ្នែកណាមួយ នៃរឿងល្ខោន	
• សរសេរសេចក្តីសង្ខេបខ្លីៗច្បាស់មួយ ពីរឿងល្ខោន	
• ប្រើសញ្ញាសម្ព័ន្ធទៅជា (>) មកពី (<) នៅក្នុងសំណេរផ្ទាល់ខ្លួនបានត្រឹមត្រូវ	
• បង្ហាញ និងប្រាប់បានពីគុណកិរិយាបរិមាណ និងទីតាំងគុណកិរិយាក្នុងល្បះ	១៣៩
• រៀបចំសំណេរដោយផ្ទិតផ្ទង់ និងទ្បើងបង្ហាញបានត្រឹមត្រូវ	

មេរៀនទី ៩: (២២ ម៉ោង) **ទំព័រស.ស**

• បង្ហាញតរិយាបថក្នុងការស្តាប់ប្រកបដោយប្រសិទ្ធភាពពេលស្តាប់ការពណិនាំពីការលេងល្បែងប្រជាប្រិយ o បង្ហាញគោលបំណងនៃល្បែងប្រជាប្រិយ o កត់ត្រាការណែនាំសំខាន់ៗ	
• ប្រាប់ទ្បើងវិញពីរបៀបលេងល្បែងប្រជាប្រិយ ដល់អ្នកដទៃ	
• រកឧទាហរណ៍ចេញពីប្រភពផ្សេងៗ នៃចំណុចខាងក្រោម: o សំនួនរៅហារសព្ទខ្មែរងាយៗ o ពាក្យស្លោក ចំរៀង ប្រជាប្រិយ o សុភាសិត o ពាក្យបណ្តៅ	
• ពិភាក្សា និងពន្យល់ពីអត្ថន័យតាមផ្នែកនីមួយៗ	៨៣
• បង្កើតពាក្យស្លោក ឬ សុភាសិតដោយខ្លួនឯង	
• សរសេរអត្ថបទចំរៀងប្រជាប្រិយខ្មែរមួយចំនួន	
• បង្ហាញ និងតាងល្បះទោលតាមទំរង់មូលដ្ឋាន	
• រកឧទាហរណ៍ពីក្នុងបទចំរៀង ដែលមានទំរង់ជាពាក្យកាព្យ (ឧ. ពាក្យជួន ភាសាច្បាស់លាស់ ភាសាពណិនា)	១៣៨-១៧៦

មេរៀនទី ១០: (២៤ ម៉ោង) **ទំព័រស.ស**

• អានរឿងនិទានវែង ដោយខ្លួនឯង: o ឆ្លើយសំនួរ ដើម្បីបង្ហាញពីការយល់ដឹងពីអត្ថន័យនៃរឿង o បង្ហាញលក្ខណៈពិសេសមួយចំនួននៃសំណេរ ដែលអ្នកនិពន្ធប្រើ (ឧ. ភាសាច្បាស់លាស់) o បង្ហាញពីតំលៃអប់រំនៃរឿងនិទាន	
• ប្រើវិធីស្ងួយកែលំអ ដើម្បីយល់ន័យនៃពាក្យដែលពុំធ្លាប់ស្គាល់	
• រកពាក្យបាលី សំស្ក្រឹត នៅក្នុងរឿងនិទាន	៩៨
• រៀបចំ និងឡើងនិយាយអំពីឧប្បត្តិហេតុដែលមិនអាចបំភ្លេចបាន អោយក្រុមសិស្ស ឬថ្នាក់រៀនស្តាប់: o ប្រើភាសាពណ៌នា ប្រកបដោយប្រសិទ្ធភាព o និយាយ ដោយមានការកំរិតសូរសំលេង ការលើកដាក់សំលេងបានត្រឹមត្រូវច្បាស់លាស់	
• រៀបចំ ព្រាង កែលំអ និងសរសេរសំរេចរឿងនិទានវែងមួយ ដែលមានកាលអាកាសច្រើន: o ប្រើភាសាពណ៌នា ប្រកបដោយប្រសិទ្ធភាព o ប្រើវាក្យសព្ទ ដែលបានមកពីការអាននៅក្នុងសំណេរផ្ទាល់ខ្លួន	
• ប្រើសញ្ញាសម្ព័ន្ធគូសពីរ (=)នៅក្នុងសំណេរផ្ទាល់ខ្លួនបានត្រឹមត្រូវ	
• បង្ហាញ និងតាងល្បះទោលតាមទំរង់មូលដ្ឋាន	
• រៀបចំសំណេរដោយផ្ទិតផ្ទង់ និងឡើងបង្ហាញបានត្រឹមត្រូវ	

លទ្ធផលសិក្សាភាសាខ្មែរ ថ្នាក់ទី ៨

សមត្ថភាព	**លទ្ធផលសិក្សា**
ការស្តាប់	• ស្តាប់ កត់ត្រា សង្ខេបគំនិតសំខាន់ និងសេចក្តីលំអិតនៃអត្ថបទផ្សេងៗ ដែលបានស្តាប់ • **វាយតំលៃការប្រើល្បឿន កិរិតសូរ ការលើកដាក់សំលេង និងការបន្ធឺពាក្យច្បាស់ក្នុងការនិយាយរបស់អ្នកដទៃ ដើម្បីសំរេចគោលបំណងអ្វីមួយ**
ការនិយាយ	• ប្រើរបៀបអាន កិរិតសូរសំលេង ការលើកដាក់សំលេង កាយវិការ និងទឹកមុខ បានត្រឹមត្រូវច្បាស់លាស់តាម ស្ថានភាពផ្សេងៗ o និយាយសូមអភ័យទោស o ឡើងសូត្រកំណាព្យ o រៀបចំ និងឡើងអានរឿងល្ខោន o ផ្តល់របាយការណ៍ពីព្រឹត្តិការណ៍ ហេតុការណ៍សំខាន់ៗ ដោយផ្តល់ និងពន្យល់មូលហេតុបានត្រឹមត្រូវ
	• ធ្វើទំនាក់ទំនងការងារជាដៃគូជាក្រុមតូច និងសិស្សក្នុងថ្នាក់ ដើម្បីបំពេញកិច្ចការ ដែលមានលក្ខណៈកាន់តែស្មុកស្មាញ ប្រកបដោយប្រសិទ្ធភាព
	• បង្កើនការប្រើសង្ឃសព្ទ និងរាជសព្ទបានច្រើន នៅពេលនិយាយទៅកាន់អ្នកទាំងនោះ
ការអាន	• អានប្រឌិតកថាផ្សេងៗ (រឿងនិទានខ្មែរបុរាណ ល្ខោន និងតុក្កតា) និង បង្ហាញពី : o រចនាបថនៃអត្ថបទ o ទំនាស់ក្នុងរឿង o ចំណោទបញ្ហានៅក្នុងរឿង
	• បង្ហាញគំនិតសំខាន់ដែលបង្ហាញត្រង់ និងគំនិតសំខាន់ដែលបង្កប់ក្នុងរឿង
	• អាន**កំណាព្យបទពាក្យ ៦.៧.៨.៩ :** o បង្ហាញពីចំណាប់ចួន ផ្ចួន រណ្តំ o បង្ហាញពីកាព្យមាត្រ o បង្ហាញពីគំនិតសំខាន់ដែលបង្កប់នៅក្នុងកំណាព្យ o ផ្តល់យោបល់ពីប្រសិទ្ធភាពនៃការប្រើប្រាស់ពាក្យមួយចំនួន
	• **អានឧទាហរណ៍**ពីអត្ថបទពិតកថា (ជីវប្រវត្តិ កាសែត សំបុត្រ សេចក្តីជូនដំណឹង ឬសេចក្តីប្រកាសព័ត៌មាន **អត្ថបទ បែបឃោសនា**) : o **បង្ហាញពីគោលបំណង និងអ្នកស្តាប់/អ្នកអាន** o **ចង្អុលបង្ហាញ** និងសង្ខេបគំនិតសំខាន់ៗ**ក្នុងអត្ថបទបញ្ចុះបញ្ចូល** o វិភាគ និងវាយតំលៃលើការប្រើប្រាស់ភាសា អំណះអំណាង និងបច្ចេកទេស ដែលលើកឡើងក្នុងអត្ថបទ

	• ប្រើវិធីផ្សេងៗ ដើម្បីយល់ន័យនៃពាក្យពហុព្យាង្គ: o ប្រើវចនានុក្រម និងបទានុក្រម
	• បង្ហាញពីពាក្យកម្ចីមួយចំនួនមកពីភាសាបរទេស
ការសរសេរ	• **សរសេរជាអត្ថបទដែលមានលក្ខណៈកាន់តែពិបាក ដោយប្រើទំរង់ខុសគ្នា ដែលបំរើអោយគោលបំណង និងអ្នកអានខុសៗគ្នា រួមមាន:** o រឿងនិទាន o អត្ថបទបែបពន្យះបញ្ចូលដែលបង្ហាញពីគំនិតច្រើន o **សេចក្តីប្រកាសព័ត៌មានពីសកម្មភាពរបស់សាលារៀន និងសហគមន៍** o សំបុត្រផ្សេងៗ (សួររកពត៌មាន សួរសុខទុក្ខ ជួយរំលែកទុក្ខ...)
	• **តែងកំណាព្យបទកាកគតិ ព្រហ្មគីតិ ពំនោល ភុជង្គលីលា... យ៉ាងតិច៥វគ្គ**
	• បង្ហាញពីកាលរបស់កិរិយា ទីតាំងគុណនាម និងនាមផ្សំ
	• បង្ហាញ និងប្រើប្រាស់ប្រភេទពាក្យ ដូចជាជំនួយកិរិយា គុណកិរិយា ធ្នាក់ ឈ្នាប់ នៅក្នុងសំណេរផ្ទាល់ខ្លួន
	• បង្ហាញ និងប្រើប្រាស់សញ្ញាដំពីរ និងសញ្ញាដំលើនៅក្នុងសំណេរផ្ទាល់ខ្លួន
ធ្វើការជាក្រុម	• ធ្វើការជាដៃគូ ឬក្រុមតូច ជាមួយអ្នកដែលមានសមត្ថភាពផ្សេងៗ

កំណត់សំគាល់: អក្សរខ្មៅដិតច្បាស់នៅក្នុងលទ្ធផលសិក្សាគឺដកចេញមកពីស្តង់ដា ជាចំណុចដែលកំណត់អោយសិស្សត្រូវតែ សំរេចអោយបាននៅដំណាច់ឆ្នាំសិក្សាថ្នាក់ទី៩។

មេរៀនភាសាខ្មែរ ថ្នាក់ទី៨

មេរៀនទី ១: (២២ ម៉ោង) ទំព័រសៀវភៅ.សិស្ស

• អានឧទាហរណ៍ពីជីវប្រវត្តិខ្លីៗ ដោយខ្លួនឯង: o ប្រើវិធីស្វែយកែលំអ ដើម្បីយល់ន័យនៃពាក្យពហុព្យាង្គដែលពុំធ្លាប់ស្គាល់ o បង្ហាញពីកម្មវត្ថុ និងសង្ខេបចំណុចសំខាន់នៃព័តិមាននៅក្នុងជីវប្រវត្តិ o បង្ហាញតរិយាបថរបស់អ្នកនិពន្ធចំពោះកម្មវត្ថុនៃជីវប្រវត្តិ និងផ្តល់មូលហេតុនៃចំលើយ	
• បង្ហាញសមាជិកគ្រួសារឬបុគ្គលណាម្នាក់ដែលមានវ័យចំណាស់នៅក្នុងភូមិសំរាប់ធ្វើជាកម្មវត្ថុក្នុងការសរសេរ ជីវប្រវត្តិ : o រៀបចំនិងធ្វើការជាដៃគូហាត់សួរសំនួរ(ដល់បុគ្គលនោះ)ដើម្បីយកព័តិមានសំខាន់ៗពីជីវិតរបស់គាត់ o សំភាសន៍បុគ្គលនោះ តាមសំនួរដែលបានរៀបចំ o ធ្វើការកត់ត្រាចំលើយដែលទទួលបាន អោយបានម៉ត់ចត់ ត្រឹមត្រូវ	
• ប្រើកំណត់ត្រាដែលបានមកពីការសំភាសន៍ ដើម្បីព្រាង កែលំអ និងសរសេរសំរេចជីវប្រវត្តិខ្លីអំពីសមាជិកគ្រួសារ ឬបុគ្គលដែលមានវ័យចំណាស់ម្នាក់នៅក្នុងភូមិ: o បញ្ចូលគ្រប់ពតិមានសំខាន់ៗទាំងអស់ ទៅតាមលំដាប់លំដោយត្រឹមត្រូវ o បញ្ចូលការពណិនាពីឧប្បត្តិហេតុគួរអោយចាប់អារម្មណ៍មួយចំនួនកើតឡើងនៅក្នុងជីវិតរបស់បុគ្គលនោះ	១៤០-១៤១
• ប្រើវណ្ណយុត្តិ ដំលើ (^{0}) នៅក្នុងសំណេរផ្ទាល់ខ្លួនបានត្រឹមត្រូវ	

មេរៀនទី ២: (២៦ ម៉ោង) ទំព័រសៀវភៅ.សិស្ស

• រៀបចំជាក្រុមតូចៗ ដើម្បីឡើងអានរឿងនិទានបុរាណខ្មែរ ឬសង្ខេបរឿងបុរាណខ្មែរ: o អោយសមាជិកក្រុមផ្សេងៗ ប្រាប់ផ្នែកផ្សេងៗនៃរឿង ឬ និយាយពីផ្នែកផ្សេងៗនៃតួអង្គ o រៀបចំ វីកហាត់ និងឡើងអាន	
• អានឧទាហរណ៍នៃរឿងនិទានបុរាណខ្មែរ : o បង្ហាញលក្ខណៈពិសេសផ្សេងៗនៃរឿងបុរាណខ្មែរ o បង្ហាញពីអ្នកនិពន្ធ និងកាលកំណត់តែង o ឆ្លើយនឹងសំនួរដើម្បីបង្ហាញការយល់ដឹងពីតួអង្គ កាលអាកាស និងដំណើររឿងបុរាណខ្មែរ o បង្ហាញពីតំលៃអប់រំនៃរឿងបុរាណខ្មែរ	៧ ៧.១៥.២២ ៧
• ប្រើវិធីស្វែយកែលំអ ដើម្បីយល់ន័យនៃពាក្យដែលពុំធ្លាប់ស្គាល់	
• រៀបចំ ព្រាង កែលំអ និងសរសេរសំរេចរឿងនិទានបុរាណខ្លីមួយ ដែលមានតួអង្គកាលអាកាសនាសម័យទំនើប ប៉ុន្តែ សំណេរជាបែបរឿងនិទានបុរាណខ្មែរ: o ប្រើវចនាបថក្នុងការសរសេរ និងពាក្យស័ព្ទមួយចំនួនដែលទាក់ទងនឹងរឿងនិទានបុរាណខ្មែរ	
• ប្រើសញ្ញាសម្ព័ន្ធដំពីរ (÷)នៅក្នុងសំណេរផ្ទាល់ខ្លួនបានត្រឹមត្រូវ	

• សរសេរតាមអានអត្ថបទ	
• រៀបចំសំណេរដោយផ្ទិតផ្ទង់ និងឡើងបង្ហាញបានត្រឹមត្រូវ	

មេរៀនទី៣ : (២២ ម៉ោង) **ទំព័រស.ស**

• ស្តាប់អត្ថបទរឿងនិទានខ្លីៗ រួមទាំងឈុតនៃទំនាស់ ឬការជជែកវែកញែកផ្ទាល់ខ្លួន : o ដាក់ចំណងជើងសមស្របទៅនឹងរឿង o បង្ហាញពីការសូមអភ័យទោស ដែលប្រើនៅក្នុងរឿង	
• អានអត្ថបទប្រលោមលោកខ្លី ដោយខ្លួនឯង ដោយ: o ឆ្លើយនឹងសំនួរ ដើម្បីបង្ហាញពីតួអង្គឯក តួអង្គរង	៣២-៣៩
• បង្ហាញពីកាលអាកាសនៃរឿងប្រលោមលោក: o បង្ហាញពីទំនាស់នៅក្នុងរឿង o បង្ហាញពីរចនាបថ និងភាសាអធិប្បាយរបស់អ្នកនិពន្ធ (ភាសារស់រវើក)	៣២-៣៩
• ធ្វើការជាដៃគូ: o បង្កើតជាឈុតមួយ ស្តីពីការសូមអភ័យទោសរបស់មនុស្សម្នាក់ចំពោះមនុស្សម្នាក់ទៀត o ហាត់និយាយពីការសូមអភ័យទោស រួមទាំងពន្យល់ពីទង្វើខុសឆ្គង	៤៦-៤៧
• អានដោយខ្លួនឯង នូវអត្ថបទរឿងនិទាន ដែលមានឈុតនៃទំនាស់ ឬ ការជជែកវែកញែក: o បង្ហាញពីមូលហេតុនៃទំនាស់ ឬការមិនចុះសំរុង o ពិភាក្សាអំពីរបៀបដែលទំនាស់នោះត្រូវបានដោះស្រាយ ឬអំពីរបៀបដោះស្រាយទំនាស់ o ពិភាក្សាពីអាកប្បកិរិយារបស់តួអង្គឯក	
• រៀបចំ ព្រាង កែលំអ និងសរសេរសំរេចសំបុត្រប្រឱតមួយ ដែលសំដែងពីការសូមអភ័យទោស	៤៩-៥១
• ប្រើសញ្ញាសម្ព័ន្ធ លាក់ ឬបេយ្យាល: នៅក្នុងសំណេរផ្ទាល់ខ្លួនបានត្រឹមត្រូវ	
• សរសេរតាមអានអត្ថបទវែងងាយៗ	
• រៀបចំសំណេរដោយផ្ទិតផ្ទង់ និងឡើងបង្ហាញបានត្រឹមត្រូវ	
• បង្ហាញបានពីប្រភេទសព្ទនាម (សព្ទនាមឈ្នាប់)	១៦៨-១៧៦

មេរៀនទី ៤: (២២ ម៉ោង) **ទំព័រស.ស**

• អានសំបុត្រប្រភេទផ្សេងៗ (ឧទាហរណ៍ សំបុត្រសាកសួរព័តិមាន សំបុត្រសួរសុខទុក្ខ សំបុត្រជួយរំលែកទុក្ខ) o បង្ហាញពីទំរង់ និងធាតុផ្សេងៗនៃសំបុត្រធម្មតា o ឆ្លើយសំនួរដែលទាក់ទងទៅនឹងសំបុត្រ ដើម្បីបង្ហាញការយល់ដឹងពីអត្ថន័យ	៦៦
• ធ្វើការជាដៃគូដើម្បីបង្កើតនិងហាត់សំដែងល្បែងដើរតួខ្លីៗអំពីការសន្ទនាតាមទូរស័ព្ទឬរវាងអ្នកសរសេរផ្ទើ និងអ្នកទទួលសំបុត្រ:	

○ បង្ហាញពីភាពខុសគ្នាមួយចំនួនរវាងភាសានិយាយ និងភាសាសរសេរ ○ បង្ហាញពីគុណសម្បត្តិ និងគុណវិបត្តិនៃទំនាក់ទំនងតាមទូរស័ព្ទ និងតាមសំបុត្រ	
• រៀបចំ ព្រាង កែលំអ និងសរសេរសំរេចសំបុត្រប្រភេទណាមួយ: ○ ប្រើទំរង់ និងធាតុនៃសំបុត្រ	
• ប្រើប្រាស់នាមឆ្សំនៅក្នុងសំណេរផ្ទាល់ខ្លួនបានត្រឹមត្រូវ	
• រៀបចំសំណេរដោយផ្ទិតផ្ទង់ និងឡើងបង្ហាញបានត្រឹមត្រូវ	

មេរៀនទី ៥: (២២ ម៉ោង) **ទំព័រសៀវភៅ**

• អាននិងសូត្រកំណាព្យបទពាក្យ ៦ ពាក្យ៧ ពាក្យ ៨ និងពាក្យ ៩ ដោយខ្លួនឯង: ○ ឆ្លើយនឹងសំនួរដើម្បីបង្ហាញពីការយល់ដឹងពីអត្ថន័យនៃកំណាព្យ ដូចជាភាសាដែលអ្នកនិពន្ធប្រើ ទំហៀបន័យ រឺឧបមាន ○ បង្ហាញពាក្យចួន ផ្ទួន រណ្តំ និងកាព្យមាត្រនៃកំណាព្យ ○ បង្ហាញពីការប្រើប្រាស់ពាក្យផ្ទួននៅក្នុងកំណាព្យ	៧០- ៧២.៨៣
• ប្រើវិធីស្វ័យកែលំអ ដើម្បីយល់ន័យនៃពាក្យដែលពុំធ្លាប់ស្គាល់	
• រៀបចំ និងឡើងសូត្រកំណាព្យតាមបទដែលខ្លួនជ្រើសរើសបានត្រឹមត្រូវ	
• បង្ហាញវិរិយាបថក្នុងការស្តាប់ប្រកបដោយប្រសិទ្ធភាព ពេលស្តាប់សិស្សដទៃសូត្រកំណាព្យ	
• រៀបចំ ព្រាង កែលំអ និងសរសេរសំរេចកំណាព្យបទពាក្យ ៦ យ៉ាងតិចបំផុត៣ វគ្គ	
• បង្ហាញពាក្យន័យដូច និងពាក្យន័យផ្ទុយមួយចំនួនធៀបទៅនឹងពាក្យដែលប្រើនៅក្នុងកំណាព្យ	
• រៀបចំសំណេរដោយផ្ទិតផ្ទង់ និងឡើងបង្ហាញបានត្រឹមត្រូវ	
• បង្ហាញ និងប្រើប្រាស់ប្រភេទល្បះទោលមួយចំនួន	

មេរៀនទី ៦: (២២ ម៉ោង) **ទំព័រសៀវភៅ**

• អានសេចក្តីប្រកាសព័ត៌មាន ឬជូនដំណឹង ដោយខ្លួនឯង: ○ ប្រើវិធីស្វ័យកែលំអ ដើម្បីយល់ន័យនៃពាក្យពហុព្យាង្គដែលពុំធ្លាប់ស្គាល់ ○ បង្ហាញពីគោលបំណង និង អ្នកអានព័ត៌មាន ○ សង្ខេបចំណុចសំខាន់ៗនៃពត៌មាន ○ រកចំលើយដើម្បីឆ្លើយទៅនឹងសំនួរនៅក្នុងអត្ថបទព័ត៌មាន	១៣៤- ១៣៧
• រៀបចំ ព្រាង កែលំអ និងសរសេរសំរេចសេចក្តីប្រកាសព័ត៌មានឬជូនដំណឹងអំពីសាលារៀន ឬព្រឹត្តិការណ៍នៅក្នុងសហគមន៏: ○ ប្រើទំរង់ដូចជាពណិ ស្រមោល សុំប្រអប់ ដើម្បីបង្ហាញព័ត៌មានអោយមានលក្ខណៈកាន់តែចាប់អារម្មណ៏ ហើយច្បាស់លាស់	
• ធ្វើការជាដៃគូ ហាត់ផ្តល់ព័ត៌មានផ្ទាល់មាត់ដល់អ្នកដទៃ និយាយពីព័ត៌មាន: ○ ប្រើសំណេរផ្ទាល់ខ្លួន ជាជំនួយក្នុងការផ្តល់ព័ត៌មាន	២២៥- ២២៤

• បង្ហាញតរិយាបថក្នុងការស្តាប់ប្រកបដោយប្រសិទ្ធភាព ពេលស្តាប់សិស្សដទៃ: o កត់ត្រាចំណុចសំខាន់ៗនៃព័តិមាន	៩៧ ៤៨
• ប្រើប្រាស់ពាក្យប្រាប់កាលរបស់កិរិយា(អតីតកាល បច្ចុប្បន្ន អនាគត)នៅក្នុងសំណេរផ្ទាល់ខ្លួនបានត្រឹមត្រូវ	

មេរៀនទី ៧: (២២ ម៉ោង) ទំព័រស.ស

• បង្ហាញតរិយាបថក្នុងការស្តាប់ប្រកបដោយប្រសិទ្ធភាព ពេលស្តាប់អត្ថបទបញ្ចុះបញ្ចូល ដែលគេអានញ: o បង្ហាញកម្មវត្ថុនៃអត្ថបទ o បង្ហាញពីគំនិតដែលបង្ហាញនៅក្នុងអត្ថបទ o កត់ត្រាសេចក្តីលំអិតមួយចំនួនដែលគាំទ្រគំនិត	៤៨
• អានឧទាហរណ៍ពីអត្ថបទបញ្ចុះបញ្ចូល ដោយខ្លួនឯង: o ប្រើវិធីស្វ័យកែលំអ ដើម្បីយល់ន័យនៃពាក្យពហុព្យាង្គដែលពុំធ្លាប់ស្គាល់ o បង្ហាញពីកម្មវត្ថុ និងគំនិតនៃអត្ថបទ o សង្ខេបអំណះអំណាងសំខាន់ៗនៅក្នុងអត្ថបទ ដើម្បីគាំទ្រគំនិត ដែលបានបង្ហាញ	
• រៀបចំ ព្រាង កែលំអ និងសរសេរសំរេចអត្ថបទបញ្ចុះបញ្ចូលអំពីប្រធានបទដែលបានជ្រើសរើស ដោយខ្លួនឯង: o បង្ហាញពីគំនិតផ្ទាល់ខ្លួន បានច្បាស់លាស់ o ផ្តល់មូលហេតុ និងអំណះអំណាង ដើម្បីគាំទ្រគំនិត o រៀបចំមតិជំទាស់ និងពន្យល់មូលហេតុ	
• បង្ហាញពីទីតាំង និងប្រើប្រាស់គុណនាមនៅក្នុងល្បះបានត្រឹមត្រូវ	

មេរៀនទី ៨: (២៤ ម៉ោង) ទំព័រស.ស

• ចូលរួមក្នុងការអានរឿងល្ខោនដែលមានលក្ខណៈស្មុគស្មាញ: o តាមរយៈការឆ្លើយនឹងសំនួរពង្រីកការយល់ដឹងអំពីរឿងល្ខោនបង្ហាញនិងពណិនាតួអង្គសំខាន់ៗនិងគំនិតសំខាន់ៗក្នុងរឿង o បង្ហាញពីការប្រើប្រាស់ភាសាប្រកបដោយប្រសិទ្ធភាពនៅក្នុងរឿងល្ខោន (ទំហៀបន័យ អារម្មណ៍របស់អ្នកនិពន្ធ)	
• ប្រើវិធីស្វ័យកែលំអ ដើម្បីយល់ន័យនៃពាក្យដែលពុំធ្លាប់ស្គាល់	
• អានផ្នែកណាមួយនៃរឿងល្ខោន ដោយមានការកំរិតសូរសំលេង ការលើកដាក់សំលេងបានច្បាស់លាស់	
• បង្ហាញតរិយាបថក្នុងការស្តាប់ប្រកបដោយប្រសិទ្ធភាព ពេលស្តាប់ផ្នែកណាមួយនៃរឿងល្ខោន	
• សរសេរសង្ខេបរឿងល្ខោនមួយ ដែលមានលក្ខណៈច្បាស់លាស់	
• ប្រើប្រាស់ពាក្យជាជំនួយកិរិយា នៅក្នុងសំណេរផ្ទាល់ខ្លួនបានត្រឹមត្រូវ	
• រៀបចំសំណេរដោយផ្ទិតផ្ទង់ និងឡើងបង្ហាញបានត្រឹមត្រូវ	

មេរៀនទី ៩: (២៤ ម៉ោង) **ទំព័រសៀវភៅ**

• ស្តាប់កំណាព្យបទពាក្យ៦ ពាក្យ ៧ ពាក្យ ៨ និងពាក្យ ៩: o បង្ហាញគំនិតសំខាន់ដែលបង្កប់ និងបង្ហាញត្រង់នៅក្នុងកំណាព្យ	១៦៣- ១៦៤
• អានកំណាព្យបទពាក្យ៦ ពាក្យ៧ ពាក្យ៨ និងពាក្យ ៩ ដោយខ្លួនឯង: o ឆ្លើយសំនួរ ដើម្បីបង្ហាញពីការយល់ដឹងពីអត្ថន័យនៃកំណាព្យ o បង្ហាញពាក្យចួន ផ្ទួន រណ្តំ និងកាព្យមាត្រ o បង្ហាញពីការប្រើប្រាស់ពាក្យមេតាផរនៅក្នុងកំណាព្យ	១៦៣- ១៦៤ ៩៩
• ប្រើវិធីស្វ័យកែលំអ ដើម្បីយល់ន័យនៃពាក្យដែលពុំធ្លាប់ស្គាល់	
• រៀបចំ និងឡើងសូត្រកំណាព្យដែលខ្លួនជ្រើសរើស តាមបទត្រឹមត្រូវ	
• បង្ហាញឥរិយាបថក្នុងការស្តាប់ប្រកបដោយប្រសិទ្ធភាព ពេលស្តាប់សិស្សដទៃសូត្រកំណាព្យ	
• រៀបចំ ព្រាង កែលំអ និងសរសេរសំរេចកំណាព្យបទពាក្យ ៦ យ៉ាងតិចបំផុត៣ វគ្គ	
• បង្ហាញពាក្យន័យដូច និងពាក្យន័យផ្ទុយមួយចំនួនធៀបទៅនឹងពាក្យដែលប្រើនៅក្នុងកំណាព្យរបស់ខ្លួន	
• រៀបចំកិច្ចការសំណេរដោយផ្ចិតផ្ចង់ និងឡើងបង្ហាញបានត្រឹមត្រូវ	

មេរៀនទី ១០: (២២ ម៉ោង) **ទំព័រសៀវភៅ**

• អាន ឧទាហរណ៍ពីរឿងនិទានដែលទាក់ទងទៅនឹងអក្សរសិល្ប៍រូបភាព: o ឆ្លើយសំនួរ ដើម្បីបង្ហាញពីការយល់ដឹងពីអត្ថន័យនៃរឿង o បង្ហាញភាពខុសគ្នារវាងរឿងនិទាន និងអក្សរសិល្ប៍រូបភាព o បង្ហាញពីរបៀបបង្កើតតួអង្គ កាលអាកាសនៅក្នុងអក្សរសិល្ប៍រូបភាព ធៀបនឹងរឿងនិទាន	២៤៧-២៥៥
• ធ្វើការជាដៃគូ ហាត់អានពាក្យរបស់តួអង្គមួយចំនួនក្នុងអក្សរសិល្ប៍រូបភាព ដោយត្រាប់តាមសូរសំលេង និងការលើកដាក់សំលេងនានារបស់តួអង្គ	
• សរសេរឡើងវិញអក្សរសិល្ប៍រូបភាព តាមទំរង់បែបរឿងនិទានខ្លីមួយ: o រៀបចំ ព្រាង កែលំអ និងសរសេរសំរេចរឿង	
• ប្រើប្រាស់ពាក្យ ជាធ្នាក់ ឈ្នាប់ នៅក្នុងសំណេរផ្ទាល់ខ្លួនបានត្រឹមត្រូវ	២៨០- ២៨១
• រៀបចំសំណេរដោយផ្ចិតផ្ចង់ និងឡើងបង្ហាញបានត្រឹមត្រូវ	

លទ្ធផលសិក្សាភាសាខ្មែរ ថ្នាក់ទី ៩

សមត្ថភាព	លទ្ធផលសិក្សា
ការស្តាប់	• **វាយតំលៃពីភាពទាក់ទងការបញ្ចុះបញ្ចូលនិងភាពច្បាស់លាស់នៃព័ត៌មាននិងគំនិតដែលនិយាយបង្ហាញដោយអ្នកដទៃ:** o ញែកវរាងពត៌មានឃោសនា និងអំណះអំណាង ដោយមានហេតុផល o វាយតំលៃលើភាពត្រឹមត្រូវនៃការទាញសេចក្តីសន្និដ្ឋានសមរម្យដោយផ្អែកលើអំណះអំណាងដែលមាន
ការនិយាយ	• ប្រើរបៀបអាន ក៏រិតសូរសំលេង ការលើកដាក់សំលេង កាយវិការ និងទឹកមុខ បានត្រឹមត្រូវ ច្បាស់លាស់ក្នុងពេល និយាយ ក្នុងបរិបទផ្សេងៗ: o **និយាយបង្ហាញពីព័ត៌មាន និងគំនិតផ្ទាល់ខ្លួនលើប្រធានបទដែលមានលក្ខណៈស្មុគស្មាញ** o ឡើងសូត្រកំណាព្យកាន់តែមានលក្ខណៈស្មុគស្មាញ
	o រៀបចំ និងឡើងអានរឿងល្ខោនកាន់តែមានលក្ខណៈស្មុគស្មាញ
	• **ចូលរួមដោយមានប្រសិទ្ធភាព ក្នុងស្ថានភាពជាក្រុម ដោយផ្តល់ព័ត៌មាន សួរសំនួរ បញ្ចេញយោបល់ ធ្វើសំណើ និងសង្ខេប** **បានត្រឹមត្រូវលើចំណុចសំខាន់ៗដែលបានស្តាប់ (ឧ. ការប្រជុំមួយ ដែលមានការរៀបចំជាមុន)**
	• ប្រើសង្ឃសព្ទ និងរាជ្យសព្ទកាន់តែមានលក្ខណៈស្មុគស្មាញ
ការអាន	• **អានឧទាហរណ៍ពីអត្ថបទបែបនិទានបុរាណ និងអត្ថបទបែបនិទានសម័យទំនើប ប្រភេទផ្សេងៗគ្នាដែលមានលក្ខណៈកាន់តែស៊ីជំរៅ និង** o **ចង្អុលបង្ហាញពីធាតុសំខាន់របស់វារួមមាន ការផ្តើមរឿង (ការណែនាំ) ដំណើររឿង (ភាពស្មុគស្មាញ) និងបញ្ចប់រឿង(ដំណោះស្រាយបញ្ហា)** o **ចង្អុលបង្ហាញពីរបៀបបង្ហាញតួអង្គ(ឧ.ប្រភេទនិទានបែបបុរសទី១ និងទី៣ ការប្រើភាសា ក្នុងការអធិប្បាយ) និងកាលអាកាស របស់អ្នកនិពន្ធ**
	• អានកំណាព្យ និងចំរៀង ដែលមានលក្ខណៈកាន់តែស្មុគស្មាញ: o **ពន្យល់ពីការប្រើបច្ចេកទេសផ្សេងៗ របស់អ្នកនិពន្ធ ក្នុងការតែងកំណាព្យបីបទខុសគ្នា រួមមានចំណាប់ចួន ផ្ទួនរណ្តំ** **ការប្រើប្រាស់ពាក្យ** o បង្ហាញពីគំនិតសំខាន់ដែលបង្កប់ និង មិនបង្កប់នៅក្នុងកំណាព្យ
	• **អានឧទាហរណ៍**ពីអត្ថបទពិតកថា (ជីវប្រវត្តិ រឿងនិទានបែបប្រវត្តិសាស្ត្រ អត្ថបទ**ពត៌មាន** និងការណែនាំ): o **បង្ហាញពីគោលបំណង និងអ្នកស្តាប់/អ្នកអាន** o ចង្អុលបង្ហាញ និងសង្ខេបគំនិតសំខាន់ៗ o វិភាគ និងវាយតំលៃលើការប្រើប្រាស់ភាសារបស់អ្នកនិពន្ធ ក្នុងអត្ថបទ
	• ប្រើវិធីផ្សេងៗ ដើម្បីយល់ន័យនៃពាក្យពហុព្យាង្គ: o បង្ហាញពីភាសាបាលី សំស្ក្រឹត និងភាសាផ្សេងៗ

ការសរសេរ	• **សរសេរអត្ថបទដែលមានលក្ខណៈកាន់តែពិបាក ដោយប្រើទំរង់ខុសគ្នា ដែលបំរើអោយគោលបំណង និងអ្នកអានខុសៗគ្នា រួមមាន:** o **សរសេរអត្ថបទសង្ខេបពីបញ្ហាមួយដោយលើកចំលើយពីរផ្សេងគ្នា ហើយផ្តល់ហេតុផល សំរាប់គាំទ្រដល់ចំលើយ របស់ខ្លួន ដោយប្រើប្រាស់កថាខណ្ឌបានត្រឹមត្រូវ** o អត្ថបទឡោនខ្លីៗ កាន់តែមានលក្ខណៈស្មុគស្មាញ o ប្រឌិតកំណត់ហេតុប្រចាំថ្ងៃ ឬ សំបុត្រ o អត្ថបទពិតកថា រួមទាំងអត្ថបទពតិមាន ការណែនាំ និងតែងសេចក្តី
	• តែងកំណាព្យបទពាក្យ ៦, ៧,៨ និងពាក្យ ៩
	• **បំពេញទំរង់បែបបទដែលប្រើប្រាស់ប្រចាំថ្ងៃ(មានលក្ខណៈពិបាក)បានត្រឹមត្រូវ រួមមានប្រវត្តិរូបផ្ទាល់ខ្លួន ពាក្យសុំប្រលង ពាក្យសុំចូលជាសមាជិក និងពាក្យសុំចូលបំរើការងារ**
	• បង្ហាញពីកំណើតរបស់នាម គុណនាម កិរិយាមួយចំនួន និងវិធីបង្កើតពាក្យ
	• **ចង្អុលបង្ហាញ និងប្រើប្រាស់ល្បះផ្សំ និងល្បះក្រែងក្នុងសំណេរផ្ទាល់ខ្លួនបានត្រឹមត្រូវ**
	• បង្ហាញ និងប្រើប្រាស់សញ្ញារបាទ ក្បៀសបើកបិទ... នៅក្នុងសំណេរផ្ទាល់ខ្លួន
ធ្វើការជាក្រុម	• **ដើរតួនាទីជាអ្នកដឹកនាំក្រុមម្នាក់ ប្រកបដោយប្រសិទ្ធភាព មានឥរិយាបថល្អ (ស្តាប់ ប្តូរវេន មិនរំខានដល់អ្នកដទៃ) និងការនិយាយគាំទ្រទស្សនៈមតិសមាជិកដទៃទៀត**

កំណត់សំគាល់: អក្សរខ្មៅដិតច្បាស់នៅក្នុងលទ្ធផលសិក្សាគឺដកចេញមកពីស្តង់ដា ជាចំណុចដែលកំណត់អោយសិស្សត្រូវតែសំរេចអោយ បាននៅដំណាច់ឆ្នាំសិក្សាថ្នាក់ទី៩។

មេរៀនមុខវិជ្ជាភាសាខ្មែរ ថ្នាក់ទី ៩

មេរៀនទី ១: (២២ ម៉ោង) **ទំព័រសៀវភៅ.ស**

• អានសេចក្តីសំរង់ចេញពីជីវប្រវត្តិផ្ទាល់ខ្លួន: o ប្រើវិធីស្វ័យកែលំអ ដើម្បីយល់ន័យនៃពាក្យពហុព្យាង្គដែលពុំធ្លាប់ស្គាល់ o បង្ហាញកម្មវត្ថុ និងសង្ខេបចំណុចសំខាន់ៗនៃព័ត៌មាន នៅក្នុងសេចក្តីសំរង់	
• បង្ហាញប្រភេទពាក្យដែលប្រើនៅក្នុងអត្ថបទដែលគេអានឮ	
• រៀបចំ ព្រោង កែលំអ និងសរសេរសំរេចជីវប្រវត្តិផ្ទាល់ខ្លួន: o ប្រាប់ពីព្រឹត្តិការណ៍តាមលំដាប់ត្រឹមត្រូវ ច្បាស់លាស់ o រករឿងផ្សេងៗដែលទាក់ទងទៅនឹងព្រឹត្តិការណ៍តាំងពីកុមារភាព o ប្រើសំណេរបែបពណ៌នា ប្រកបដោយប្រសិទ្ធភាព	៥០
• ប្រើសញ្ញារបាទ នៅក្នុងសំណេរផ្ទាល់ខ្លួនបានត្រឹមត្រូវ	២៩
• បង្ហាញពាក្យដែលចេញមកពីបាលី សំស្ក្រឹត	១៣
• ប្រើប្រភេទនាមជីវចល និងនាមអជីវចល នៅក្នុងសំណេរផ្ទាល់ខ្លួនបានត្រឹមត្រូវ	
• ឡើងបង្ហាញកិច្ចការសំណេរដោយផ្ទិតផ្ទង់ បានត្រឹមត្រូវ	
• ឡើងនិយាយអំពីផ្នែកណាមួយនៃជីវប្រវត្តិផ្ទាល់ខ្លួនដែលទាក់ទងទៅនឹងព្រឹត្តិការណ៍ឬទីកន្លែងឬបុគ្គលណាម្នាក់ដែលមិនអាចបំភ្លេចបានតាំងពីនៅកុមារភាពអោយក្រុមសិស្សឬសិស្សក្នុងថ្នាក់រៀនទាំងអស់ស្តាប់: o និយាយបានច្បាស់លាស់ ដោយប្រើភ្នែក និងភាសា កាយវិការយ៉ាងមានប្រសិទ្ធភាព	
• បង្ហាញឥរិយាបថក្នុងការស្តាប់ប្រកបដោយប្រសិទ្ធភាព ពេលស្តាប់សិស្សដទៃឡើងបង្ហាញ: o កត់ត្រាអំពីកម្មវត្ថុនៃការនិយាយ (ឧទ្ទេស) o កត់ត្រាអំពីប្រសិទ្ធភាពនៃការឡើងនិយាយបង្ហាញ	

មេរៀនទី ២: (២២ ម៉ោង) **ទំព័រសៀវភៅ.ស**

• ស្តាប់ចំរៀងប្រជាប្រិយខ្មែរ: o បង្ហាញឥរិយាបថក្នុងការស្តាប់ប្រកបដោយប្រសិទ្ធភាព o បង្ហាញពីកម្មវត្ថុ និងតំលៃអប់រំនៃចំរៀង o ឆ្លើយសំនួរ ដើម្បីយល់ន័យនៃបទចំរៀង ដោយយោងទៅលើផ្នែកណាមួយ o បង្ហាញលក្ខណៈនៃកំណាព្យមួយចំនួន ដែលមាននៅក្នុងបទចំរៀង	៣១
• អានកំណាព្យបទពាក្យ៦ ពាក្យ៧ ពាក្យ៨ និងពាក្យ ៩ ដោយខ្លួនឯង: o ឆ្លើយនឹងសំនួរ ដើម្បីបង្ហាញពីការយល់ដឹងពីអត្ថន័យនៃកំណាព្យ o បង្ហាញពាក្យចួន ផ្ទួន រណ្តំ និងកាព្យមាត្រ o ប្រាប់ពីអារម្មណ៍ ដែលបង្ហាញនៅក្នុងកំណាព្យ	២៣,២៥

o ប្រើវិធីស្ងួយកែលំអ ដើម្បីយល់ន័យនៃពាក្យដែលពុំធ្លាប់ស្គាល់	
• បង្ហាញពីមេតាផរ និងពន្យល់ពីន័យចំ និងន័យធ្យៀបនៃមេតាផរ	២៥
• បង្ហាញពីសុភាសិត និងពន្យល់ន័យចំ និងន័យធ្យៀបរបស់វា	៣៥.៩៥
• រៀបចំ ព្រាង កែលំអ និងសរសេរសំរេចកំណាព្យចំនួន ៥វគ្គ	
• ប្រើប្រភេទនៃនាមរូបី និងនាមអរូបី នៅក្នុងសំណេរផ្ទាល់ខ្លួនបានត្រឹមត្រូវ	
• រៀបចំសំណេរដោយផ្ទិតផ្ទង់ និងឡើងបង្ហាញបានត្រឹមត្រូវ	

មេរៀនទី ៣: (២៤ ម៉ោង) **ទំព័រសៀវភៅ**

• អានរឿងនិទានបែបប្រវត្តិសាស្ត្រ មានលក្ខណៈកាន់តែស្មុគស្មាញ : o ឆ្លើយសំនួរពង្រីកការយល់ដឹងទាក់ទងទៅនឹងតួអង្គនិងកាលអាកាសដើម្បីបង្ហាញពីការយល់ដឹងពីអត្ថន័យនៃរឿង o បង្ហាញពីទំរង់ និងធាតុនៃរឿងនិទាន (ការផ្តើមរឿង ដំណើររឿង ដំណោះស្រាយបញ្ហា) o បង្ហាញពីបញ្ហា ឬដំលោះសំខាន់ៗ ដែលពិពណ៌នានៅក្នុងរឿងនិទាន និងពណ៌នាពីវិធីដោះស្រាយ o ប្រើវិធីស្ងួយកែលំអ ដើម្បីយល់ន័យនៃពាក្យដែលពុំធ្លាប់ស្គាល់	
• បង្ហាញបានកំណើតរបស់នាមករណ៍ ឬករណៈនាម	៨១
• ប្រើសញ្ញាក្បៀសបើកបិទ នៅក្នុងសំណេរផ្ទាល់ខ្លួនបានត្រឹមត្រូវ	
• រៀបចំកិច្ចការសំណេរដោយផ្ទិតផ្ទង់ និងឡើងបង្ហាញបានត្រឹមត្រូវ	
• ស្តាប់ និងបង្ហាញឧទាហរណ៍ពីភាសាដែលប្រើសំរាប់និយាយទៅកាន់ព្រះសង្ឃ និងរាជវង្សានុវង្ស	
• ហាត់ប្រើប្រាស់ភាសាសំរាប់និយាយទៅកាន់លោកសង្ឃ និងសមាជិករាជវង្សានុវង្ស	

មេរៀនទី ៤: (២២ ម៉ោង) **ទំព័រសៀវភៅ**

• អានព័ត៌មានដែលមានទស្សនៈពីរផ្សេងគ្នានៅក្នុងប្រធានបទមួយ: o បង្ហាញពីប្រធានបទ o បង្ហាញពីទស្សនៈទាំងពីរទាក់ទងទៅនឹងប្រធានបទ o បង្ហាញពីមូលហេតុមួយចំនួន ដើម្បីគាំទ្រដល់ទស្សនៈនីមួយៗ o បង្ហាញពីបច្ចេកទេសក្នុងការបញ្ចុះបញ្ចូល o វាយតំលៃពីការវែកញែកទស្សនៈនីមួយៗ o បង្ហាញពីមតិផ្ទាល់ខ្លួនទាក់ទងទៅនឹងប្រធានបទ និងផ្តល់មូលហេតុមួយចំនួន ដើម្បីគាំទ្រមតិនោះ	១៦៣ ១៦៤
• បង្ហាញបានពីកំណើតរបស់នាមការក៍ ឬការកៈនាម	
• ចូលរួមក្នុងការជជែកវែកញែក(ដែលមានការរៀបចំ) អំពីប្រធានបទដោយមានវាគ្មិនពីរនាក់ទាំងសងខាង o រៀបចំ ព្រាង សរសេរ និងប្រើប្រាស់កំណត់ត្រា ដើម្បីជាជំនួយក្នុងការនិយាយ o ប្រើភាសាបញ្ចុះបញ្ចូល	

o ប្រើភាសា កាយវិការ ទឹកមុខ និងឥរិយាបថបញ្ចុះបញ្ចូល	
• បង្ហាញឥរិយាបថក្នុងការស្តាប់ប្រកបដោយប្រសិទ្ធភាព ពេលស្តាប់សិស្សដទៃឡើងនិយាយវែកញែក: o កត់ត្រាអំពីប្រសិទ្ធភាពនៃការឡើងបង្ហាញរបស់វាគ្នី	
• រៀបចំ ព្រាង កែលំអ និងសរសេរសំរេចអត្ថបទបែបបញ្ចុះបញ្ចូល អំពីប្រធានបទមួយ: o សរុបបញ្ហា o បង្ហាញទស្សន:ផ្ទាល់ខ្លួនបានច្បាស់លាស់ o ផ្តល់មូលហេតុ និងធ្វើការវែកញែក ដើម្បីគាំទ្រទស្សន: o បង្កើតទស្សន:ប្រឆាំង និងពន្យល់ពីមូលហេតុ	២២៥

មេរៀនទី ៥: (២៤ ម៉ោង) **ខែពិរស.ស**

• ស្តាប់កំណាព្យបទកាកគតិ ព្រហ្មគីតិ ពំនោល: o បង្ហាញគំនិតសំខាន់ដែលបង្កប់ និងមិនបង្កប់នៅក្នុងកំណាព្យ	៣៧, ១៤១
• អានកំណាព្យបទកាកគតិ ព្រហ្មគីតិ ពំនោល ដោយខ្លួនឯង: o បង្កើតសំនួរពង្រីកការយល់ដឹង ដើម្បីបង្ហាញពីការយល់ដឹងពីអត្ថន័យនៃកំណាព្យ o បង្ហាញពាក្យចួន និងកាព្យមាត្រ o បង្ហាញពីការប្រើប្រាស់ពាក្យស្នួននៅក្នុងកំណាព្យ	២៣
• ប្រើវិធីស្វ័យកែលំអ ដើម្បីយល់ន័យនៃពាក្យដែលពុំធ្លាប់ស្គាល់	
• រៀបចំ និងឡើងសូត្រកំណាព្យដែលខ្លួនជ្រើសរើស តាមបទត្រឹមត្រូវ	
• បង្ហាញឥរិយាបថក្នុងការស្តាប់ប្រកបដោយប្រសិទ្ធភាព ពេលស្តាប់សិស្សដទៃសូត្រកំណាព្យ	
• រៀបចំ ព្រាង កែលំអ និងសរសេរសំរេចកំណាព្យបទពំនោល យ៉ាងតិចបំផុត៣ វគ្គ	
• បង្ហាញពាក្យន័យដូច និងពាក្យន័យផ្ទុយមួយចំនួន ធ្យៀបនឹងពាក្យដែលប្រើនៅក្នុងកំណាព្យរបស់ខ្លួន	
• បង្ហាញពីកំណើតរបស់គុណនាម បានច្បាស់លាស់	១៩៤
• រៀបចំកិច្ចការសំណេរដោយផ្ទិតផ្ទង់ និងឡើងបង្ហាញបានត្រឹមត្រូវ	

មេរៀនទី ៦: (២២ ម៉ោង) **ខែពិរស.ស**

• ចូលរួមក្នុងការអានរឿងល្ខោនកាន់តែមានលក្ខណ:សុគស្ចាញ: o តាមរយ:ការឆ្លើយសំនួរពង្រីកការយល់ដឹងអំពីរឿងល្ខោន បង្ហាញ និងពណ៌នាតួអង្គសំខាន់ៗ និងគំនិតសំខាន់ៗក្នុងរឿង o បង្ហាញពីការប្រើប្រាស់ភាសា ប្រកបដោយប្រសិទ្ធភាព នៅក្នុងរឿងល្ខោន	
• ប្រើវិធីស្វ័យកែលំអ ដើម្បីយល់ន័យនៃពាក្យដែលពុំធ្លាប់ស្គាល់	
• អានផ្នែកណាមួយនៃរឿងល្ខោន ដោយមានការកំរិតសួរសំលេង ការលើកដាក់សំលេងបានច្បាស់លាស់	

• បង្ហាញពីការប្រើប្រាស់ប្រភេទនៃពាក្យបន្ថែមដើម និងបន្ថែមចុង នៅក្នុងសំណេរផ្ទាល់ខ្លួនបានត្រឹមត្រូវ	
• បង្ហាញឥរិយាបថក្នុងការស្តាប់ប្រកបដោយប្រសិទ្ធភាព ពេលស្តាប់ផ្នែកណាមួយនៃរឿងល្ខោន:	
• ប្រើឈុតមួយនៅក្នុងរឿងនិទានដែលបានអាននៅក្នុងថ្នាក់ សរសេរឈុតនោះឡើងវិញ ជាទំរង់បែបល្ខោន: o ប្រើប្រាស់ទំរង់បែបបទនៃល្ខោនបានត្រឹមត្រូវ o ប្រើការសន្ទនា ដើម្បីបង្កើនចំណាប់អារម្មណ៍ទៅលើបុគ្គលិកលក្ខណៈរបស់តួអង្គសំខាន់ៗ	
• រៀបចំកិច្ចការសំណេរដោយផ្ទិតផ្ទង់ និងឡើងបង្ហាញបានត្រឹមត្រូវ	

មេរៀនទី ៧: (២៤ ម៉ោង) **ធំពាក់ស.ស**

• អានអត្ថបទព័ត៌មានផ្សេងៗ ដោយខ្លួនឯង ដែលមានកម្មវត្ថុដូចគ្នា: o ឆ្លើយសំនួរពង្រីកការយល់ដឹង ដើម្បីយល់ន័យនៃអត្ថបទ o បង្ហាញពីលក្ខណៈពិសេសនៃអត្ថបទព័ត៌មាន ធៀបទៅនឹងអត្ថបទបែបឃោសនា	
• បង្ហាញពីការប្រើប្រាស់ប្រភេទនៃពាក្យក្តាយនៅក្នុងសំណេរផ្ទាល់ខ្លួនបានត្រឹមត្រូវ	
• ធ្វើការជាក្រុមតូច ដើម្បីបង្ហាញ និងសង្ខេបព័ត៌មានសំខាន់ ក្នុងអត្ថបទ	
• ធ្វើការជាក្រុមតូច ដើម្បីរៀបចំការឡើងនិយាយផ្ទាល់មាត់ពីបញ្ហា ដែលផ្តល់អោយ: o រៀបចំបែបបទនៃការឡើងបង្ហាញ ដើម្បីធ្វើអោយអ្នកស្តាប់មានការចាប់អារម្មណ៍ o ហាត់សាកល្បងដើម្បីឡើងបង្ហាញ o ឡើងបង្ហាញ o និយាយបានច្បាស់លាស់ ប្រើការកិរិតសូរសំលេង និងការលើកដាក់សំលេង	
• បង្ហាញឥរិយាបថក្នុងការស្តាប់ប្រកបដោយប្រសិទ្ធភាព ពេលស្តាប់ការឡើងបង្ហាញ: o វាយតំលៃប្រសិទ្ធភាពនៃការឡើងបង្ហាញ	
• បំពេញទំរង់បែបបទដែលប្រើប្រាស់ប្រចាំថ្ងៃបានត្រឹមត្រូវ រួមមាន ពាក្យសុំប្រលង ពាក្យសុំចូលជាសមាជិក	២២៦
• សរសេរតែងសេចក្តីពន្យល់បានត្រឹមត្រូវ	

មេរៀនទី ៨: (២២ ម៉ោង) **ធំពាក់ស.ស**

• អានអត្ថបទណែនាំដែលមានលក្ខណៈកាន់តែស្មុគស្មាញ : o បង្ហាញពីកម្មវត្ថុនៃអត្ថបទ o បង្ហាញពីទំរង់ និងធាតុសំខាន់ៗនៃអត្ថបទណែនាំ o ឆ្លើយសំនួរពង្រីកការយល់ដឹង ដើម្បីយល់ន័យនៃអត្ថបទ	
• សរសេរអត្ថបទណែនាំដោយខ្លួនឯង: o អនុវត្តតាមទំរង់ និងធាតុនៃអត្ថបទណែនាំ o បង្ហាញការណែនាំតាមលំដាប់លំដោយត្រឹមត្រូវ	

• ប្រើប្រភេទនៃពាក្យផ្សំ នៅក្នុងសំណេរផ្ទាល់ខ្លួនបានត្រឹមត្រូវ	
• រៀបចំកិច្ចការសំណេរដោយផ្ទិតផ្ទង់ និងឡើងបង្ហាញបានត្រឹមត្រូវ	
• រៀបចំ និងឡើងបង្ហាញពីការណែនាំមួយៈ o ប្រើអត្ថបទណែនាំផ្ទាល់ខ្លួន ជាមូលដ្ឋានសំរាប់រៀបចំឡើងបង្ហាញការពន្យល់មួយដល់សិស្សម្នាក់ទៀត ឬ ដល់សិស្សក្នុងថ្នាក់ o ឡើងបង្ហាញតាមលំដាប់លំដោយត្រឹមត្រូវ	
• វាយតំលៃការឡើងបង្ហាញពីការណែនាំរបស់សិស្សដទៃៈ o វាយតំលៃភាពច្បាស់លាស់នៃការណែនាំ o វាយតំលៃប្រសិទ្ធភាពនៃការប្រើប្រាស់សំលេង និងល្បឿននិយាយ	

មេរៀនទី ៩ៈ (២២ ម៉ោង) **ទំព័រស.ស**

• ស្តាប់កំណាព្យបទភុជង្គលីលា និងបន្ទោលកាកៈ o បង្ហាញគំនិតសំខាន់ដែលបង្កប់ និងបង្ហាញត្រង់នៅក្នុងកំណាព្យ	
• អានកំណាព្យបទភុជង្គលីលា បន្ទោលកាក ដោយខ្លួនឯងៈ o ឆ្លើយសំនួរពង្រីកការយល់ដឹង ដើម្បីបង្ហាញពីការយល់ដឹងពីអត្ថន័យនៃកំណាព្យ o បង្ហាញពាក្យចួន និងកាព្យមាត្រ o បង្ហាញពីការប្រើប្រាស់ពាក្យផ្ទួននៅក្នុងកំណាព្យ	
• ប្រើវិធីស្វ័យកែលំអ ដើម្បីយល់ន័យនៃពាក្យដែលពុំធ្លាប់ស្គាល់	
• រៀបចំ និងឡើងសូត្រកំណាព្យដែលខ្លួនជ្រើសរើស តាមបទត្រឹមត្រូវ	
• បង្ហាញឥរិយាបថក្នុងការស្តាប់ប្រកបដោយប្រសិទ្ធភាព ពេលស្តាប់សិស្សដទៃសូត្រកំណាព្យ	
• រៀបចំព្រាងកែលំអ និងសរសេរសំរេចកំណាព្យបទភុជង្គលីលា បន្ទោលកាកមួយអត្ថបទ ឬមួយវគ្គ	
• បង្ហាញ និងប្រើប្រាស់ល្បះផ្សំ នៅក្នុងសំណេរផ្ទាល់ខ្លួនបានត្រឹមត្រូវ	
• រៀបចំសំណេរដោយផ្ទិតផ្ទង់ និងឡើងបង្ហាញបានត្រឹមត្រូវ	

មេរៀនទី ១០ៈ (២៤ ម៉ោង) **ទំព័រស.ស**

• អានរឿងប្រលោមលោក ឬសំរង់រឿងប្រលោមលោក ដោយខ្លួនឯងៈ o ឆ្លើយនឹងសំនួរ ដើម្បីបង្ហាញពីការយល់ដឹងអត្ថន័យនៃរឿង o បង្ហាញពីរបៀបដែលអ្នកនិពន្ធបង្កើតតួអង្គសំខាន់ៗ និងកាលអាកាស o បង្ហាញពីប្រសិទ្ធភាពនៃសំណេរបែបពណិនា o បង្ហាញពីសមាសធាតុនៃរឿងប្រលោមលោក (ការផ្តើមរឿង ដំណើររឿង បញ្ចប់រឿង)	៥៥
• ប្រើវិធីស្វ័យកែលំអ ដើម្បីយល់ន័យនៃពាក្យដែលពុំធ្លាប់ស្គាល់	

• ធ្វើការជាដៃគូ ដើម្បីរៀបចំ ហាត់សាកល្បង និងឡើងបង្ហាញការសំភាសន៍បែបប្រឌិតមួយជាមួយនឹងតួអង្គណា មួយក្នុងរឿង អោយក្រុមសិស្ស ឬសិស្សក្នុងថ្នាក់ស្តាប់: o សហការជាមួយគ្នា ដើម្បីបង្កើតសំនួរ និងចំលើយ ដែលសមស្រប o បង្ហាញចំណេះដឹងពីតួអង្គតាមរយៈការឆ្លើយសំនួរ o និយាយបានច្បាស់លាស់ដោយមានល្បឿន ការកិរិតសូរសំលេងនិងការលើកដាក់សំលេងបានត្រឹមត្រូវ	
• រៀបចំ ព្រាង កែលំអ និងសរសេរសំរេចកំណត់ហេតុប្រចាំថ្ងៃ ឬសំបុត្របែបប្រឌិត ដែលមានតួអង្គណាមួយ ដកស្រង់ចេញពីរឿងប្រលោមលោក: o បង្ហាញបុគ្គលិកលក្ខណៈរបស់តួអង្គ តាមរយៈការប្រើប្រាស់ពាក្យ o ប្រើទំរង់ និងធាតុនៃសំណេរដែលបានជ្រើសរើសបានត្រឹមត្រូវ	
• បង្ហាញ និងប្រើប្រាស់ល្បះក្រង នៅក្នុងសំណេរផ្ទាល់ខ្លួនបានត្រឹមត្រូវ	
• រៀបចំកិច្ចការសំណេរដោយផ្ទិតផ្ទង់ និងឡើងបង្ហាញបានត្រឹមត្រូវ	